មុនីចាសាក់

# ពិជ័យសង្គ្រាម

# បុរាណតម្រាសឹក

ដោយ៖ ជ័យ សេន



©រក្សាសិទ្ធិ

ព.ស ២៥៥៨ គ.ស ២០១

ទទួលបានពីលោក ខ្មៅ ឃុនសំរិង ដល់ករុណាថ្មីរ
ដើម្បីដាក់ទុកក្នុង elibrary of Cambodia កញ្ញា 2015

# ពិជ័យសង្គ្រាម

# បុរាណតម្រាសឹក

www.elibraryofcambodia.org

# ពិជ័យសង្គ្រាម
# បុរាណាគម្ពីរសឹក

រៀបរៀងប្រែសម្រួល

ដោយ ៖ **ជ័យ សេន**

ការីកុំព្យូទ័រដោយ ៖ សាម ស៊ីណា

## សម្ពហាកម្មមុនីបាសាក់

បោះពុម្ពលើកទី១

អ្នកនិពន្ធរក្សាសិទ្ធិ

ព.ស. ២៥៥៨ គ.ស. ២០១៤

www.elibraryofcambodia.org

www.elibraryofcambodia.org

# មាតិកា

អារម្ភកថា ........................................i

ក្បួនព្យូហ៍សឹក ១២ប្រការ តម្រាពិជ័យ

សង្គ្រាមតេជោ យ៉ត ....................................១

ស៊ុនជឺ ពិជ័យសង្គ្រាម ១៣ជំពូក....................៤

សំណួរ-ចម្លើយបុរាណតម្រាសឹក....................១១២

សឹម៉ាពិជ័យសង្គ្រាម ......................................១៤៥

ល្បិចចៅក្រម....................................................១៥០

ឆាកប្រយុទ្ធ ......................................................១៥៦

ក្បួនយុទ្ធសាស្ត្រ.......................................... ១៧០

www.elibraryofcambodia.org

## សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម **អ៊ិន ទីម** អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ , លោកសាស្ត្រាចារ្យ **ឈាង ម៉ារាឌី**, លោក **លី ដារា** អតីតអាចារ្យបាលីជាន់ខ្ពស់, លោក **អៀង សុផាត់** អតីតប្រធានវរៈសេនាតូចវរៈហ្វឹកហ្វឺន ខេត្តតាកែវ, លោក **ញ្ញេន សុផាន់** អតីតសេនាធិការយោធាខេត្តតាកែវ និងពិសេស សូមថ្លែងអំណរគុណដល់លោក **ញ៉ែម ទិបុល** ដែលជានិច្ចកាលតែងតែជួយប្រឹក្សា និងជំរុញលើកទឹកចិត្តទាំងការសរសេរ ទាំងការបោះពុម្ពផ្សាយស្នាដៃទាំងនេះ។

សូមអរគុណជាអតិបរមា

www.elibraryofcambodia.org

**អារម្ភកថា**

ប្រវត្តិសាស្ត្រមនុស្សជាតិ ជាប្រវត្តិសាស្ត្រនៃការតស៊ូ។ កាលពីបុរេប្រវត្តិ មនុស្សតស៊ូជាមួយធម្មជាតិ តស៊ូជាមួយសត្វសាហាវ។ ពេលមានកម្មសិទ្ធិឯកជន មនុស្សចាប់ផ្តើមតស៊ូរវាងមនុស្ស និងមនុស្សគ្នាឯង មានការតស៊ូវណ្ណៈជាដើម។

ប្រវត្តិសាស្ត្រតស៊ូរបស់មនុស្សជាតិ ជានិច្ចកាលតែងផ្សារភ្ជាប់ទៅនឹងប្រវត្តិសង្គ្រាម ពីព្រោះន័យទូលំទូលាយរបស់សង្គ្រាម គឺការតស៊ូនោះឯង។ ហេតុនេះ ទោះជាសហគមន៍ជាតិ ឬប្រទេសជាតិ ធំតូចទាំងឡាយណាក៏ដោយ ក៏ហាក់ដូចជាមិនអាចចៀសផុតពីក្រិត្យក្រមនេះបានឡើយ។ អាស្រ័យ ដោយចំណុចចាប់ផ្តើមនេះហើយ ទើបកិច្ចការលើកកំពស់សិល្បៈសង្គ្រាម សិល្បៈនៃជំនាញជាញជ័យ ក៏ដូចជាសិល្បៈនៃភាពជោគជ័យ ក្នុងសមរភូមិប្រយុទ្ធទាំងឡាយ បានក្លាយទៅជាទ្រឹស្តី ជាមុខវិជ្ជាវិទ្យាសាស្ត្រជាតម្រូវការចាំបាច់សម្រាប់នាយទាហាន មេទ័ពតូចធំ ដែលជាអ្នកបញ្ជាការប្រយុទ្ធ ទាំងដោយផ្ទាល់ក្តី ទាំងដោយប្រយោលក្តី។ ក្នុងសមរភូមិប្រយុទ្ធ ក្រៅ



www.elibraryofcambodia.org

ពីកត្តាកម្លាំងទ័ព អាវុធយុទ្ធភណ្ឌ និងភាពអំណោយផលផ្សេងៗ អ្នកណាដែលក្តាប់ច្បាស់សិល្បសាស្ត្រសង្គ្រាម អ្នកនោះនឹងមានឱកាសឈ្នះច្រើនជាង បើគេជាភាគីខាងខ្លាំង។ ប៉ុន្តែក៏ជាឱកាសជួយបញ្ចៀសភាពបរាជ័យច្រើនជាងដែរសម្រាប់អ្នក ដែលជាភាគីខាងខ្សោយ។ ធម្មតាជាអ្នកខ្សោយ ប៉ុន្តែ គេចផុតពីភាពបរាជ័យបាន វាក៏សក្តិសម ស្មើដូចជាអ្នកឈ្នះនោះដែរ ។

ដោយបុរាណតម្រាសឹក បានប្រសូត្រចេញពីស្ថានភាពដូចនេះ ហើយទើបយើងអាចឈ្វេងយល់រកឃើញភាពអាថ៌កំបាំង ក្នុងក្បួនវិធី នៃការដឹកនាំទ័ពនាសម័យនោះ នៅក្នុងបុរាណតម្រាសឹកទាំងឡាយមានជាអាថ៌ដូចៈ ទាំងពីវិធីផ្តាច់ស្បៀង វិធីផ្តាច់ផ្លូវដឹកជញ្ជូន ដល់ការវាយលុកក្រុងកំពែង ដណ្តើមទីតាំង រហូតដល់វិធីឃុំគ្រងពលសេនា វិធីត្រួតត្រាកងទ័ព វិធីតែងតាំងមន្ត្រីយោធា តែងតាំងមេទ័ពជាដើម។ រាល់វិធីទាំងនោះ សុទ្ធសឹងតែជាវិធី ដែលលុះដោយគតិបណ្ឌិត បញ្ញាញាណ ប្រកដោយសិល្បៈលំអិតសុខុម របស់បុរាណជន ដែលជាបញ្ញាជន



www.elibraryofcambodia.org

ជាអ្នកក្លាហានជំនាញជាញជ័យនាសម័យនោះ។ ក្នុងភាពអាថ៌កំបាំងនោះ មានតាំងពីកលយុទ្ធវាយលុកផ្ទៃក្នុង បំបាក់ទឹកចិត្តមេទ័ពខ្មាំង រហូតដល់ធ្វើឲ្យបាក់ទឹកចិត្ត បាត់បង់ស្មារតីប្រយុទ្ធរបស់ជួរទ័ពខ្មាំង ហើយមានទាំងសិល្បវិធី មើលមេឃ មើលផ្កាយ មើលប្រផ្នូលអាក្រក់ល្អ ដែលជាកង្វល់របស់បណ្ដាមេទ័ពទាំងឡាយ ប៉ុន្តែបុរាណតម្រាសឹក មិនត្រឹមតែមានលក្ខណៈសាមញ្ញនៅកម្រឹតប៉ុណ្ណោះទេ។ បុរាណតម្រាសឹក នៅមានភាពអាថ៌កំបាំងជាច្រើនទៀត ដែលបានផ្ទុកទុកក្នុងទំព័រក្រាំងមាស ដោយឆ្លងកាត់បទពិសោធ៍ជាច្រើនតំណ ។ បុរាណតម្រាសឹកចិនជាតម្រាសឹក ដែលបានឆ្លងកាត់បទពិសោធន៍ជាក់ស្ដែង មានភាពហ្មត់ចត់ ហើយថែមទាំងមានការលើកកំពស់ទ្រឹស្ដីប្រកបដោយសុក្រិតភាពទៀតផង ។ វីរជនខ្មែរគ្រប់សម័យជំនាន់ ក្រៅពីសិក្សាតម្រាសឹករបស់ជាតិខ្លួន លោកតែងធ្វើការសិក្សាស្រាវជ្រាវក្បួនតម្រា ពីបណ្ដាប្រជាជាតិនានាលើពិភពលោក ជាពិសេសក្បួនតម្រារបស់ចិន យកមកគួបផ្សំជាមួយទ្រឹស្ដីរបស់ខ្មែរ ដើម្បីអនុវត្តន៍ជាក់ស្ដែងក្នុងភាព



www.elibraryofcambodia.org

ប្រាកដនិយមរបស់ខ្មែរសម្រាប់ខ្មែរ ។ ថ្វីត្បិតទ្រឹស្តី និងសិល្បៈយោធាទាំងឡាយ មកដល់បច្ចុប្បន្នមាន ការខុសប្លែកពីមុនច្រើន តែក៏មិនតិចដែរ នូវអ្វីដែល បានកត់ត្រាក្នុងក្រាំងមាសនៃបុរាណតម្រាសឹកនេះ វា គ្រាន់តែនៅមានអត្ថន័យជាប្រវត្តិសាស្ត្រដូច ដែលឯក សារតម្កល់ទុកអំពីអតីតកាលតែប៉ុណ្ណោះ ។ ប៉ុន្តែវា នៅមានក៏មិនតិចដែរ នូវសច្ចភាពក្នុងបុរាណតម្រាសឹក ដែលបច្ចុប្បន្ន នៅមានមូលតម្លៃរបស់វានៅឡើយ មានពាក្យពេជ្រឃ្លាប្រយោគ ដែលបានដកស្រង់ ចេញពីតម្រាសឹក ហើយក៏ក្លាយជាភាសាពេញនិយម ជាពាក្យស្លោកក្នុងជីវភាព និងការរស់នៅប្រចាំថ្ងៃជា បណ្តើរៗមានដូចជា៖ ធ្វើស្រែនិងទឹក ធ្វើសឹកនិងបាយ ល្បិចទល់មេឃ ល្បិចរត់ជាកំពូលល្បិច ស្គាល់យើង ដឹងគេ ច្បាំងមួយរយដងឈ្នះមួយរយដង សមរភូមិ ក្រោយមិនរឹងមាំ សមរភូមិមុខប្រៀបដូចរំសេវត្រូវ ទឹក ។ ល ។ ទាំងនេះវាហាក់ដូចជាពាក្យនិយាយរត់ មាត់ ចាំមាត់ទៅហើយ។ មានកត្តាខ្លះដែលអ្នកប្រាជ្ញ អ្នកក្លាហានជំនាញជាញជ័យសម័យបុរាណ លោក បានសរសេរ ចារទុកមកនោះ វានៅតែត្រូវ នៅតែ



www.elibraryofcambodia.org

មានន័យ សម្រាប់បច្ចុប្បន្ន ហើយនិងនៅតែត្រូវ នៅតែមានន័យ រហូតដល់អនាគតខាងមុខទៀតផង ។

បច្ចុប្បន្ន បុរាណតម្រាសឹក មិនត្រឹមតែមាននូវអត្ថន័យយោធាសុទ្ធសាតតែប៉ុណ្ណោះទេ។ បុរាណតម្រាសឹកបាននឹងកំពុងបានសន្សឹមៗ រំលាយខ្លួនដោយធ្វើដំណើរយ៉ាងស្ងប់ស្ងាត់ ចូលទៅក្នុងជីវភាពនិងការរស់នៅប្រចាំថ្ងៃនៃប្រជាជាតិនានា ហើយក៏បានក្លាយជាសិល្បៈក្នុងការប្រាស្រ័យទាក់ទង ជាសិល្បៈក្នុងការគ្រប់គ្រង ក៏ដូចជាអ្នកដែលទទួលការដឹកនាំ អ្នកដែលនៅក្រោមបង្គាប់បញ្ជាគេផងដែរ។ ដូចនេះ វាមិនមែនជាការសល់ ហើយក៏មិនមែនជារឿងមិនបានការនោះទេ បើមិននិយាយថា វាមិនមានសារប្រយោជន៍ ពេលដែលពិចារណាសិក្សាស្រាវជ្រាវឡើងវិញ នូវឧត្តមគំនិត ក្នុងបុរាណតម្រាសឹក។ ធ្វើដូចនេះទើបហៅថាបុរាណអភិរក្ស ទំនើបអភិវឌ្ឍ (អភិរក្សនិងអភិវឌ្ឍន៍) នៅពេលតែមួយ ។ ដែលជាមេទ័ព ជាអ្នកដឹកនាំ កាលបើបានអាន បានរៀនវិជ្ជាបុរាណតម្រាសឹក ក៏ជាឱកាសដើម្បីបានឈ្វេងយល់ថែមទៀត នូវអ្វីដែលជាក្បួន ជាសិល្ប៍វិធីត្រួតត្រាផែនដីបុរីនគរ នូវអ្វីដែលជាក្បួន ជាសិល្ប៍



www.elibraryofcambodia.org

វិធីឃុំគ្រងកងទ័ព ត្រីកពល បញ្ហាទ័ពប្រយុទ្ធរបស់លោកអ្នកនាសម័យដើម ហើយក៏នឹងបានយល់ថែមទៀតអំពីធម្មៈ ដែលជាកិច្ចការមិនមែនឥតប្រយោជន៍សម្រាប់ធ្វើជាមេទ័ព នាសម័យទំនើបយើងនេះ។ រីឯអ្នកទទួលបញ្ជាក្រោមបង្គាប់វិញ កាលបើបានអានបានសិក្សាបុរាណតម្រាសឹក ក៏នឹងបានយល់អំពីភារកិច្ច និងកាតព្វកិច្ច ក៏ដូចជាការលត់ដំខ្លួន ដើម្បីឈានឡើងខ្ពស់ឆ្ពោះទៅកាន់ភាពរុងរឿង ក្នុងពេលអនាគត ។ ទាំងនេះហើយដែលថា៖

( កាលបើយើងមិនបានបំភ្លេចចោលនរណាម្នាក់ដែលដើរមុនយើង នោះក៏គ្មាននរណាម្នាក់ដើរក្រោយយើង គេបំភ្លេចយើងចោលដែរ )។

យើងខ្ញុំ ពុំមែនជាអ្នកសិក្សាស្រាវជ្រាវវិស័យយោធា ហើយក៏ពុំមែនជាអ្នកចំបាំង ឬ ជាមេទ័ពនោះក៏ទេដែរ ។ ប៉ុន្តែគ្រាន់តែជាអ្នកដែលបានអានបានឮ និងបានយល់ ពីវិស័យនេះជាបង្គួរ ពិសេសបានរស់នៅឆ្លងកាត់ក្រោមភ្លើងសង្គ្រាម តាំងពីសម័យមុនឆ្នាំ ១៩៧៥ នៅស្រុកកំណើត រហូតមកដល់សព្វថ្ងៃនេះ ក៏បានអាន បានឈ្វេងយល់ ពីរឿងសង្គ្រាមថែមទៀត ទើបខិតខំប្រមែប្រមូលទិន្នន័យ



www.elibraryofcambodia.org

ពាក់ព័ន្ធទាំងឡាយ យកមកចងក្រង រៀបរៀងប្រែសម្រួល ជាបណ្តុំឯកសារ ជាក្រាំងសៀវភៅ ប៉ុន្តែដោយសារជានិច្ចកាល តែងតែគិតថា កាលបើទុកសម្រាប់អានខ្លួនឯង សម្រាប់ដឹងតែម្នាក់ឯង ខ្លាចក្រែងមានកំហុសជាមួយបុព្វជន កាលបើគិតតែបុគ្គលសួនតួ ខ្លាចក្រែងវិប្បដិសារីយ៍ស្តីបន្ទោស។ ម្លោះហើយក៏សម្រេចចិត្តរៀបចំបោះពុម្ព ដើម្បីផ្សព្វផ្សាយដល់មិត្តអ្នកអាន នូវឧត្តមគំនិត នៃបុរាណតម្រាសិកនេះ ទុកជាចំណងដៃជូនខេមរៈជន ដោយចំណែកមួយក្នុងពិជ័យសង្គ្រាមការពារទឹកដី ក្នុងពិជ័យសង្គ្រាម ដើម្បីបញ្ចៀសសង្គ្រាមសម្រាប់ខ្មែរ និងចំណែកមួយដើម្បីជាប្រយោជន៍ នៃជីវិតពិត។ ពុំនោះសោតវាក៏ជាតម្លៃ នៃចំណែកមួយដ៏សំខាន់ក្នុងការសិក្សាស្រាវជ្រាវផងដែរ។

រាល់ការខ្វះចន្លោះ រមែងកើតមានពុំខានឡើយ សូម្បីអ្នកដែលមានភាពហ្មត់ចត់បំផុត គ្រាន់តែតិច ឬច្រើនតែប៉ុណ្ណោះ។ ហេតុនេះសូមស្វាគមន៍ ដោយក្តីសោមនស្ស ចំពោះការរិះគន់ កែតម្រូវក្នុងស្មារតីកសាងទាំងឡាយពីគ្រប់មជ្ឈដ្ឋាន។

ភ្នំពេញ, ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៤

**ជ័យ សេន**



www.elibraryofcambodia.org

www.elibraryofcambodia.org

# ក្បួនព្យូហ៍សឹក ១២ ប្រការ
## តម្រាពិជ័យសង្គ្រាម - តេជោ យ៉ត

❋❋❋

ទី១ : ត្រូវស្គាល់ទីណាត់ សម្រាប់លើកទ័ពជួបជុំគ្នា ព្រមទាំងទីបង្កប់ទ័ព និងទីសំញែងទ័ព។

ទី២ : ត្រូវតែស្គាល់ចិត្តពលទាហានឲ្យច្បាស់ តើពលទាហានទាំងនោះ គោរពកោតខ្លាចនិងទុកចិត្តលើមេទ័ពហើយឬនៅ?

ទី៣: ត្រូវស្គាល់ឲ្យច្បាស់នូវសូរស័ព្ទ ក្បួនទ័ពសឹករបស់បច្ចាមិត្តដែលចូលមក មេទ័ពមិនត្រូវភ្ញាក់ផ្អើល នឹងសូរស័ព្ទសន្ធឹកសឹក និងសូរសម្រែកសត្វ មនុស្ស ឬ ព័ត៌មានពាក្យចចាមអារាមផ្សេងៗនោះឡើយ បើឮហើយ ត្រូវពិចារណាឲ្យយល់ច្បាស់។

ទី៤ : ត្រូវតែស្គាល់ស្ថានភាពធាតុអាកាស រដូវកាលខ្យល់នៃតំបន់ ទីដែលចេញទៅប្រយុទ្ធនោះ។



www.elibraryofcambodia.org

ទី៥ : បើមុននឹងចូលច្បាំង ត្រូវស្គាល់ឲ្យច្បាស់នូវគ្រប់ច្រកទិសទីសម្រាប់ចូលប្រយុទ្ធ និងដកថយ។

ទី៦ : ត្រូវចេះប៉ាន់ស្មាន នូវកម្លាំង ស្បៀងអាហាររបស់សត្រូវ និងស្បៀងអាហាររបស់ខ្លួនយើង។

ទី៧: ត្រូវស្គាល់ឲ្យច្បាស់ប្រាកដ នូវកម្លាំងគ្រឿងសាស្ត្រាវុធ របស់ខ្លួនយើង និងរបស់សត្រូវ។

ទី៨ : ត្រូវស្គាល់ទីជ័យភូមិ ដែលនឹងត្រូវតាំងទីបន្ទាយវាយល្បាត។

ទី៩ : ត្រូវចេះស្ទាត់ស្ទាញ ប៉ិនប្រសប់ ក្នុងការចាត់តាំងយាមល្បាត គឺកុំទុកចិត្តគេឲ្យហួសពីគំនិតរបស់ខ្លួនយើង។

ទី១០: ត្រូវចេះប្រើសេនាទាហាន ប្រើឲ្យទៅធ្វើការឲ្យចេះថ្លឹងថ្លែង ឲ្យសមល្មមកម្លាំងទាហានយើង និង កម្លាំងទាហានសត្រូវ។

ទី១១: ត្រូវកាន់អាជ្ញាសឹកឲ្យរឹងមាំដូចផែនសិលា កុំត្រចៀក-ស ឆាប់ជឿគេ ដោយឥតពិចារណា។

ទី១២: រីឯព្រះករុណាម្ចាស់ជីវិត ដែលត្រាស់ប្រើមេទ័ពឲ្យចេញទៅច្បាំងនោះ ត្រូវប្រកាន់ពាក្យសត្យា



www.elibraryofcambodia.org

ឲ្យមេទ័ពទុកចិត្ត និងកុំព្រួយបារម្ភពីទ័ពក្រោយ
ឲ្យសោះ។ បានន័យថា បើមេទ័ពនោះរវល់នឹង
សមរភូមិមុខផង ហើយងាកមកខ្វល់រវល់ នឹង
សមរភូមិក្រោយទៀត មេទ័ពនោះនឹងប្រៀប
ដូចជារំសេវ ដែលត្រូវទឹក ទោះបីជាខំប្រឹង
បាញ់ រលាស់កែ ដូចម្ដេចក៏ពុំឆេះដែរ។

ព្យូហ៍សឹកទាំង១២ប្រការ តម្រាពិជ័យសង្គ្រាម
នេះហើយ គឺជាអាវុធដ៏សក្តិសិទ្ធិណាស់ សម្រាប់
យកឈ្នះលើបច្ចាមិត្ត! កុំថាឡើយត្រឹមពួកខ្មាំងបៀត
បៀនបះបោរ បង្កចលាចល កង្វល់នៅជាយដែន
នគរ រហូតដល់រាប់ម៉ឺនសែននាក់ក៏ដោយ ក៏គង់តែ
ចាញ់មេទ័ព ដែលស្ទាត់ជំនាញ ប្រកាន់ខ្ជាប់នូវក្បួន
តម្រាទាំង ១២ ប្រការនេះដែរ។

( **ឯកសារមហាបុរស** )



www.elibraryofcambodia.org

www.elibraryofcambodia.org

# ស៊ុនជី

## ពិជ័យសង្គ្រាម
## ១៣ ជំពូក

www.elibraryofcambodia.org

www.elibraryofcambodia.org

# ជំពូកទី១
# ប្រមាណការណ៍សឹក

**ស៊ុនជឺ** និយាយថា:

សង្គ្រាមជារឿងធំ ជាកិច្ចការសំខាន់ចាំបាច់របស់ប្រទេសជាតិ ទាក់ទងដល់អាយុជីវិតប្រជានុរាស្ត្រ ដល់ការបាត់បង់ គង់វង្ស ដល់សុខសន្តិភាព សុវត្ថិភាព បូរណភាពដែនដី ឬ ក្តីវិនាសសូន្យទឹកដីនៃ បុរីនគរ។

សង្គ្រាម ជាប្រធានបទនៃការចោទសួរដ៏ធំធេង សម្រាប់អ្នកដឹកនាំ អ្នកគ្រងនគរ ដែលត្រូវសិក្សាពិនិត្យ អង្កេត យ៉ាងយកចិត្តទុកដាក់ ហ្មត់ចត់បំផុត ដោយខានពុំបាន។

ដោយហេតុនេះ យើងត្រូវផ្អែកលើកត្តាជាមូលដ្ឋានប្រាំយ៉ាង ដើម្បីសិក្សាពិចារណាឲ្យបានល្អិតល្អន់ហ្មត់ចត់ ហើយធ្វើការវិភាគ ប្រៀបធៀប ផ្ទួរផ្ទង នូវរាល់កត្តាអាក្រក់ ល្អ រវាងកម្លាំងភាគីទាំងសងខាង



www.elibraryofcambodia.org

ប្រយោជន៍ឈ្នះយល់ពីស្ថានភាព នូវជោគវាសនាឈ្នះចាញ់ក្នុងសឹកសង្គ្រាម។

កត្តាទាំងប្រាំយ៉ាង រួមមាន ៖

មួយ=**សីល**(**តាវ**-Dao) ពីរ=**មេឃ**(**ធៀន**-Tian) បី=**ដី**(**ទី**-Di) បួន=**មេ**(**ស៊ាង**-Shang) និង ប្រាំ=**វិន័យ**(**ហ្វា**-Fa)។

-**សីល** គឺវិរតិចេតនា ដែលវៀរចាកអំពើអាក្រក់ ជាផ្លូវទៅកាន់សេចក្តីល្អ ដែលមានចរិតលក្ខណៈចរិយា គតិប្រកបដោយធម្មជាតិជាធម្មតា។ ក្នុងន័យម្យ៉ាងទៀត គឺជាធម្ម ដែលជាធម៌ ជាសភាវៈទ្រទ្រង់ជាភាពនៃសេចក្តីរីកចម្រើន ជាគោលច្បាប់ប្រទេស។ ពោលគឺបានដល់គោលមាគ៌ា និងកិច្ចការនយោបាយលុះក្នុងសច្ចគុណធម៌ សង្គមធម៌ ដែលត្រូវធ្វើយ៉ាងណាឲ្យឆន្ទៈប្រជានុរាស្ត្រ និងស្តេចផែនដី អ្នកដឹកនាំប្រទេស បានចុះសម្រុង និងឯកភាពគ្នា រួមចិត្តគំនិតក្នុងមនសិការតែមួយ។ ជានិច្ចកាលតែងគិតតម្កល់ផលប្រយោជន៍ជាតិជាធំ។ កាលបើធ្វើបានយ៉ាងដូចនេះ ទើបក្នុងភ្លើងសង្គ្រាម គេអាចប្រើឲ្យរាស្ត្រប្រជា



www.elibraryofcambodia.org

តស៊ូ ដើម្បីស្តេចផែនដី ដើម្បីអ្នកដឹកនាំប្រទេស ហ៊ានស៊ូប្តូរស្លាប់រស់ ដោយឥតខ្លាចញញើត ឬ ក្រែងរអែងចំពោះគ្រោះថ្នាក់ ក្តីវិនាសមហន្តរាយ ទោះទាំងទ្រព្យសម្បត្តិ ទាំងអាយុជីវិត ក៏ឥតស្តាយស្រណោះផងដែរ។

-**មេឃ** : គឺលំហអាកាសខាងលើ ដែលល្ហល្ហេវបានដល់ស្ថានភាពអាកាសធាតុ ពោលគឺអានុភាពនៃ ពេលវេលា ថ្ងៃយប់ រដូវកាល ក្តៅ ត្រជាក់ វស្សាប្រាំង មេឃស្រទំ ភ្លៀងរលឹម ឬមេឃស្រឡះជាដើម។ តាមរយៈ នៃធម្មជាតិទាំងនោះ នឹងអនុលោមសម្រប តាមកាល ធ្វើការដឹកនាំទ័ពប្រយុទ្ធយ៉ាងមានប្រសិទ្ធភាព។

-**ដី** : គឺទឹកដី ភូមិសាស្ត្រ សំដៅទៅលើ ទីតាំងភូមិសាស្ត្រ ដែលមានលក្ខណៈជាជ័យភូមិ ឬភូមិគ្រោះ ពោល គឺទីតាំងដែលមានដំណើរផ្លូវឆ្ងាយជិត ឬសណ្ឋានដីខ្ពស់ទាប ក្រវិចក្រវៀន កេលកុង រាបស្មើ...។ល។ ជាតំបន់ប្រតិបត្តិការសឹកទូលាយ ឬចង្អៀតជាភូមិសាស្ត្រគប្បី មានប្រយោជន៍ ដល់ការធ្វើការ



www.elibraryofcambodia.org

វាយលុក ការការពារ ការរុលទៅមុខ ឬដកថយ ដោយងាយស្រួល ល្អប្រសើរសម្រាប់ ជូរទ័ពយើង តែជាឧបសគ្គរាំង សម្រាប់ជូរទ័ពខ្មាំងឯណោះវិញ។

-**មេ** : គឺ មេកោយ បានដល់មេទ័ព មេកង នាយក្រុម តំណាងឲ្យគុណធម៌ គតិបណ្ឌិត ដែល ប្រកបដោយលក្ខណសម្បត្តិ ជាមេធា មានគំនិត ប្រាជ្ញាឈ្លាសវៃ មានកិត្យានុភាព មានចិត្តមេត្តាធម៌ សន្តោសប្រណី តែមានភាពក្លាហាន មោះមុត ហ្មត់ចត់ ដាច់ខាត និងស្មោះត្រង់។ ភាពជាអ្នកដឹកនាំប្រកប ដោយជំនាញជាញជ័យនៃមេទ័ព នាយកងទាំងឡាយ។

-**វិន័យ** : គឺក្រឹត្យ ច្បាប់ អាជ្ញា បានដល់ ក្រឹត្យក្រម ក្រមខ័ណ្ឌ អាជ្ញាសឹក ពោលគឺស្ថានភាព នៃការ ចាត់តាំង ការកំណត់សញ្ញា បទបញ្ជា ការ បែងចែក អំណាច នាទី ឋានន្តរស័ក្តិ ដល់មេទ័ព នាយទាហាន ពលទាហាន តាមឋានានុក្រមយោធា។ ការផ្គត់ផ្គង់សម្ភារៈ យុទ្ធោបករណ៍ យោធ បរិក្ខារ ស្បៀងអាហារ ឲ្យដល់កងទ័ព សេនាទាហាន សម្រាប់ជាគ្រឿងឧបភោគ បរិភោគ និង ការប្រើ



www.elibraryofcambodia.org

ប្រាស់គ្រប់យ៉ាង ពិសេសនៅក្នុងសមរភូមិប្រយុទ្ធ និង របបគ្រប់គ្រងផ្សេងៗ។

ដោយយោងតាមស្ថានភាព នៃគោលការណ៍ចម្បង ប្រាំយ៉ាង ដែលបានចែងខាងលើនេះ គ្រប់មេបញ្ជាការទាំងអស់ ដែលមានភាពជាអ្នកជំនាញជាញជ័យ ជាមេទ័ពក្នុង **ពិជ័យសង្គ្រាម** គឺមិនអាចថាមិនដឹង មិនយល់បានឡើយ ។ មានតែការក្តាប់ណែន យល់ច្បាស់អំពីចំណុចទាំងនេះ ទើបអាចយកជ័យជម្នះទៅលើសត្រូវ បានយ៉ាងពិតប្រាកដ ។ តែប្រសិនបើពុំបានយល់ដឹង អំពីចំណុច ទាំងនេះទេ គឺពុំអាចទទួលបានជោគជ័យឡើយ ។

ដើម្បីឈ្វេងយល់អំពីស្ថានភាពឈ្នះចាញ់ ក្នុងសឹកសង្គ្រាម យើងត្រូវពិនិត្យគិតសម្រេច ដើម្បីកំណត់លក្ខណៈ យុទ្ធសាស្ត្ររបស់កងទ័ព ពោលគឺធ្វើការប្រៀបធៀប ថ្លឹងថ្លែងនូវរាល់កត្តាផ្សេងៗ រវាងទាំងជួរទ័ពខ្មាំង ទាំងជួរទ័ពយើង ប្រកបដោយគតិបណ្ឌិតដោយចាប់ផ្តើមពីគោលការណ៍ មូលដ្ឋានទាំងប្រាំពីរ (៧) ចំណុចដូចខាងក្រោម ដែលថា :



www.elibraryofcambodia.org

១-តើព្រះមហាក្សត្រ ឬ ថ្នាក់ដឹកនាំប្រទេសខាងណា ដែលមានគោលនយោបាយស្របនឹងចិត្តរាស្ត្រ ពោលគឺបម្រើរាស្ត្របានល្អជាង?

២-តើមេទ័ពខាងណា ដែលមានសមត្ថភាពជាមេធា ប្រកបដោយគំនិត ប្រាជ្ញាឈ្លាសវៃ ជំនាញ-ជាញជ័យ ល្អប្រសើរជាង?

៣-តើមេឃដី ភូមិសាស្ត្រខាងណា ដែលមានអំណោយផលពីអាកាសធាតុ ក៏ដូចជាលក្ខណៈជ័យភូមិ ល្អ ប្រសើរជាង?

៤-តើក្រឹត្យវិន័យ ច្បាប់អាជ្ញាសឹក ខាងណាដែលមានការបដិបត្តិតឹងរឹង ម៉ឺងម៉ាត់ជាង?

៥-តើកងទ័ពខាងណាមានកម្លាំងខ្លាំងពូកែជាង?

៦-តើសេនា ពលទាហានកងទ័ពខាងណា ដែលបានទទួលការហ្វឹកហ្វឺនស្ទាត់ជំនាញខ្ពស់ជាង?

៧-តើកងទ័ពខាងណា ដែលមានការផ្តល់ជូនរង្វាន់ និងការដាក់ទោសខ្ជាប់ខ្ជួន ប្រកបដោយយុត្តិធម៌ សមធម៌ និងសុក្រឹតភាពជាង?



www.elibraryofcambodia.org

យោងតាមការពិចារណា ទៅលើល័ក្ខខណ្ឌដែលបានចែងខាងលើនេះ យើងនឹងអាចប៉ាន់ប្រមាណទស្សន៍ទាយ ដឹងមុនថាអ្នកណាឈ្នះ អ្នកណាចាញ់រួចជាស្រេចទៅហើយ។

បើនាយកង មេទ័ពណា បានស្តាប់បង្គាប់ ពាក្យណែនាំ គោរពបទបញ្ជា ជឿតាមកលយុទ្ធរបស់ខ្ញុំ (**ស៊ុន ជឺ**) ហើយឲ្យខ្ញុំបញ្ជាទ័ពប្រយុទ្ធ សឹកសង្គ្រាមនោះ នឹងទទួលបានជោគជ័យយ៉ាងពិតប្រាកដ ។ ពេលនោះកលយុទ្ធរបស់ខ្ញុំ មានតម្លៃទាំងគ្រប់កាលៈទេសៈក្នុងសង្គ្រាម ខ្ញុំនឹងនៅទីនេះតទៅទៀត តែបើមិនស្តាប់ពាក្យណែនាំ អំពីកលយុទ្ធរបស់ ខ្ញុំទេនោះ ទោះជាទុកឲ្យខ្ញុំបញ្ជាទ័ពប្រយុទ្ធដោយផ្ទាល់ក៏សង្គ្រាមនោះ នឹងមិនអាចទទួលជោគជ័យបានឡើយ។ រួបខ្ញុំក៏នឹងត្រូវចាកចេញពីទីនេះ ទៅជាមួយនឹងពាក្យណែនាំ នៃកលយុទ្ធដែលត្រូវបាត់តម្លៃនោះផងដែរ ។

កាលបើយុទ្ធវិធី និងស្ថានភាពពិត នៃសមរភូមិមានអំណោយផលល្អប្រសើរ ហើយថែមទាំង ទទួលបានការ អនុម័តក្នុងកម្រិតខ្ពស់លើសលប់ក៏ដោយ



www.elibraryofcambodia.org

ក៏ត្រូវតែស្វែងរកវិធីបង្កើតឲ្យបាន នូវស្ថានភាពអំណោយផលផ្សេងៗទៀត ដែលអាចប្រព្រឹត្តទៅបាន ដើម្បីជាកត្តាជំនួយខាងក្រៅ ជួយដល់ការចាប់ផ្ដើមនៃសឹកសង្គ្រាម។

ប្រៀប ស្មៀត ក្នុងរាល់ការច្បាំងគ្នា អាស្រ័យទៅលើការចេះស្វង់យល់ពីស្ថានភាពជាក់ស្ដែង ដែលជាអំណោយផល ដើម្បីបញ្ចេញសកម្មភាពសមស្រប។ ការដឹកនាំ ទ័ពប្រយុទ្ធក្នុងសឹកសង្គ្រាម គឺជាសកម្មភាពបោកបញ្ឆោត លៃបំភាន់ប្រកបដោយសិល្បវិធីជ្រាលជ្រៅ ល្អិតសុខុមនិងគំនិតបញ្ញាឈ្លាសវៃជាទីបំផុត។ ដូច្នេះ ធម្មតានៅពេលដែលអាចធ្វើការវាយប្រហារបាន យើងត្រូវធ្វើហាក់ដូចជាមិនអាច នៅពេលដែលយើងធ្វើសកម្មភាព យើងត្រូវធ្វើហាក់ដូចជា នៅស្ងៀមគ្មានសកម្មភាព បើចង់ធ្វើសកម្មភាពនៅទីជិត យើងត្រូវធ្វើឲ្យខ្មាំងគិតថានៅទីឆ្ងាយ បើធ្វើសកម្មភាពនៅទីឆ្ងាយ ត្រូវធ្វើឲ្យខ្មាំងជឿថានៅទីជិតវិញ។



www.elibraryofcambodia.org

សម្រាប់ពួកខ្មាំងដែលមានចិត្តលោភ យើងត្រូវចេះ យកផលប្រយោជន៍តូចតាចឲ្យវា ដើម្បីធ្វើនុយលួងលោម បញ្ឆោតឲ្យចូលអន្ទាក់របស់យើង។ បើទ័ពខ្មាំងកំពុងមានវិបត្តិ ស្មុគស្មាញ ត្រូវឆក់ឱកាសវាយប្រហារកំទេចវាចោល យកឈ្នះជាបន្ទាន់។ បើទ័ពខ្មាំងមានកម្លាំងមាំទាំគ្រប់ផ្នែក មានប្រដាប់អាវុធគ្រប់គ្រាន់ យើងត្រូវប្រុងជើងការប្រយ័ត្នខ្ពស់ចំពោះវា ហើយត្រៀមលក្ខណៈឲ្យបានហ្មត់ចត់ជាទីបំផុត។ បើទ័ពខ្លាំងមានកម្លាំងច្រើន ខ្លាំងលើសលប់ យើងត្រូវគេច ចេញពីទីនោះឲ្យឆ្ងាយសិន។ ចំពោះ បច្ចាមិត្តរបស់យើង ដែលជាមនុស្សមានចរិតឆេវឆាវ ឆាប់ខឹងយើងត្រូវរកវិធីញុះញង់ អុជអាល ធ្វើឲ្យគេកាន់តែច្រឡោតខឹងខ្លាំងទៀត។ ចំពោះ ខ្មាំងសត្រូវ ដែលមានការប្រមាថ មើលស្រាលយើង យើងត្រូវចេះរកវិធី ធ្វើឲ្យគេកាន់តែក្រអឺតក្រទម អួតអាងទ្វេឡើង។ តែបើទ័ពខ្មាំង ដែលមានការឈប់សម្រាកបានល្អយើងត្រូវរកវិធីរំខាន ដើម្បីឲ្យគេហេវហត់ឥតស្រាកស្រាន។ រីឯទ័ពខ្មាំង ដែលមានការសាមគ្គីផ្ទៃក្នុង



www.elibraryofcambodia.org

បានល្អ យើងត្រូវរកវិធីចាក់ចុច បំបែក បំបាក់ សាមគ្គី-ភាពនោះ ឲ្យខានតែបាន។ ធ្វើការវាយប្រហារខ្មាំងក្នុងពេលដែលខ្មាំង គ្មានការប្រុងប្រយ័ត្នទុកមុន។ ត្រូវធ្វើសកម្មភាពនៅត្រង់ចំណុច ដែលខ្មាំងមិនបានគិតស្មានដល់។ នូវរាល់កត្តាដែលបានចែងខាងលើទាំងនេះ សុទ្ធតែជាឧបាយកលនៃសឹកសង្គ្រាម ប្រកបដោយភាពឈ្លាសវៃ ដើម្បីទំនុកបម្រុង ដល់ការយកឈ្នះ សម្រាប់អ្នកចម្បាំង អ្នកជំនាញជាញជ័យ និងយុទ្ធវិទូទាំងឡាយ ប៉ុន្តែកិច្ចការសឹកសង្គ្រាមជាច្រើនពុំអាចដោះស្រាយ ដោយកំណត់ទុកជាមុនបានឡើយ។ ធម្មតាមុនពេលសង្គ្រាមចាប់ផ្តើម បើកប្រយុទ្ធ គេបានរៀបចំគម្រោងផែនការយុទ្ធសាស្ត្រតាំងពីក្នុងព្រះពន្លាជ័យ ឬ បន្ទាយជំរំទ័ពខ្លួន រួចហើយទើបពិនិត្យគិតសម្រេចទុកជាមុនថាអាចនឹងវាយយកឈ្នះបានគឺអាស្រ័យ ដោយការរៀបចំបានហ្មត់ចត់ គឺប្រាកដជាមានកត្តាឈ្នះច្រើន។

ប៉ុន្តែ បើមុនពេលបើកយុទ្ធនាការសឹក ហើយបានប្រមាណឃើញថា ពុំអាចយកឈ្នះទៅលើខ្មាំង



www.elibraryofcambodia.org

សត្រូវបាននោះ ក៏ព្រោះតែការគិតគូរ កំណត់សម្រេច ពុំបានហ្មត់ចត់ កត្តាឈ្នះក៏ពុំមានគ្រប់គ្រាន់។

កាលបើបានគិត ពិនិត្យ យ៉ាងហ្មត់ចត់ មានកត្តាឈ្នះច្រើន គឺអាចយកឈ្នះបានយ៉ាងពិតប្រាកដ តែបើគិតគូរ ពុំបានហ្មត់ចត់ កត្តាឈ្នះមានតិចតួច គឺពុំអាចយកឈ្នះទៅ លើបច្ចាមិត្តបានឡើយ។ ចំណង់អីបើពុំបានគិតគូរអ្វីសោះនោះ ហើយកត្តា យកឈ្នះទៅលើខ្មាំងសត្រូវ ក៏ពុំមានស្រមោលទៀតនោះ សួរថា តើយកឈ្នះម្ដេចនឹងបានទៅ?

ក្នុងពេលដែលបានពិនិត្យ អង្កេតថ្លឹងថ្លែង នូវគ្រប់ចំណុចល្អ អាក្រក់ និងកត្តាឈ្នះចាញ់ដូចបានរៀបរាប់ ខាងលើហើយនោះ ការកំណត់ថាអ្នកណាឈ្នះ អ្នកណាចាញ់ វាជារឿងអាចប្រមាណទុកមុនបានយ៉ាងប្រាកដច្បាស់ក្រឡែត ដូចពេលថ្ងៃ យ៉ាងនោះឯង។

❊❊❊❊❊



www.elibraryofcambodia.org

# ជំពូកទី២
# យុទ្ធនាការសឹក

**ស៊ុន ជឺ** និយាយថា :

ជាទូទៅ ក្នុងដំណើរការសង្គ្រាម ពេលបើកយុទ្ធនាការសឹក ដឹកនាំទ័ពប្រយុទ្ធ គឺជាពេលដែល ត្រូវកេណ្ឌ ប្រមូលកម្លាំង រទេះ រថសឹក រទេះសេះធំៗ សម្រាប់ដឹកជញ្ជូន រាប់ពាន់ កងទ័ពរាប់សែននាក់ ការនាំស្បៀង ដឹកជញ្ជូន ចម្ងាយផ្លូវរាប់ពាន់យោជន៍...។ ស្ថិតក្នុង ស្ថានភាពបែបនោះ ការចំណាយនៅសមរភូមិមុខ សមរភូមិក្រោយ ចំណាយ សម្រាប់ទទួលភ្ញៀវពន្លឺ គ្រប់បែបយ៉ាង រាប់បញ្ចូលទាំងការ ផ្គត់ផ្គង់ដល់បេសកកម្មការទូត និងការថែទាំ ការរក្សាបំប៉ន់ បំពេញបន្ថែម គ្រប់ខ្ទង់ចំណាយដែលត្រូវប្រើប្រាស់ រាប់ពាន់ គ្រណោតមាស ទើបអាចបើកយុទ្ធនាការសឹក ចេញដំណើរ ទ័ពរាប់សែននាក់ ប្រព្រឹត្តទៅដោយរលូន ល្អប្រសើរបាន។

គោលដៅចម្បងរបស់សង្គ្រាម គឺជ័យជម្នះ។



www.elibraryofcambodia.org

ការដឹកនាំទ័ពដ៏ធំសម្បើមយ៉ាងនេះ ដើម្បីចេញធ្វើសឹក តម្រូវការចាំបាច់ គឺទាមទារការប្រយុទ្ធយកឈ្នះឲ្យបានឆាប់រហ័សជាទីបំផុត។ ព្រោះបើអូសបន្លាយពេលវេលានៃការច្បាំង គឺធ្វើឲ្យកងទ័ព ត្រូវហេវហត់ល្វើយចិត្ត ស្មារតីប្រយុទ្ធរបស់កងទ័ពទាំងមូលក៏នឹងធ្លាក់ចុះ ដោយសភាពនោះហើយ ការវាយលុកកំពែងក្រុង បន្ទាយខ្មាំងក៏នឹងត្រូវខាតបង់កម្លាំងប្រយុទ្ធជាច្រើន។ សម្រាប់កងទ័ពដែលធ្វើយុទ្ធនាការនៅក្រៅប្រទេស (នគរ) រយៈពេលយូរ វានឹងធ្វើឲ្យខ្សឿនសេដ្ឋកិច្ច ហិរញ្ញវត្ថុ ពោលគឺធនធានប្រទេសជាតិហិនហោច ដោយចៀសមិនផុត។ កាលបើ កងទ័ពសេនាទាហានអស់កម្លាំង នឿយហត់ខ្លាំង ទឹកចិត្តប្រយុទ្ធធ្លាក់ចុះយ៉ាងដំណំទៀតនោះ ពេលនោះ ទោះណាជាឲ្យមានទីប្រឹក្សាពូកែ អ្នកចម្បាំងជំនាញជាញជ័យ យុទ្ធវិទូដ៏ចំណាន ក៏ពិបាកនឹងស្រោចស្រង់ស្ថានការណ៍ឡើងវិញបានដែរ ហើយពេលនោះផងដែរ ក៏ជាឱកាសសម្រាប់ប្រទេសជិតខាង ឬ ពួកស្តេចនៃសាមន្តប្រទេស (ប្រទេសចំណុះ) ឆ្លៀតឱកាស



www.elibraryofcambodia.org

វាយបក ឈ្លានពាន ទន្ទ្រានយើងវិញពុំខាន។ អាស្រ័យហេតុនេះ ការដឹកនាំទ័ព ធ្វើសឹកសង្គ្រាម តែងបានឮ អំពីភាពល្ងង់ខ្លៅ ចំពោះការប្រញាប់ប្រញាល់ក្នុងសឹកសង្គ្រាម ពោលគឺ ប្រយុទ្ធយកឈ្នះក្នុងមួយប៉ប្រិចភ្នែក រមែងតែងមានការខ្វះចន្លោះក្នុងយុទ្ធវិធី ប៉ុន្តែ ពុំដែលបានឮពាក្យសរសើរណាមួយអំពីភាពឈ្លាសវៃ ដែលភ្ជាប់ជាមួយនឹងការអូសបន្លាយពេលវេលា នៃការច្បាំងយកឈ្នះក្នុងសឹកសង្គ្រាមឡើយ។ ពុំដែលមានការអូសបន្លាយពេលវេលានៃការធ្វើសឹកសង្គ្រាមណាមួយ ដែលមាន ប្រយោជន៍ដល់ប្រទេសជាតិនោះទេ។ ហេតុនេះ អ្នកដែលមិនយល់ដឹងអំពីភាពអន្តរាយ ក្នុងការបញ្ជាទ័ព គេក៏មិនអាច យល់ដឹងបានដែរអំពីផលប្រយោជន៍ នៃការដឹកនាំទ័ព ធ្វើសឹកសង្គ្រាម។ អ្នកជំនាញជាញជ័យដឹកនាំទ័ពប្រយុទ្ធ គេមិនដែលកេណ្ឌប្រមូលពួកទាហាន ដែលរំសាយរួចហើយ យកមក ច្បាំងជាលើកទីពីរនោះឡើយ។ រីឯស្បៀងផ្គត់ផ្គង់កងទ័ពវិញ ក៏គេមិនឲ្យដឹកជញ្ជូនលើសពីចំនួនពីរដងដែរ។



www.elibraryofcambodia.org

រាល់សម្ភារៈបរិក្ខាកងទ័ព គឺនាំយកពីប្រទេសខ្លួន ចំណែកឯស្បៀងអាហារដែលមានអង្ករ ពោត សណ្តែក និងគ្រឿងឧបភោគបរិភោគផ្សេងៗ ត្រូវដោះស្រាយនៅនឹងកន្លែង គឺនៅលើទឹកដីរបស់បច្ចាមិត្ត នៅជុំវិញទីតាំងដែលកងទ័ពឈរជើង។ ធ្វើបានយ៉ាងដូចនេះ ទើបស្បៀងអាហារ និង ការផ្គត់ផ្គង់ដល់កងទ័ពនឹងបានគ្រប់គ្រាន់ ពេញលេញបរិបូរ។ ហេតុដែលប្រទេសត្រូវទទួលរងនូវភាពក្រីក្រ ដោយការនាំទ័ពធ្វើសឹកសង្គ្រាម ក៏ព្រោះតែផ្លូវត្រូវដឹកជញ្ជូនស្បៀងឆ្ងាយពេក។ ការដឹកជញ្ជូនស្បៀងផ្លូវឆ្ងាយនាំឲ្យមហាជន (ប្រជារាស្ត្រ) ក្រីក្រ។ នៅជុំវិញតំបន់ទីតាំងដែលទ័ពឈរជើង រាល់ទំនិញសព្វសារពើ តែងឡើងថ្លៃខ្ពស់កប់ពពក តម្លៃស្មុះឡើងខ្ពស់ នឹងធ្វើឲ្យលុយកាក់ ទ្រព្យសម្បត្តិរដ្ឋរីងស្ងួត សម្បត្តិរដ្ឋរីងស្ងួតគឺត្រូវតែប្រញាប់ប្រមូលពន្ធអាករ ពីរាស្ត្របន្ថែមជាបន្ទាន់។ កម្លាំងធនធានខាតបង់អស់ ទ្រព្យសម្បត្តិរីងស្ងួត នៅទូទាំងប្រទេស គ្រប់ទីជនបទនានា គ្រប់ក្រុមគ្រួសារ ផ្ទះសម្បែងល្ហល្ហេវ មានតែដំបូលឥត



www.elibraryofcambodia.org

ជញ្ជាំង។ ទ្រព្យសម្បត្តិរដ្ឋដប់ភាគ ត្រូវបាត់បង់អស់ប្រាំពីរភាគ ធនធានថវិកា ប្រទេសជាតិត្រូវខាតបង់យ៉ាងដំណំ ដូចជារទេះសេះ រថសឹក បាក់បែក ខូចបង់ សេះចាស់ៗហេវហត់ ជំងឺតំកាត់ ស្លាំងស្លម អាវក្រោះ មួកដែក ធ្នូព្រួញ ដាវ លំពែង ខែលដៃ ខែលខ្លួន និង ក្របី គោ រទេះធំ ដប់ភាគ ក៏ខូចខាតអស់ប្រាំមួយភាគដែរ។

ហេតុនេះ មេទ័ពខ្លាំងពូកែ ហើយឈ្លាសវៃ គឺជាមេទ័ពដែលចេះរិះរកវិធី ដោះស្រាយបញ្ហាស្បៀងនៅនឹងកន្លែង គឺនៅក្នុងប្រទេសរបស់បច្ចាមិត្តតែម្តង។ ស៊ីអង្ករមួយតៅនៅប្រទេសបច្ចាមិត្ត ស្មើនឹងម្ភៃតៅដែលនាំមកពីប្រទេសខ្លួន។ បានស្មៅ (ចំបើង) មួយបាច់ឲ្យសេះស៊ី នៅប្រទេសបច្ចាមិត្ត ស្មើនឹងស្មៅម្ភៃបាច់ នាំយកពីប្រទេសខ្លួន។

ដើម្បីឲ្យកងទ័ពក្លាហានមោះមុត ក្នុងការប្រយុទ្ធប្រហារខ្មាំងសត្រូវ គឺត្រូវធ្វើយ៉ាងណាឲ្យពួកគេមានចិត្តចងកំហឹងនឹងខ្មាំងសត្រូវយ៉ាងប្លូរប្លេជ្ញ ។ ដើម្បីដណ្តើមរឹបអូសយក សម្ភារៈ យុទ្ធោបករណ៍ និង



www.elibraryofcambodia.org

យោធបរិក្ខាររបស់ខ្មាំងសត្រូវ ត្រូវចេះប្រើប្រាស់វត្ថុសម្ភារៈទាំងនោះ និង ត្រូវចេះជូនជារង្វាន់ ដល់ពលសេនា ។ ដូចនេះ ក្នុងសមរភូមិប្រយុទ្ធ សង្គ្រាមទ័ពសេះ (យុទ្ធជនណា ឬក្រុមណា) កាលបើដណ្ដើមបានរថសឹកពីដប់គ្រឿងឡើងទៅ គឺត្រូវតែឲ្យរង្វាន់ដល់អ្នកណាដែលដណ្ដើម យកបានមុនគេបង្អស់។ ខណៈនោះ ត្រូវយកសញ្ញាទង់ជាតិរបស់ទ័ពខ្មាំងនៅលើរថសឹកទាំងនោះ ចោលចេញ ដោយដាក់ជំនួសសញ្ញាទង់ជាតិរបស់កងទ័ពយើងវិញ រួចហើយដាក់បញ្ចូលទៅក្នុងកងរថសឹក របស់កងទ័ពយើងសម្រាប់ប្រើប្រាស់តែម្ដង។ ចំពោះទ័ពខ្មាំងដែលយើងចាប់បានជាឈ្លើយសឹក ត្រូវរាប់អាន មើលថែទាំពួកគេ ឲ្យបានល្អប្រពៃ។ នោះហើយដែលថាជោគជ័យលើខ្មាំង និងធ្វើឲ្យយើងកាន់ តែខ្លាំងថែមទៀត។ ហេតុនេះ ការដឹកនាំទ័ពធ្វើសឹកសង្គ្រាមផលចំណេញ គ្រង់ឈ្នះរហ័ស ឈ្នះក្នុងមួយប៉ប្រិចភ្នែក។ បើអូសបន្លាយពេលវេលា នាំឲ្យខាតបង់ផលប្រយោជន៍កាន់តែច្រើន។



www.elibraryofcambodia.org

ហេតុនេះហើយ ទើបមានពាក្យដំណាលថា មេទ័ព ដែលចេះដឹកនាំទ័ពធ្វើសឹកសង្គ្រាម ជំនាញ ជាញជ័យ គឺជាអាទិទេព នៃវាសនាប្រជានុរាស្ត្រ ជាអ្នករក្សាការពារសុវត្ថិភាព សុខសន្តិភាពជូនប្រទេសជាតិ។



www.elibraryofcambodia.org

# ជំពូកទី៣
# កលយុទ្ធសង្គ្រាម

**ស៊ុន ជឺ** និយាយថា :

ជាទូទៅ គោលនយោបាយ ក្នុងក្បួនដឹកនាំទ័ព ការធ្វើឲ្យខ្មាំងសត្រូវទូទាំងប្រទេសខ្លបខ្លាច បាក់ស្បាត ចុះញ៉ម នោះជាកំពូលល្បិច ត្រឹកពលកៀងទ័ព ទៅវាយប្រហារប្រទេសជាគូសត្រូវ នោះជាគំនិតអន់ ក្តោបក្តាប់ស្មារតីទឹកចិត្តប្រយុទ្ធរបស់កងទ័ពខ្មាំងទាំងមូល ធ្វើឲ្យគេ បាក់ស្មារតី ទទួលចុះញ៉ម នោះជាកំពូលល្បិច។ កៀងពលបញ្ជាទ័ព ទៅវាយលុកទ័ពខ្មាំង នោះជាគំនិតអន់ ធ្វើឲ្យទ័ពខ្មាំងទាំងកងពល ស្ងប់ស្ងែងឫទ្ធិអំណាច ទទួលចុះញ៉ម នោះជាកំពូលល្បិច។ ត្រឹកពលទៅវាយប្រហារ នោះជាគំនិតអន់។ ធ្វើឲ្យកងសេនា ពលរេហ៍ក្នុងជួរទ័ពខ្មាំង គ្រាន់តែឮខ្លាច គ្រាន់តែឃើញរត់ ព្រោះការបាក់ស្បាតចំពោះឫទ្ធិអំណាចខ្លួន នោះជាកំពូលល្បិច ។ នាំពលទៅវាយប្រហារ នោះជាគំនិតអន់។



www.elibraryofcambodia.org

ហេតុនេះ ការប្រយុទ្ធដូចរន្ទះ ការឈ្នះមួយប៉ប្រិចភ្នែក ក៏ពុំទាន់ហៅថាជាយុទ្ធសាស្ត្រ ឬ វិធីសាស្ត្រឈ្លាសវាងវៃបំផុត ក្នុងចំណោមភាពឈ្លាសវៃនោះដែរ។ ក្បាច់គុនមិនបាច់ដាល់ ដូចជាការធ្វើសង្គ្រាមមិនចាំបាច់ប្រយុទ្ធ តែធ្វើយ៉ាងណាឲ្យខ្មាំងសត្រូវ បាក់បបខួបខ្លាច ទទួលចុះចាញ់ នោះទើបជាយុទ្ធវិធីឈ្លាសវៃបំផុត ក្នុងចំណោមភាពវាងវៃ ទាំងឡាយ។

ដូចនេះ កំពូលល្បិចក្នុងការដឹកនាំទ័ពប្រយុទ្ធ គឺប្រើកលយុទ្ធសង្គ្រាម ដើម្បីជាកត្តាយកឈ្នះទៅលើទ័ពខ្មាំង បន្ទាប់មកតាមរយៈមធ្យោបាយការទូតដើម្បីត្រៀម លក្ខណៈយកឈ្នះ ហើយបន្ទាប់ទៀតគឺប្រើប្រាស់កម្លាំង ប្រដាប់អាវុធដើម្បីយកឈ្នះទៅលើទ័ពខ្មាំង។ ការវាយលុកកំពែងក្រុង ជាជម្រើសចុងក្រោយ។ ការវាយលុកកំពែង ក្រុង ជាវិធីម៉្យាងដែលធ្វើឡើងដោយបង្ខំ។ ព្រោះការ ផលិត កែច្នៃរទេះសេះ រថសឹក គ្រឿងសព្វាវុធគ្រប់ បែបយ៉ាងត្រូវប្រើពេលយ៉ាងតិចបីខែ ទើបសម្រេចរួចរាល់ ការ



www.elibraryofcambodia.org

កសាងទំនប់ ភ្នំដីជាឈ្នាន់ សម្រាប់ការវាយលុក កំពែងក្រុងខ្មាំង ក៏ត្រូវអស់ពេលមិនតិចជាងបីខែដែរ ទើប អាចប្រើប្រាស់បាន។

ពួកនាយកង មេទ័ព ដែលតក់ក្រហល់ទល់ពុទ្ធោ ក្តៅក្រហាយក្នុងចិត្ត គិតច្រឡោតខឹង ទៅបញ្ជា កៀងពល ឲ្យវារឡើងជណ្តើរ ផ្ទឹបនឹងជញ្ជាំង កំពែងក្រុង ដូចហ្វូងស្រមោច ដើម្បីវាយលុក បុក ទំលុះក្រុងរបស់ខ្មាំង។ ប៉ុន្តែ ពេលនោះ កងទ័ព សេនា ពលវេហ៍ ស្លាប់ផង របួសផងអស់មួយភាគបី នៃចំនួនទ័ពទៅហើយ តែក្រុង នគរទ័ពខ្មាំងនៅពុំ ទាន់ត្រូវបានកំទេច ដណ្តើមយកបាន នោះហើយជា ភាពអន្តរាយ ជាក្តីវិនាសនៃការវាយលុកបុកទំលុះ កំពែងក្រុង។

អាស្រ័យហេតុនេះ អ្នកដែលជំនាញជាញជ័យ ក្នុងសឹកសង្គ្រាម គឺធ្វើយ៉ាងណាក្តោបក្តាប់ស្មារតីខ្មាំង ឲ្យចុះញ៉ម ដោយមិនចាំបាច់ពើបប្រយុទ្ធដោយផ្ទាល់ កំទេចនិង ដណ្តើមក្រុងរបស់ខ្មាំងបាន ដោយមិន បាច់ប្រើការវាយលុកបុកទំលុះ។ វាយប្រហារ កម្ទេច



www.elibraryofcambodia.org

ទឹកដីបុរីនគររបស់ខ្មាំងដោយ មិនប្រើពេលវេលាយូរអង្វែង ប្រការទាំងនោះ ដាច់ខាតត្រូវ ប្រើកលយុទ្ធឈ្នះៗទាំងស្រុង ដើម្បីត្រៀមយកឈ្នះអ្នកផង ក្រោមមេឃលើដីនេះ។

ធ្វើបានដូចនេះ ក្នុងជួរកងទ័ព ពលសេនា មិនមានការហត់នឿយ និងជួបការលំបាកខ្លាំង ក៏ប៉ុន្តែនៅតែទទួលបានជោគជ័យ យ៉ាងត្រចះត្រចង់ជាស្ថាពរ។ នោះហើយ ជាក្បួនវាយលុកដោយកលគំនិតយុទ្ធបញ្ញា។ ហេតុដូចនេះ តាមក្បួន **ពិជ័យសង្គ្រាម** ការដឹកនាំទ័ពប្រយុទ្ធ កាលបើ កម្លាំងយើងច្រើនលើសខ្មាំងដប់ដង ត្រូវធ្វើការហ៊ុមព័ទ្ធទ័ពខ្មាំង បើច្រើនលើសប្រាំដង ត្រូវធ្វើការវាយលុកទៅលើទ័ពខ្មាំង បើគ្រាន់តែលើសទ្វេដង គឺត្រូវរកវិធីបំបែកជួរកងទ័ពខ្មាំង តែបើស្មើគ្នា យើងត្រូវតែរកវិធីយកឈ្នះជាបន្ទាន់។ តែពេលដែលកម្លាំងទ័ពយើងតិចជាងទ័ពខ្មាំង គឺយើងត្រូវ រកវិធីគេចចេញ ឲ្យផុតពីមុខទ័ពខ្មាំង ។ កាលបើឃើញថា កម្លាំងពិតរបស់កងទ័ពយើងគ្រប់ចំណុចទន់ខ្សោយ ជាងទ័ពខ្មាំងនោះ



www.elibraryofcambodia.org

ត្រូវគេចឲ្យផុតពីការពើបប្រយុទ្ធជាដាច់ខាត។ ហេតុនេះសម្រាប់ជួរកងទ័ពមួយ ដែលតូចទន់ខ្សោយ ក៏ប៉ុន្តែនៅតែរឹងទទឹងក្រាញននៀល គិតតែប្រយុទ្ធតទល់នឹងទ័ពខ្លាំង ដែលខ្លាំងជាងខ្លួនហួសប្រមាណនោះទីបំផុត ប្រាកដជាក្លាយជាចំណីនៃភ្លើងសង្គ្រាម ឬយ៉ាងហោចណាស់ ក៏ត្រូវខ្មាំងចាប់ខ្លួន ជាឈ្លើយសឹកដែរ។

សេនាប្រមុខ មេទ័ពធំ នាយកង នាយក្រុមទាំងឡាយ ជាជំនួយការផ្ទាល់សម្រាប់ព្រះរាជា ឬថ្នាក់ដឹកនាំប្រទេស ជាសសរទ្រូងរបស់ជាតិ ប្រៀបបានកំពែងការពារដែនដីបុរីនគរដ៏រឹងមាំ។ ប្រសិនបើជំនួយការសសរទ្រូង ឬ កំពែងនោះរឹងមាំ គ្មានការខ្វះចន្លោះ ហើយល្អប្រសើរគ្រប់ជ្រុងជ្រោយទៀតនោះ តាមរយៈនោះ ប្រទេសជាតិក៏រឹងមាំ និងវឌ្ឍនភាពរុងរឿងដែរ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើអ្នកទាំងនោះ មានការថ្លោះធ្លោយ ខ្វះចន្លោះ អន់ខ្សោយ តាមរយៈនោះប្រទេសជាតិ ក៏ធ្លាក់ចុះ អន់ថយ ឆ្ពោះទៅកាន់ហីនភាព ក្តីវិនាសពុំខានឡើយ។ ប្រមុខរាជ



www.elibraryofcambodia.org

រដ្ឋាភិបាល ថ្នាក់ដឹកនាំជាតិ អាចក្លាយជារឿង គ្រោះថ្នាក់ ឧបស័គ្គ ជាវត្ថុរាំង ដល់សកម្មភាពកងទ័ពរបស់ខ្លួនដោយករណីបីយ៉ាង ៖

១- មិនយល់ដឹងអំពីស្ថានភាពរបស់កងទ័ព ដែលថាមិនអាចធ្វើការរុលទៅមុខបាន ប៉ុន្តែ បែរជាបង្ខំឲ្យរុលទៅមុខ។ មិនយល់ដឹងអំពីស្ថានភាពរបស់កងទ័ព ដែលថា មិនអាចធ្វើការដកថយបាន ប៉ុន្តែ បែរជាឲ្យទ័ពដកថយ។ កត្តានេះគេហៅថាជាការដាក់កំហិតជាចំណងចងរឹតកងទ័ព។

២-មិនដឹងមិនយល់ អំពីកិច្ចការផ្ទៃក្នុងរបស់កងទ័ព ក៏ប៉ុន្តែព្យាយាម ធ្វើការត្រួតត្រា ដោយលូកដៃចូលក្នុងកិច្ចការ រដ្ឋបាលរបស់កងទ័ព ធ្វើឲ្យនាយទាហាន ពលសេនា កើតក្ដីខ្វល់ខ្វាយ មិនយល់ហេតុការណ៍ មិនយល់ដឹងកលឧបាយ នៃសឹកសង្គ្រាម ក៏ប៉ុន្តែ ព្យាយាមត្រួតត្រា ក្នុងកិច្ចការបញ្ជាទ័ពនាសមរភូមិប្រយុទ្ធ ធ្វើឲ្យ មេទ័ព នាយទាហាន ពលសេនា ក្នុងជួរកងទ័ព កើតក្ដីខ្វល់ខ្វាយ មន្ទិលសៅហ្មង បាត់បង់ជំនឿចិត្ត ក្នុងការប្រយុទ្ធ។ ពេល



www.elibraryofcambodia.org

ដែលកងទ័ពកើតភាពខ្វល់ខ្វាយ មន្ទិលសៅហ្មង ផ្ទៃក្នុងវឹកវរ ពេលនោះហើយ បណ្តាសាមន្តប្រទេស និងប្រទេសជិតខាង នឹងឆ្លៀតឱកាសវាយលុក ធ្វើវិទ្ធង្សនា ប្រើកលឧបាយដោយវិទ្ធង្សនា បំផ្លិចបំផ្លាញ បង្កើតអំពើបះបោគ្រប់ទិសទី ជាគ្រោះអាសន្ន មហន្ត-រាយ ប្រៀបបាន ភ្នំបាក់ធ្លាក់មកសង្កត់ពីលើយ៉ាងនោះឯង។ នេះហើយដែល ហៅថាខ្លួនបង្កើតភាពស្មុកស្មាញឲ្យខ្លួន ជាហេតុនាំភាពជោគជ័យ ទៅឲ្យគូភាគីសត្រូវ ឯណោះវិញ។ បានមិនបាច់ខំ រលំមិនបាច់ច្រាន។ ដូចនេះ ទើបមានស្ថានភាពប្រាំយ៉ាង សម្រាប់ ប្រមាណភាពជោគជ័យទុកជាមុនគឺ :

ក- កាលបើអាចដឹងបានថា ក្នុងស្ថានភាពណាគួរប្រយុទ្ធ ក្នុងស្ថានភាពណាមិនគួរប្រយុទ្ធ នោះគេនឹងឈ្នះ។

ខ-កាលបើចេះយោងទៅលើចំនួនទ័ពតិចតួច ឬច្រើន ដើម្បីអនុវត្តក្បួនប្រយុទ្ធផ្សេងគ្នាឲ្យសមស្រប នោះគេនឹងឈ្នះ។



www.elibraryofcambodia.org

គ-កាលបើទាំងមន្ត្រី ទាំងទាហាន មានឆន្ទៈរួម មនសិការតែមួយ ពីថ្នាក់លើចុះដល់ក្រោម រួមកម្លាំងកាយចិត្តជាធ្លុងមួយ នោះគេនឹងឈ្នះ។

ឃ-កាលបើចេះយកភាពដែលបានរៀបចំត្រៀមលក្ខណៈទុកជាមុនបានល្អ ដើម្បីរង់ចាំតទល់ជាមួយភាពដែល មិនបានរៀបចំទុកជាមុននោះគេនឹងឈ្នះ។

ង-កាលបើនាយទាហ៊ាន មេទ័ពដែលជាអ្នកជំនាញជាញជ័យ មានសមត្ថភាពបញ្ជាទ័ពប្រយុទ្ធយ៉ាងចំណាន ហើយមិនមានការលូកដៃរំខានពីសំណាក់ប្រមុខរដ្ឋ ឬ អ្នកមានអំណាច ដែលមិនចេះក្បួនទ័ពមកដាក់កំហិត ខាឃាំងទេនោះ នោះគេនឹងឈ្នះ។

ស្ថានភាពទាំងប្រាំយ៉ាងនេះ ជាប្រមាណវិធី ដើម្បីគិតទុកជាមុន នូវភាពជោគជ័យក្នុងសឹកសង្គ្រាម។ ដូច្នេះ ទើបមានពាក្យថា បើស្គាល់ ច្បាស់អំពីខ្មាំង និងស្គាល់ច្បាស់អំពីខ្លួនយើង ច្បាំងទាំងមួយរយសមរភូមិ ឈ្នះទាំងមួយរយដង ពោលគឺស្គាល់គេស្គាល់យើង ឈ្នះ ឈ្នះ មិនចេះចាញ់ ។ ប៉ុន្តែប្រសិនបើមិនស្គាល់អំពីស្ថានភាពខ្មាំង ហើយគ្រាន់



www.elibraryofcambodia.org

តែស្គាល់អំពីខ្លួនឯង ឬស្គាល់អំពីខ្មាំង តែមិនស្គាល់អំពីខ្លួនឯង នោះជោគជ័យនិងបរាជ័យមួយខាងម្នាក់ ឬពាក់កណ្ដាលម្នាក់ ផ្ទុយទៅវិញ ប្រសិនបើមិនស្គាល់ខ្មាំង ហើយក៏មិនស្គាល់ ខ្លួនឯងទៀតនោះ ច្បាំងមួយរយដង ចាញ់មួយរយដង។



www.elibraryofcambodia.org

# ជំពូកទី៤
# ក្បួនយុទ្ធសាស្ត្រ

**ស៊ុន ជឺ** និយាយថា :

កាលពីសម័យដើម អ្នកដែលពូកែដឹកនាំទ័ព ធ្វើសឹកសង្គ្រាម ដំបូងបង្អស់ គឺត្រូវបង្កើតឲ្យបានកត្តានៃភាពជោគជ័យ ដោយមិនទុកឲ្យខ្មាំងសត្រូវ វាយប្រហារមកលើខ្លួនបាន ហើយរង់ចាំឱកាសយកឈ្នះលើខ្មាំងតែម៉្យាងគត់។ ដើម្បីមិនទុកឱកាស ឲ្យខ្មាំងយកជ័យជម្នះលើខ្លួនបាន ភាពម្ចាស់ការស្ថិតនៅលើយើង។ ការដែលអាចយកឈ្នះទៅលើខ្មាំងបាន គឺស្ថិតនៅត្រង់ភាពខ្វះចន្លោះ ថ្លោះធ្លោយរបស់ខ្មាំង ដែលយើងចេះឆ្លៀតឆក់យកឱកាសនោះ ក្តោបក្តាប់ស្ថានការណ៍ឲ្យ បាន។ ដូច្នេះ អ្នកជំនាញជាញជ័យក្នុងសឹកសង្គ្រាម គឺជាអ្នកដែលអាចមានលទ្ធភាពក្នុងការធ្វើសង្គ្រាម ការពារខ្លួន ឲ្យបានរួចផុតពីការវាយប្រហារយកឈ្នះរបស់ខ្មាំង សត្រូវមកលើខ្លួន។ ក៏ប៉ុន្តែ ពុំប្រាកដថាយើងអាចវាយប្រហារ យកឈ្នះ



www.elibraryofcambodia.org

ដាច់ខាតលើខ្មាំងបាននោះដែរ។ ហេតុដូច្នេះ ទើបមានពាក្យស្លោកថា ៖

"ជោគជ័យអាចប្រមាណដឹង
តែមិនអាចបង្ខំតាមចំណង់ចិត្តបានឡើយ"។

ពេលស្ថិតក្នុងស្ថានភាព មិនអាចយកឈ្នះលើទ័ពខ្មាំង គឺចាំបាច់ត្រូវធ្វើការការពារឲ្យបានរឹងមាំ។ ពេលអាចយក ឈ្នះលើទ័ពខ្មាំងបាន គឺចាំបាច់ត្រូវធ្វើការវាយលុកជាបន្ទាន់។ ការពារព្រោះពុំទាន់មានគ្រប់លក្ខណៈដើម្បីឈ្នះ។ ធ្វើការវាយលុក គឺព្រោះកត្តាឈ្នះមានគ្រប់គ្រាន់ពេញលេញ។ មេទ័ព ដែលជំនាញខាងការពារ ជាអ្នកចេះក្លែងភេទ លាក់ខ្លួនបំបាំងកាយ ឲ្យកម្លាំងទ័ពខ្លួនស្ថិតក្នុងអាថ៌កំបាំង នៃសណ្ឋានដី គ្រប់ប្រភេទ នៅលើទីតាំងភូមិសាស្ត្រនាសមរភូមិប្រយុទ្ធ។ ប្រៀបបានដូចគេបង្កប់ខ្លួននៅក្រោមដីប្រាំបួនជាន់យ៉ាងនោះដែរ រីឯអ្នកពូកែខាងវាយលុក គឺចេះពង្រីកកម្លាំងទ័ពប្រយុទ្ធរបស់ខ្លួនតាមគ្រប់រូបភាពដល់កម្រិតខ្ពស់ជាអតិបរមា ហើយចេះធ្វើសកម្មភាព យ៉ាងសមស្របតាមគ្រប់ស្ថាន



www.elibraryofcambodia.org

ភាពនៃអាកាសធាតុធម្មជាតិ ដោយចលនាមួយ ប្រៀបដូចគេបោះពួយ ពីលើទីតាំងខ្ពស់ ទម្លាក់ចុះ មកទីតាំងទាប ឬប្រៀបដូចល្បាក់ទឹក ដែលហូរធ្លាក់ ពីលើកំពូលភ្នំដ៏សែនខ្ពស់ បុកទម្លាក់ មកជ្រោះជ្រៅ យ៉ាងនោះឯង។ ត្រង់នេះហើយដែលហៅថាសមត្ថភាព ព្រមទាំងការពារផង ទាំងដណ្តើមយកឈ្នះ ទាំងស្រុង ផង។ ការប្រមាណក្នុងភាពជោគជ័យ កាលបើគ្មាន ភាពលើសលប់ ហួសពីគំនិតយល់ដឹងនៃមនុស្ស ភាគច្រើនទេ នោះការប្រមាណនោះ ពុំមែនជា គតិបណ្ឌិតខ្ពង់ខ្ពស់ ក្នុងចំណោមគតិបណ្ឌិតខ្ពង់ខ្ពស់ ទាំងឡាយឡើយ។ ឆ្លងកាត់បទពិសោធច្បាំងគ្នាក្នុង សមរភូមិមួយ ដែលត្រៀមយកឈ្នះបាន ហើយ អ្នកផងតែងកោតសរសើរថាពូកែ តែក៏ពុំទាន់អាច ចាត់ទុកថាជាអ្នកខ្លាំងពូកែ ក្នុងចំណោមអ្នកខ្លាំង ពូកែនោះដែរ។ ប្រៀបដូចគេចាប់យកស្លាបសត្វបក្សី មួយយ៉ាងស្រាលឡើងពីដី គឺមិនអាចចាត់ ទុកថា ជាអ្នកមានកម្លាំងខ្លាំងនោះឡើយ។ ការដែលអាច មើលឃើញព្រះអាទិត្យ ព្រះច័ន្ទ ក៏ពុំមែនមាន ន័យ



www.elibraryofcambodia.org

ថាភ្នែកភ្លឺនោះទេ ហើយការដែល អាចស្ដាប់ឮសំឡេង ផ្គររន្ទះកក្រើកមេឃនោះ ក៏ពុំមែនមានន័យថា ត្រចៀករវៀសវៃនោះដែរ។

ពីបុរាណនាយ កាលបើមានឈ្មោះថាជាអ្នកពូកែ ច្បាំងក្នុងសឹកសង្គ្រាម ដរាបណាក៏គេតែងចេះត្រៀមយកឈ្នះទៅលើខ្មាំង ដែលងាយឈ្នះ។ ដូច្នោះភាពជោគជ័យសម្រាប់អ្នក ដែលមានឈ្មោះថា ជំនាញជាញជ័យ ដែលអាចទទួលយកបាន កាលបើគ្មានពាក្យថាជាកលយុទ្ធ ប្រកបដោយគតិបណ្ឌិតទេនោះក៏គ្មានដែរពាក្យថាយុទ្ធជ័យ ឬវិរៈជនដ៏ហានក្លាត្រចះត្រចង់នោះឡើយ។ ហេតុនេះ ភាពជោគជ័យនោះគឺមិនមានអ្វី ត្រូវសង្ស័យនោះឡើយ។ ហេតុដែលថាមិនត្រូវមានការ សង្ស័យ ក៏ព្រោះតែភាពជោគជ័យរបស់គេ ត្រូវបានសាង ឡើងលើមូលដ្ឋានគ្រឹះនៃភាពឈ្នះប្រាកដ រីឯខ្មាំងដែលគេ យកឈ្នះបាននោះជាប្រភេទខ្មាំង ដែលបានធ្លាក់ចូលក្នុង ភាពបរាជ័យរួចទៅហើយ។ ដូចនេះ អ្នកជំនាញជាញជ័យ ក្នុងសឹកសង្គ្រាម ជានិច្ចកាលតែងធ្វើឲ្យខ្លួនគេ ឈរនៅ



www.elibraryofcambodia.org

លើមូលដ្ឋានដែលមិនអាចបរាជ័យ ហើយទន្ទឹមនោះក៏គេមិនទុកឲ្យឱកាសណាមួយ ដែលអាចយកឈ្នះលើខ្មាំងសត្រូវ ត្រូវរំលងផុតនោះដែរ។ ហេតុនេះកងទ័ពដែលច្បាំងឈ្នះក្នុងសមរភូមិ តែងមានការច្នៃប្រឌិតគ្រប់ពេល នូវរាល់កត្តាឈ្នះទុកមុនជាស្រេចរួចបន្ទាប់មកទើបគេពើបប្រយុទ្ធ ជាមួយខ្មាំងជាក្រោយ។ ចំណែកកងទ័ព ដែលចាញ់សឹកសង្គ្រាមវិញ តែងធ្វើការប្រយុទ្ធមុនជាមួយខ្មាំង រួចហើយទើបគិតពីលក្ខណៈយកឈ្នះជាក្រោយ ដោយស្ថិតក្នុងភាពផ្សងព្រេងជានិច្ច។ អ្នកពូកែកាន់ទ័ពចេញច្បាំង គេអាច ចាប់ផ្ដើមពីចំណុច ដែលគិតមើលទៅដូចជាមិនអាចប្រយុទ្ធ យកឈ្នះបាន តែគេចេះកែកុនស្ថានភាព ដើម្បីឲ្យធានាបាន នូវភាពជោគជ័យជាប្រាកដ ហើយក្ដាប់យកភាពម្ចាស់ការ ក្នុងការកំណត់លើភាពឈ្នះចាញ់ នៃសឹកសង្គ្រាម។ ក្បួនដឹកនាំទ័ពប្រយុទ្ធ មានកិច្ចសំខាន់ប្រាំយ៉ាង ៖ មួយគឺ *ប្រមាណ* ពីរគឺ *ទំហំ(ទ្រង់ទ្រាយ)* បីគឺ *ចំនួន* បួនគឺ *ប្រៀបធៀប* និង ប្រាំគឺ *ឈ្នះ*។ កិច្ចសំខាន់ទាំងប្រាំ



www.elibraryofcambodia.org

យ៉ាងខាងលើ ប្រៀបដូចជាបដិច្ចសមុប្បាទធម៌ម៉្យាង ដែលមានទំនាក់ទំនង ជាហេតុបច្ច័យនឹងគ្នា។ ភូមិសាស្ត្រ និងស្ថានភាពបង្កើតភាពប៉ាន់ប្រមាណ ការប៉ាន់ប្រមាណ ចំពោះភូមិសាស្ត្រ នឹងអាចដឹងបានពីទំហំនៃសមរភូមិ គិតគូរចំនួន នៃកម្លាំងទ័ពដែលចាំបាច់ត្រូវបញ្ជូនចូលក្នុងសមរភូមិ ផ្អែកលើការប្រៀបធៀបកម្លាំងទ័ពរបស់គូភាគី នឹងប៉ាន់ប្រមាណ ភាពខ្លាំងខ្សោយ នៃកម្លាំងយោធាពិតទាំងសងខាងរួចហើយ គេនឹងប៉ាន់ប្រមាណបាន អំពីភាពឈ្នះចាញ់ក្នុងឆាកប្រយុទ្ធ។

ដូច្នេះ កងទ័ពដែលទទួលបានជោគជ័យ ក្នុងការប្រៀបធៀបរវាងកម្លាំងទ័ពទាំងសងខាង ប្រៀបដូចគេយក វត្ថុទម្ងន់មួយតោន ទៅថ្លឹងប្រៀបនឹងវត្ថុទម្ងន់មួយគីឡូយ៉ាងនោះឯង គឺដណ្តើមបានអត្តភាពដាច់ខាត ចំណែកកងទ័ពដែលបរាជ័យ ឈរលើគោលការណ៍ប្រៀបធៀបកម្លាំងទ័ព បីដូច គេយកវត្ថុមួយ ទម្ងន់ត្រឹមតែមួយគីឡូ ទៅថ្លឹងប្រៀបធៀបជាមួយនឹងវត្ថុមួយ ដែលមានទម្ងន់មួយតោនយ៉ាង



www.elibraryofcambodia.org

នេះឯង ពោលគឺស្ថិតនៅក្នុងភាពជាអ្នកចាញ់ប្រៀបជាដាច់ខាត។

ចំពោះកងទ័ពដែលមានកម្លាំងធំធេង ខ្លាំងក្លា ហើយទទួលបានជោគជ័យ គឺការបញ្ជាទ័ពប្រយុទ្ធប្រៀបដូចទឹកបាក់ទំនប់ ហូរខ្ទប់ពីលើទីខ្ពស់ ៨០០ ព្យាម ធ្លាក់ចុះមកជ្រោះជ្រៅ ដែលគ្មាននរណាអាចនឹងរាំងបាន។ ទាំងនេះ គឺជាការសម្តែងឫទ្ធិ នៃឥទ្ធិពលកម្លាំងថាមពលរបស់កងទ័ព ដែលច្បាំងឈ្នះក្នុងសឹកសង្គ្រាម។



www.elibraryofcambodia.org

# ជំពូកទី៥
# ប្រៀប និង ស្មៀត

**ស៊ុនជឺ** និយាយថា៖

កាលបើចង់គ្រប់គ្រងជួរទ័ពមួយ ដែលមានកងកម្លាំងច្រើន ឲ្យបានល្អ ដូចជាការគ្រប់គ្រងជួរទ័ពមួយ ដែលមានកងកម្លាំងតិចនោះ បញ្ហាគឺស្ថិតនៅត្រង់ក្រុមខ័ណ្ឌ និងការចាត់តាំង។ បើចង់បញ្ជាជួរទ័ពមួយ ដែលមានកងកម្លាំងច្រើនឲ្យបានល្អ ដូចជាការបញ្ជាជួរទ័ពមួយ ដែលមានកម្លាំងតិចនោះ បញ្ហាគឺស្ថិតលើព័ត៌មាន និងបទបញ្ជា។ សម្រាប់កម្លាំងទ័ពជាតិក្នុងទូទាំងប្រទេសដ៏ច្រើនលើសលប់ ប្រសិនបើស្ថានភាពអាក្រក់ណាមួយកើតឡើង ពោលគឺត្រូវខ្មាំងវាយលុកដោយចៃដន្យ ប៉ុន្តែ មិនចង់ទទួលនូវភាពបរាជ័យ បញ្ហាគឺ ស្ថិតត្រង់ការចេះប្រែប្រួលបត់បែនយុទ្ធចម្បាំងតាមយុទ្ធសាស្ត្រ យុទ្ធវិធីទ័ពធ្មក់ទ័ពស្រួច ការប្រយុទ្ធទល់មុខ ឬប្រយុទ្ធមិនទល់



www.elibraryofcambodia.org

មុខ។ សម្រាប់កងទ័ពមួយ ធ្វើការវាយលុក ទៅលើ ទ័ពខ្មាំង បើចង់មានប្រៀប ដូចយកថ្មគប់ពងមាន់ ទៅដល់ទីណាឈ្នះដាច់ដល់ទីនោះ បញ្ញាស្ថិតនៅ ត្រង់ការ ចេះអនុវត្តយ៉ាងហ្មត់ចត់និងជាក់ច្បាស់ នូវ ការចេះ គេចចេញពីភាពបំភាន់ តែក្តោបក្តាប់ភាព ពិត ។ ធម្មតា គោលការណ៍ទូទៅពេលប្រយុទ្ធ គេ តែងប្រើប្រាស់ទ័ពស្រួច ដើម្បីទប់ស្កាត់ទ័ពខ្មាំង ហើយ យកទ័ពធំរៀបរយ ដើម្បីវាយសង្គ្រប់ ដណ្តើមជ័យ ជម្នះទៅលើខ្មាំង។ ហេតុនេះ មេទ័ពដែលខ្លាំងពូកែ ស្ទាត់ជំនាញកិច្ចការសឹកសង្គ្រាម ឲ្យតែច្បាំងដឹងថា ឈ្នះ នោះយុទ្ធសាស្ត្រចម្បាំងរបស់គេ គឺប្រៀបដូច មេឃដី ប្រែប្រួលឥតទីបញ្ចប់ ប្រៀបដូចជាទន្លេដ៏ធំ ទឹកហូរខ្លួលខ្មាញ់ចាក់ទៅមហាសមុទ្រ មិនចេះរីង ស្ងួត។ ចូលមករួចហើយពេលចេញទៅវិញ ប្រៀប ដូចព្រះអាទិត្យ និងព្រះចន្ទ្រ គោចរវិលជុំប្តូរវេនគ្នា។ ទៅហើយមកវិញ ប្រៀបដូចរដូវកាលទាំងបួន ផ្លាស់ វេនគ្នា តាមក្រឹត្យក្រមធម្មជាតិ។ តន្ត្រី ដែលមាន អក្សរភ្លេង ត្រឹមតែប្រាំចង្វាក់ប៉ុណ្ណោះ ប៉ុន្តែ ភាពប្រែ



www.elibraryofcambodia.org

ប្រួល នៃចង្វាក់ទាំងប្រាំនោះ បង្កើតទៅជាបទភ្លេងដ៏សម្បូរបែប ស្តាប់គ្មានទីបញ្ចប់។ រីពណ៌ធម្មជាតិដែលមានពណ៌ដើមតែប្រាំប៉ុណ្ណោះ ប៉ុន្តែពេល លាយពណ៌ទាំងប្រាំនោះចូលគ្នា ធ្វើឲ្យប្រែប្រួល ទៅជាពណ៌ចម្រុះធម្មជាតិយ៉ាងសម្បូរបែប គួរឲ្យគយគន់គ្មានទីបញ្ចប់។ រីឯរសជាតិវិញ ក៏មានត្រឹមតែប្រាំរសជាតិដើមប៉ុណ្ណោះដែរ។ ប៉ុន្តែការប្រែប្រួលនៃរសជាតិទាំងប្រាំនោះ បានផ្តល់ឱជារស ផ្សេងៗគ្នា ធ្វើឲ្យការខ្លែម-ក្រេប-ភ្លក្សរសជាតិទាំងនោះ មិនអស់មិនហើយ។ ភាពផ្ទាល់ និងភាពប្រយោល ទំនាក់ទំនង ឆ្លើយតប និងប្រែប្រួល ប្រៀបដូចជាការវិលជុំនៅលើរង្វង់នៃមាត់ពែង គ្មានទីណា ដែលជាចំណុចចាប់ផ្តើម ហើយក៏គ្មានដែរចំណុចនៃទីបញ្ចប់។ តើមានអ្នកណាមួយដែលអាចទៅដល់ទីបញ្ចប់ នៃភាពប្រែប្រួលនោះបានទេ ខ្សែទឹកហូរចាក់យ៉ាងខ្លាំង កម្លាំងហូរលឿនដូចហោះ នឹងអាចរុញច្រានដុំថ្មទៅបាន តាមចរន្តរបស់វា ដូចពាក្យថា ទឹកហូរសឹកថ្ម កត្តានោះគឺអាស្រ័យលើល្បាក់ទឹកដ៏លើសលប់។ សត្វស្ទាំងដ៏



www.elibraryofcambodia.org

សាហាវ ប្រើល្បឿនហោះយ៉ាងលឿន ដើម្បីវាយប្រហារ ទៅលើគោលដៅ ទើបអាចចាប់បានសត្វម្រឹគ បក្សីជាចំណី កត្តានោះ គឺអាស្រ័យដោយវាចេះប្រើចង្វាក់ល្បឿនយ៉ាងសមស្រប។ ដូចនេះ អ្នកដែលពូកែបញ្ជាទ័ពប្រយុទ្ធ អ្វីដែលហៅថាប្រៀប ឬ ស្មៀតដែលគេបង្កើត គឺភាពឧបស័គ្គ និងចង្វាក់ដែលគេក្តោបក្តាប់តែក្នុងខណៈពេលដ៏ខ្លីបំផុត ពោលគឺគ្រាន់តែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ។ ប្រៀបឬស្មៀតទាំងនោះប្រៀបបានស្នា ដែលបានយឹតតំឡើងយ៉ាងតឹងអស់ទំហឹង រីឯចង្វាក់នោះ ប្រៀបបានគន្លឹះកៃរបស់ស្នានោះ ដែលគ្រាន់តែកេះ គឺបាញ់ចេញភ្លែតតែម្តង។ លឿនដូចព្រួញ។ ការប្រយុទ្ធស្ថិតក្នុងស្ថានភាពវក់វីច្របូកច្របល់ តែចាំបាច់ត្រូវរក្សាជួរទ័ពរបស់យើងកុំឲ្យមានភាពច្របូកច្របល់ឲ្យសោះ។ ប្រយុទ្ធគ្នាក្នុងស្ថានភាពច្របូក ច្របល់ មិនច្បាស់លាស់ តែចាំបាច់ត្រូវរៀបចំកងទ័ពយើង ឲ្យមានលទ្ធភាពអាចទប់ទល់បានដោយសេរី ទាំងបួនមុម ប្រាំបីទិស ធ្វើឲ្យទ័ពខ្មាំងមិនអាចវាយប្រហារ យកឈ្នះមកលើ



www.elibraryofcambodia.org

ទ័ពយើងបាន។ ត្រូវចេះបញ្ឆោតខ្មាំងឲ្យឃើញថា យើងច្របូក ច្របល់ តែមុនពេលប្រយុទ្ធ ចាំបាច់ត្រូវមានគុណភាពនៃភាពហានក្លា។ បញ្ឆាក់ឲ្យខ្មាំងឃើញថាយើងទន់ខ្សោយ តែមុនពេលប្រយុទ្ធ ចំបាច់ត្រូវមានកម្លាំងខ្លាំងក្លារឹងមាំ ។ បង្ក្រាប ចលាចល គឺជាបញ្ហាចាត់តាំងរបស់បញ្ជាការ ហ៊ាន ឬ ខ្លាច ជាបញ្ហាល្អ ឬអាក្រក់របស់ប្រៀបនិងស្ទៀត។ ខ្លាំង ឬ ខ្សោយ គឺ បញ្ហាសំញែងកម្លាំងយោធា។ ដូចនេះ មេទ័ពដែលពូកែខាង បញ្ឆោតទ័ពខ្មាំង ឲ្យលុះក្នុងបំណងរបស់ខ្លួន គឺចេះបំភាន់ ក្លែងភេទ បង្កើតរូបភាពក្លែងក្លាយ ដើម្បីបំភាន់ខ្មាំង ឲ្យវាធ្វើសកម្មភាពតាមគំនិតរបស់ខ្លួន ឲ្យខ្មាំងឃើញប្រយោជន៍ វាពិតជាត្រូវបោកបញ្ឆោត។ យកប្រយោជន៍តូច ធ្វើជានុយដើម្បីបញ្ឆោតទ័ពខ្មាំង ហើយប្រើកម្លាំងទ័ពពូនស្ទាក់រង់ចាំឱកាសវាយប្រហារសង្គ្រប់យកឈ្នះ ។ ដូច្នេះអ្នកជំនាញជាញជ័យចាំបាច់ត្រូវបញ្ចូលស្នៀត "ប្រៀប" ដែលជាភាពអំណោយផល ដើម្បីត្រៀមឈ្នះ ដោយមិនទាមទារហួសហេតុពេក លើសពីសមត្ថភាពរបស់



www.elibraryofcambodia.org

នាយទាហាន។ អាស្រ័យហេតុនេះ ទើបគេអាចជ្រើសរើសបានជនឆ្នើមពិតប្រាកដ និងឆ្លៀតឆក់បានឱកាសជាអំណោយផល។ អ្នកដែលពូកែខាង "ស្ទៀត" ល្បិច ពេលបញ្ជាទ័ពប្រយុទ្ធ ប្រៀបបានចលនានៃការផ្លាស់ប្តូរកំណាត់ឈើ និងដុំថ្មអ៊ីចឹងឯង។ លក្ខណៈធម្មជាតិនៃឈើនិងថ្មពេលដាក់នៅទីរាបស្មើ គឺងាយនៅនឹងថេរមួយកន្លែង តែបើដាក់នៅទីចោតគឺវានឹងរមៀលទៅយ៉ាងងាយ។ ដូចនេះអ្នកពូកែបញ្ជាទ័ពប្រយុទ្ធ តែងចេះបង្កើត "ស្ទៀត" ដែលមាន "ប្រៀប" ជាអំណោយផល ប្រៀបបានដូចជាការដាក់ដុំថ្មមូលពីលើកំពូលភ្នំខ្ពស់ កម្ពស់៨០០ព្យាម ឲ្យរមៀលចុះយ៉ាងនោះឯង។ នោះហើយ គឺស្ទៀតល្បិចក្នុងសមរភូមិប្រយុទ្ធ។



www.elibraryofcambodia.org

# ជំពូកទី៦
## ពិត និង មិនពិត
(ការពិត និង មាយាការ)

**ស៊ុនជឺ** និយាយថា៖

ធម្មតា ការបានទៅដល់ទីលានប្រយុទ្ធមុន ហើយរង់ចាំទ័ពខ្មាំងនោះ គឺជាឱកាសបានសម្រាកលម្ហែលម្ហើយ និងមានម្ចាស់ការ រីឯការទៅដល់ក្រោយ ត្រូវប្រញាប់ប្រញាល់ ទប់ទល់នឹងការប្រយុទ្ធ ទាំងនៅនឿយហត់ ទាំងមិនបានត្រៀមលក្ខណៈ វានឹងបាត់បង់ម្ចាស់ការ។ ហេតុនេះ អ្នកពូកែ បញ្ជាទ័ពប្រយុទ្ធគេអាចបញ្ជាបានទ័ពខ្មាំង ដោយមិនឲ្យខ្មាំងបញ្ជាគេបាន ។ អាចធ្វើឲ្យខ្មាំងមកចូលអន្ទាក់ដោយខ្លួនឯងក៏ព្រោះតែគេចេះប្រើប្រាស់នូវផលប្រយោជន៍ ដើម្បីបញ្ឆោតខ្មាំង។ ការធ្វើឲ្យទ័ពខ្មាំងពុំអាចទៅដល់តំបន់ដែលវាបានគ្រោងទុក គឺព្រោះតែគេចេះបង្កើតនូវភាពលំបាក ភាពជាឧបសគ្គ ដើម្បីរាំងស្កាត់ទ័ព



www.elibraryofcambodia.org

ខ្មាំង។ ដូចនេះ ពេលដែលខ្មាំងមានការឈប់សម្រាក ល្អ ដាច់ខាតត្រូវរកវិធីធ្វើឲ្យវានឿយហត់ ទ័ពខ្មាំង ដែលមានការផ្គត់ផ្គង់ស្បៀងគ្រប់គ្រាន់ ចាំបាច់ត្រូវ រកវិធី ធ្វើឲ្យវាខ្វះខាតអត់ឃ្លាន ទ័ពខ្មាំងសម្ងំស្ងៀម មិនធ្វើសកម្មភាព ដាច់ខាតត្រូវរកវិធីបញ្ឆោវា។ ពេល ចេញទ័ពប្រយុទ្ធត្រូវតម្រង់ឆ្ពោះទីតាំងខ្មាំង កន្លែង ដែលវាមិនអាចជួយសង្គ្រោះគ្នាបាន។ ពេលរុលទៅ មុខត្រូវរុលយ៉ាងលឿន សំដៅទីតាំងទ័ពខ្មាំង ធ្វើឲ្យ វាស្មានមិនដល់ ពុំអាចគិតទុកជាមុន។ ធ្វើប្រតិបត្តិ ការសឹក រាប់ពាន់យោជន៍ ដោយមិនជួបឧបសគ្គ គឺ ព្រោះតែធ្វើដំណើរ ទៅតំបន់ដែលគ្មានទ័ពខ្មាំង។ ការវាយលុកដែលប្រាកបដោយជោគជ័យ គឺដោយ សារ វាយចំទីតាំង ដែលខ្មាំងគ្មានធ្វើការការពារ ឬ ការពារមិនរឹងមាំ។ ការការពារដែលដាច់ខាតត្រូវតែ រឹងមាំ គឺដោយសារការការពារទីតាំង ដែលខ្មាំងមិន អាចវាយលុកបាន ឬវាយលុកដោយលំបាក។ ដូច្នេះ អ្នកពូកែខាងវាយលុក គឺធ្វើឲ្យខ្មាំងមិនដឹងថាត្រូវ ការពារដូចម្ដេច! អ្នកពូកែខាងការពារ គឺធ្វើឲ្យទ័ពខ្មាំង



www.elibraryofcambodia.org

មិនដឹងថាត្រូវវាយលុកដោយវិធីណា!។ ជាភាពអស្ចារ្យពេកក្រៃ គឺអស្ចារ្យដល់ថ្នាក់ដែលពុំអាចមើល ឃើញរូបភាព ស្លាក ស្នាម។ វិសេសវិសាល ដល់ថ្នាក់ដែលពុំអាច ស្ដាប់ឮសំឡេងអ្វីសោះ។ ធ្វើបានដូច្នេះទើបអាចហៅថាជាអធិរាជលើខ្មាំងសត្រូវ។ ធ្វើការវាយលុក ដែលទ័ពខ្មាំងមិនអាច ទប់ទល់បាន គឺដោយសារវាយលុកចំកន្លែងដែលទ័ពខ្មាំង ការពារទន់ខ្សោយ។ ការធ្វើការដកថយ ដែលទ័ពខ្មាំងមិនអាចតាមវាយប្រហារបាន គឺដោយ សារ សកម្មភាពរហ័សរហួន ធ្វើឲ្យទ័ពខ្មាំងពុំអាចតាមទាន់។ ហេតុនេះ ពេលដែលទ័ពយើង ចង់ធ្វើការវាយប្រហារទោះជាទ័ពខ្មាំងមានការខិតខំការពារ ដោយកំពែងខ្ពស់ ឬស្ថិតក្នុងលេណដ្ឋានយ៉ាងជ្រៅ ក៏បង្ខំចិត្ត ត្រូវចាកចេញពីទីតាំង ដើម្បីពើបប្រយុទ្ធជាមួយយើងដែរ គឺ ព្រោះតែយើង បានវាយលុកចំទីតាំងរបស់ខ្មាំងដែលត្រៀមទុកសម្រាប់សង្គ្រោះ។ ពេលទ័ពយើងមិនចង់វាយលុក ទោះជាការគុសវាសក្រោមដី ដើម្បីការពារក៏ដោយ ក៏ទ័ពខ្មាំងពុំ អាចមានវិធីពើប



www.elibraryofcambodia.org

ប្រយុទ្ធជាមួយយើងបានដែរ គឺព្រោះតែយើងបាន រកវិធីធ្វើឲ្យទ័ពខ្មាំងត្រូវផ្លាស់ប្តូរទិសដៅវាយលុក។ ដូច្នេះ ប្រើវិធីធ្វើឲ្យខ្មាំង មើលឃើញរូបភាពក្លែងក្លាយ ដើម្បីបោកបញ្ឆោតវា ធ្វើឲ្យវាសម្តែង និងបង្ហាញនូវគោលគំនិតរបស់វាចេញមកក្រៅឲ្យបានច្បាស់។ រីឯទ័ពយើងវិញ គឺមិនបង្ហាញរូបភាពច្បាស់លាស់ណាមួយឡើយ ធ្វើឲ្យខ្មាំងវាវរកទីតំបន់អ្វីពុំឃើញបានពេលនោះហើយ ដែលអាចអនុវត្តបានគោលការណ៍ប្រមូលផ្តុំកងកម្លាំងរបស់យើង ដើម្បីឲ្យកងកម្លាំងរបស់ខ្មាំង ត្រូវបែងចែកជាចំណែកៗ។ កងកម្លាំងទ័ពយើងប្រមូល នៅទីតាំងមួយ ឯទ័ពខ្មាំងត្រូវបែងចែកទៅដប់ទីតាំង នោះហើយដែលយើងអាចប្រើកម្លាំងទ័ពមានចំនួនតិចនៅពេលធម្មតា តែច្រើនជាងដប់ដង នៅពេលវាយប្រហារខ្មាំង។ ដូចនេះ គឺយើងបង្កើតបានប្រៀប ៖ ទ័ពយើងច្រើន ទ័ពខ្មាំងតិច។ ហើយអាចប្រមូលផ្តុំកម្លាំងទ័ពដែលមានប្រៀប ដើម្បីវាយប្រហារទៅលើទ័ពដែលគ្មានប្រៀប ឬបាត់បង់ប្រៀប។ ហេតុនេះហើយ ទ័ព



www.elibraryofcambodia.org

ខ្មាំងដែលពើបប្រយុទ្ធនឹងទ័ពយើង ដោយកម្លាំងវាមានកម្រិត។ ចំណុចទីតាំង ដែលទ័ពយើងចង់ធ្វើការវាយលុក ហើយទ័ពខ្មាំងពុំអាចដឹងបាន ការដែលមិនអាចយល់ដឹងបាននោះ គឺខ្មាំងត្រូវធ្វើការការពារទាំងគ្រប់ទីកន្លែង ទីតាំងការពារ របស់ទ័ពខ្មាំងកាន់តែច្រើន ចំនួនទ័ពដែលប្រឈមមុខប្រយុទ្ធ នឹងទ័ពយើង កាន់តែមានកម្រិតតិច។ ដូចនេះ កាលបើផ្តោតអារម្មណ៍ការពារចំណុចខាងមុខ កម្លាំងទ័ពខាងក្រោយរមែង នឹងចុះខ្សោយ។ ផ្តោតអារម្មណ៍ការពារស្លាបស្តាំ កម្លាំងទ័ព ផ្នែកស្លាបឆ្វេងនឹងចុះខ្សោយ ការពារទាំងគ្រប់ទីតាំង គឺកម្លាំងទ័ពគ្រប់ទាំងទីតាំងនឹងត្រូវចុះខ្សោយ។ ដោយសារកម្លាំងទ័ពខ្មាំងចុះខ្សោយពីព្រោះតែគេការពារទាំងគ្រប់ទីតាំង។ ចំណែកកម្លាំងទ័ពយើង ដោយសារមានច្រើនពីព្រោះតែយើង បង្ខំឲ្យទ័ពខ្មាំង ត្រូវបែងចែកកម្លាំងធ្វើការការពារពីការវាយ លុករបស់ទ័ពយើង។ ដូច្នេះ ការដែលអាចដឹងមុនថានឹងត្រូវ វាយប្រហារតំបន់ណា ត្រូវប្រយុទ្ធនៅពេលណានោះ ទោះជាធ្វើដំណើរទ័ពរាប់ពាន់យោជន៍



www.elibraryofcambodia.org

ក៏អាចពើបប្រយុទ្ធនឹងខ្មាំងបានដែរ។ ការដែលមិនអាចប្រមាណដឹងមុន ថានៅទីណា និងនៅពេលណា ដែលត្រូវធ្វើការប្រយុទ្ធ នោះយើងនឹង ត្រូវធ្លាក់ក្នុងសភាពទ័ពស្លាបឆ្វេងមិនអាចជួយស្លាបស្តាំ ទ័ពមុខ មិនអាចជួយទ័ពក្រោយ ក្រោយមិនអាចជួយមុខ ទម្រាំបើនៅឆ្ងាយពីគ្នារាប់សិបយោជន៍ ឬយ៉ាងជិតក៏រាប់យោជន៍នោះ តើនឹងទៅជាយ៉ាងណា?។

អាស្រ័យហេតុនេះ ទើបពោលថា : ជោគជ័យគឺអាស្រ័យលើការឆក់ឱកាស។ ទ័ពខ្មាំងថ្វីត្បិតមានចំនួនច្រើន ប៉ុន្តែ ត្រូវធ្វើដូចម្តេចកុំឲ្យវាយកកម្លាំងទាំងអស់នោះមកប្រយុទ្ធជាមួយយើងបាន។

ដូច្នេះ ចាំបាច់ត្រូវធ្វើការវិភាគ ប៉ាន់ប្រមាណឲ្យបានហ្មត់ចត់ ដើម្បីឈ្វេងយល់ឲ្យបានច្បាស់លាស់ពីផលប្រយោជន៍ និងភាពអន្តរាយ ពីការបាននិងការបាត់បង់។ វាយស្ទង់ស្ទាប ទៅលើទ័ពខ្មាំង ដើម្បីស្វែងរកឲ្យខានតែបានលំអាន នៃភាពកំរើក និងស្ងប់របស់ទ័ពខ្មាំង បង្ហាញរូបភាពក្លែងក្លាយ ដើម្បីបញ្ឆោតខ្មាំង ដើម្បីឈ្វេងយល់ភូមិសាស្រ្ត ដែលទ័ព



www.elibraryofcambodia.org

ខ្មាំងកំពុងកាន់កាប់ វាមានអំណោយផល ឬមិនអំណោយផល ចាប់ផ្ដើមប្រយុទ្ធ ដោយវិធីចារកម្មស៊ើបការ ដើម្បីឈ្វេងយល់ការចាត់ចែងកម្លាំងទ័ពរបស់ខ្មាំង ភាពបំភ័ន្តនិងពិតខ្លាំងខ្សោយយ៉ាងណា។ ហេតុនេះ វិធីដែលបង្ហាញរូបភាព ដើម្បីបញ្ឆោតខ្មាំងកាលបើអនុវត្តដល់កម្រិតលំអិតសុខុម គឺពុំអាចមើលឃើញស្លាកស្នាម ពិតយ៉ាងណានោះឡើយ ។ ការពុំអាចមើលឃើញ ស្លាកស្នាមនេះហើយ ទោះបើជាចារបុរសនៅពាសពេញ ក៏ពុំអាចឈ្វេងយល់យ៉ាងលំអិតបានដែរ ហើយទោះបីមានអ្នកភ្លឺស្វាងឈ្លាសវៃដល់កម្រិតណា ក៏ពុំអាចគិតឃើញវិធីទប់ទល់បានដែរ។ សម្របតាមស្ថានភាពខ្មាំង ដើម្បីត្រៀមលក្ខណៈ ឈ្នះក្នុងសឹកសង្គ្រាម ទោះជាដាក់ភាពជោគជ័យនៅចំពោះមុខ អ្នកផងទាំងពួងក៏ពួកគេនៅតែស្ងាក់ស្ទើ មិនយល់ថាព្រោះហេតុអ្វីឡើយ។ ព្រោះពួកគេតែងយល់នូវវិធីសាស្ត្រ ដែលត្រៀមយកឈ្នះដោយការប្រយុទ្ធ ប៉ុន្តែមិនយល់ថាយើងធ្វើយ៉ាងណា ផ្អែកទៅលើស្ថានភាពផ្លាស់ប្ដូររបស់



www.elibraryofcambodia.org

ខ្មាំង ហើយអនុវត្តនូវវិធីសាស្ត្រប្រយុទ្ធដ៏ឈ្លាសវៃនោះទេ។ ហេតុនេះ ពេលដែលទទួលបានជោគជ័យម្តងៗ វាពុំមែនជាការយកតម្រាប់ សាចុះសាឡើង តាមក្បួនប្រយុទ្ធពីមុននោះទេ ប៉ុន្តែ ជាការចេះសម្របទៅតាមស្ថានភាពជាក់ស្តែងរបស់ខ្មាំង ពោល គឺប្រែប្រួលឥតដែនកំណត់ ឥតទីបញ្ចប់។ ក្រិត្យក្រមនៃការដឹកនាំទ័ពប្រយុទ្ធ ប្រៀបដូចខ្សែទឹកហូរ។ ក្រិត្យក្រមនៃទឹក គឺគេចពីទីខ្ពស់ហូរចាក់មកទីទាប។ ក្រិត្យក្រមនៃការដឹកនាំទ័ព ប្រយុទ្ធ គឺចៀសពីទីតាំងដែលរឹងមាំរបស់ទ័ពខ្មាំង ងាកទៅ វាយប្រហារលើ ទីតាំងដែលទន់ខ្សោយរបស់ទ័ពខ្មាំង។ ទឹក គឺអាស្រ័យដោយភូមិសាស្ត្រខ្ពស់ទាប បានកំណត់ទិសដៅខ្សែចរន្តហូររបស់វា ចំណែកការដឹកនាំទ័ពប្រយុទ្ធ ត្រូវយោងទៅលើស្ថានភាពខ្មាំង នឹងធ្វើការសម្រេចទិសដៅគោលការណ៍ ដើម្បីត្រៀមលក្ខណៈឈ្នះ។ ហេតុនេះ ការដឹកនាំទ័ពប្រយុទ្ធ គ្មានវិធីសាស្ត្រ ឬយុទ្ធវិធីណាដែលជាភាពថេរឥតប្តូរផ្លាស់នោះទេ បីដូចជាទឹកយ៉ាងនោះដែរ តែងផ្លាស់ប្តូររូបភាពនៃចរន្តតាមសណ្ឋាន



www.elibraryofcambodia.org

ដី។ ការដែលអាចយោងទៅលើស្ថានភាពខ្លាំង និង ត្រៀមលក្ខណៈឈ្នះនោះ គឺមានឈ្មោះថាជាការ ដឹកនាំទ័ពដូច ព្រះអាទិទេព។ ក្រិត្យក្រមនៃការ ដឹកនាំទ័ពប្រយុទ្ធ ប្រៀបដូចបាតុភូតក្នុងធម្មជាតិ ដែល មានរូបធាតុទាំងប្រាំគឺ ៖ ទឹក-ភ្លើង-ឈើ-ដែក និង ដី ជាអាទិ៍។ រូបធាតុទាំងនេះ តែងមានទំនាក់ទំនង ឆ្លើយតបគ្នាទៅវិញទៅមក ជាភាពស្របផង ភាព ទំនាស់ផង ពោលគឺបង្កើតផង បំផ្លាញផង។ រដូវ កាលទាំងបួនផ្លាស់ប្តូរវេនគ្នាតាមលំដាប់។ ថ្ងៃមាន វែងមានខ្លី ពោល គឺរដូវដើមឆ្នាំថ្ងៃវែងយប់ខ្លី រដូវចុង ឆ្នាំយប់វែងថ្ងៃខ្លី។ រីឯរាត្រី ក៏មានរនោចមានខ្នើត ប្តូរ ផ្លាស់គ្មានទីបញ្ចប់។



www.elibraryofcambodia.org

# ជំពូកទី៧
# ចលនាទ័ពដណ្តើមទ្រៀបឈ្នះ

**ស៊ុនជឺ** និយាយថា៖

ធម្មតា ជាទូទៅក្នុងក្បួន ដឹកនាំទ័ពប្រយុទ្ធ នាយ-កង មេទ័ព ដែលទទួលបញ្ជាពីព្រះរាជា ពីថ្នាក់ដឹកនាំប្រទេស ដើម្បីធ្វើការចាត់តាំងប្រជារាស្ត្រឲ្យក្លាយជាកងទ័ព រហូតដល់ការដឹកនាំបញ្ជូនទ័ពចេញទៅសមរភូមិប្រយុទ្ធ ក្នុងដំណាក់កាលនោះគ្មានអ្វីពិបាកជាងការប្រជែងដណ្តើមល័ក្ខខ័ណ្ឌ ដើម្បីយកជ័យជម្នះទៅលើទ័ពខ្មាំងនោះទេ។ ប្រជែងដណ្តើមទីតាំង ដែលជាឧបស័គ្គពិបាកបំផុត ជាលក្ខ័ខ័ណ្ឌជ័យជម្នះ ប្រកបដោយអំណោយផល ហើយទន្ទឹមនោះ ត្រូវធ្វើយ៉ាងណា តាមរយៈនៃផ្លូវក្រវិចក្រវៀនកេលកុង ដើម្បីសម្រេចបានដល់គោលដៅ គឺផ្លូវត្រង់ហើយប្រែក្លាយភាពឧបស័គ្គមិនអំណោយផល ទៅជាភាពងាយស្រួល ភាពជាអំណោយផលវិញ។ ចេតនា



www.elibraryofcambodia.org

ព្យាយាមដើរតាមផ្លូវក្រវិចក្រវៀន កេលកុង រួចប្រើប្រាស់ផលប្រយោជន៍តូចតាច ដើម្បីជន្លបញ្ឆោតពួកខ្មាំង។ ធ្វើបានដូចនេះ ទើបអាចទៅដល់គោលដៅដែលត្រូវដណ្ដើមប្រជែងបានមុន ថ្វីត្បិតតែចេញដំណើរក្រោយទ័ពខ្មាំង។ ដូច្នេះ ចាត់ទុកថាបានចេះប្រើកលឧបាយ យកភាពក្រវិចក្រវៀន កេលកុង ធ្វើជាផ្លូវត្រង់ - ពោលគឺយកវៀចធ្វើត្រង់ "ផ្លូវវៀចកុំបោះបង់ ផ្លូវត្រង់កុំដើរហាង" យ៉ាងនេះឯង។ ការបញ្ជូនកងទ័ពធំមួយទាំងមូល ទៅប្រជែងដណ្ដើមយកប្រៀប នៅសមរភូមិ ដោយនាំទៅជាមួយទាំងសម្ភារៈសឹក ទាំងស្បៀងអាហារ និងទាំងរថសឹក រថដឹកជញ្ជូនធំតូច គ្រប់បែបសព្វយ៉ាងនោះ ប្រាកដជាពុំអាចទៅដល់គោលដៅទាន់ពេល ដូចដែលបានកំណត់ទុកឡើយ។ ប្រសិនបើទុករទេះធំ រថដឹកជញ្ជូនធ្ងន់ៗ ចោលនៅខាងក្រោយ ដើម្បីឲ្យកងទ័ពបានស្រាលខ្លួនធ្វើដំណើរទៅ ដណ្ដើមប្រជែងប្រៀបនោះវត្ថុសម្ភារៈទាំងនោះ នឹងត្រូវខូចខាតអន្តរាយអសារបង់។ ហេតុដូច្នេះ ការដែលដោះអាវក្រោះ



www.elibraryofcambodia.org

ចោលចេញ ហើយពាក់ឯកសណ្ឋានស្រាលៗជំនួស វិញ ដើម្បីទៅឲ្យឆាប់ដល់ដោយថ្ងៃមិនឈប់ យប់ក៏មិនសម្រាក បង្កើនល្បឿនទ្វេដង ធ្វើដំណើរជាប់រហូតឥតឈប់ឈរ ឆ្លងកាត់ចម្ងាយផ្លូវរាប់រយយោជន៍ ដើម្បីប្រជែងដណ្តើមយកប្រៀបលើទ័ពខ្មាំង។ ធ្វើដូចនេះ ទាំងពលទាហាន ទាំងមេទ័ព នឹងត្រូវខ្មាំងចាប់ខ្លួន ធ្វើជាឈ្លើយសឹកពុំខានឡើយ ពីព្រោះ ពួកអ្នកដែលខ្លួនខ្លាំងកម្លាំងមាន គេនឹងទៅដល់មុន រីឯអ្នកកម្លាំងខ្សោយ ហេវហត់ ក៏ត្រូវបោះបង់ចោលនៅតាមផ្លូវ ទីបំផុត សម្រេចសម្រួចមក មានតែមួយភាគដប់ នៃចំនួនទ័ពដែលបានទៅដល់គោលដៅ ។ ការចល័តដំណើរទ័ពដោយប្រញាប់ប្រញាល់បន្ទាន់ក្នុងចម្ងាយផ្លូវមួយ ៥០ យោជន៍ ដើម្បីប្រជែងប្រៀបនោះ ពួកមេទ័ព នាយកង និងពលទាហានជួរមុខ អាចជួបការលំបាក ពីព្រោះមានតែពាក់កណ្តាល នៃចំនួនទ័ពប៉ុណ្ណោះ ដែលបានទៅដល់គោលដៅ។ តែបើធ្វើដំណើរជាបន្ទាន់ ក្នុងចម្ងាយផ្លូវ ៣០យោជន៍ ដើម្បីប្រជែងប្រៀបវិញនោះ



www.elibraryofcambodia.org

នឹងអាចមានត្រឹមតែពីរភាគបីនៃចំនួនទ័ព ដែលបានទៅដល់គោលដៅ។ ដូច្នេះ កងទ័ពដែលគ្មានរទេះធំ រថដឹកជញ្ជូនធ្ងន់ៗ នឹងត្រូវបរាជ័យ កងទ័ពដែលគ្មានស្បៀង គឺមិនអាចរស់បាន គ្មានវត្ថុសម្ភារៈបម្រុង ក៏មិនអាចតស៊ូ អត់ធ្មត់ប្រយុទ្ធបាននោះដែរ។ បើមិនយល់ មិនក្តាប់បាន នូវកលឧបាយរបស់បណ្តាសាមន្តប្រទេស (ប្រទេសជាចំណុះ) គឺមិនអាចចងសម្ព័ន្ធជាមួយពួកគេបានឡើយ។ មិនយល់មិនស្គាល់ស្ថានភាពព្រៃភ្នំ ទីជាឧបស័គ្គ រាល់ភូមិសាស្ត្រដែលជាភក់ល្បាប់បឹងបួ គឺពុំអាចទទួលបានជ័យភូមិ ភូមិសាស្ត្រជាអំណោយផល សម្រាប់ទ័ពខ្លួននោះឡើយ។ កាន់ទ័ពចេញច្បាំង ត្រូវចេះឈ្លាសវៃក្នុងការបោកបញ្ឆោត ត្រូវចេះប្រែប្រួលសម្បូរបែប ទើបអាចសម្រេចជោគជ័យ។ ផ្អែកទៅលើកត្តា ដែលគប្បីមានប្រយោជន៍ ដើម្បីធ្វើការសម្រេចចិត្តឲ្យសកម្មភាពរបស់ខ្លួន ធ្វើការបែងចែកឬប្រមូលផ្តុំកម្លាំង អាស្រ័យដោយស្ថានភាព និងធ្វើការផ្លាស់ប្តូរឲ្យសមស្រប។ ហេតុដូចនេះ ពេលកងទ័ពធ្វើសកម្មភាពរហ័ស គឺ



www.elibraryofcambodia.org

ត្រូវគេគ្រឹកគគ្រេងសន្ទឹកគ្រាំៗ ប្រៀបដូច ខ្យល់បក់ព្យុះភ្លូច តែបើពេលសកម្មភាពឃឹតវិញ គឺត្រូវនៅនឹងថ្កល់ ប្រៀបបីដូចព្រៃភ្នំ។ ពេលដែលត្រូវវាយប្រហារទៅលើទ័ពខ្មាំង គឺសន្ធោសន្ធៅដូចអណ្តាតភ្លើងឆាបឆេះត្របាក់លេបយ៉ាងនោះឯង តែបើបោះជំរំនៅទីតាំងការពារវិញ គឺឈរខ្ពស់ត្រដឹម រឹងមាំដូចកំពូលភ្នំ តែកាលបើលាក់ខ្លួន ពួនស្ងាក់ គឺប្រៀបដូចផ្ទៃមេឃងងឹតឈឹង ពុំអាចមើលឃើញ ព្រះអាទិត្យព្រះច័ន្ទឬផ្កាយរះនៅទីណានោះឯង ប៉ុន្តែ ដល់ពេលធ្វើសកម្មភាពប្រៀបដូចផ្គររន្ទះកក្រើកមេឃ។ រឹបអូសទ្រព្យសម្បត្តិចាប់មនុស្សក្នុងភូមិ-ឃុំ បែងចែកប្រជារាស្ត្រ ដែលចាប់បានបើកទូលាយពង្រីកដែនដី បែងចែកភោគសម្បត្តិដែលរឹបអូសបានទាំងនោះ ធ្វើការវាយតម្លៃពីផលប្រយោជន៍ និង ភាពអន្តរាយ ពីភាពចំណេញឬខាត បាត់ឬគង់ តាមកាលឱកាសនិងធ្វើសកម្មភាពឲ្យបានសមស្រប។ ត្រូវដឹងឲ្យបានមុន នូវកលឧបាយ យកផ្លូវវៀចធ្វើផ្លូវត្រង់ គឺអាចទទួលបានជ័យជម្នះក្នុងសឹកសង្គ្រាម។ នេះគឺជាគោលការណ៍



www.elibraryofcambodia.org

ចលនាទ័ពដណ្ដើម ប្រៀបឈ្នះយ៉ាងដូច្នេះឯង ។ ដូចពាក្យពោលថា៖ " ពីព្រោះ ប្រើភាសានិយាយ ដើម្បីបញ្ជាទ័ពស្ដាប់ឥតច្បាស់ ដូច្នេះត្រូវចាត់ចែង ប្រើស្គរ គោំង ផ្លូង ជាដើម។ ប្រើកាយវិការដើម្បី បញ្ជាទ័ព មើលមិនឃើញច្បាស់ ទើបត្រូវតែចាត់ ចែងប្រើទង់បញ្ជា។ ស្គរ ផ្លូង គោំង-ទង់បញ្ជា សុទ្ធតែ បានប្រើប្រាស់ ដើម្បីឯកភាពសកម្មភាពរបស់កង ទ័ពពេលប្រយុទ្ធ ពេលដែលកងទ័ពបានឯកភាពធ្វើ សកម្មភាព គឺមនុស្សគ្រប់ៗរូប ក្លៀវក្លា ក្លាហាន ដោយមិនឯកោ ធ្វើដំណើររុលទៅមុខតែម្នាក់ឯង រីឯ អ្នកដែលខ្លាចញញើត រួញរា ក៏ពុំអាចដកថយក្រោយ តែឯងបានដែរ។ នេះគឺជាវិធីបញ្ជាទ័ព ដែលមាន កម្លាំងច្រើន។ ដូច្នេះ ជាទូទៅ ប្រយុទ្ធពេលយប់ តែងប្រើភ្លើង និងសម្លេងស្គរ ប្រយុទ្ធពេលថ្ងៃ តែង ប្រើទង់បញ្ជា។ អ្នកពូកែកាន់ទ័ពប្រយុទ្ធ ចាំបាច់ត្រូវ ចៀសពីភាពក្លៀវក្លារបស់ទ័ពខ្មាំង ពេលពើបប្រយុទ្ធ រង់ចាំដល់ពេលវា ធុញទ្រាន់ នឿយហត់ គឺវាយលុក ភ្លាមជាបន្ទាន់។ នោះហើយ ជាវិធីក្ដោបក្ដាប់ធាតុ



www.elibraryofcambodia.org

ភ្លៀវភ្លារបស់កងទ័ព។ យកភាពសុក្រឹតរបស់ខ្លួន ដើម្បីតទល់នឹងភាពច្របូកច្របល់របស់ទ័ពខ្មាំង យកភាពរឹងមាំរបស់ខ្លួន តទល់ជាមួយភាពធូរលុង ខ្វះចន្លោះរបស់ទ័ពខ្មាំង នោះគឺជាវិធីក្តោបក្តាប់ ក្រសោបចិត្តកងទ័ព។ យកទីតាំងកងទ័ពយើង ដែលស្ថិតនៅជិតសមរភូមិប្រយុទ្ធ ដើម្បីតទល់ជាមួយការស្វះស្វែងធ្វើដំណើរផ្លូវឆ្ងាយរបស់ទ័ពខ្មាំង យកការឈប់សម្រាកបានល្អ របស់កងទ័ពយើង តទល់ ជាមួយការនឿយហត់របស់ទ័ពខ្មាំង យកកងទ័ពដែលមានស្បៀងគ្រប់គ្រាន់ ហូបចុកឆ្អែតឆ្អន់ តទល់ជាមួយទ័ពខ្មាំង ដែលខ្វះស្បៀង ស៊ីចុកមិនគ្រប់គ្រាន់ នោះហើយ ជាវិធីក្តោបក្តាប់កម្លាំងប្រយុទ្ធរបស់កងទ័ព។ មិនរារាំងទ័ពខ្មាំងដែលមាន ទង់បញ្ជា រៀបរយ មានការចាត់តាំងហ្មត់ចត់ មិនវាយលុកទៅលើសមរភូមិណាដែលមានភាពសុក្រឹត មានកម្លាំងទ័ពភ្លៀវភ្លារបស់ទ័ពខ្មាំង នោះគឺវិធីក្តោបក្តាប់ស្ថានភាពខ្មាំង ហើយ ធ្វើការប្តូរផ្លាស់ឲ្យបានសមស្រប។ ហេតុនេះក្បួនពិជយ័សង្គ្រាម សម្រាប់ការដឹកនាំទ័ពប្រយុទ្ធគឺ :



www.elibraryofcambodia.org

ពេលដែលកងទ័ពខ្មាំង ដណ្ដើមបានទីតាំង ដែលជាតំបន់ដីខ្ពស់ យើងមិនត្រូវធ្វើការវាយលុកពីក្រោមទៅលើទីខ្ពស់នោះទេ។ ទ័ពខ្មាំងផ្អែកខ្នងទៅលើតំបន់ដីខ្ពស់ យើងមិនគួរវាយលុកចំពីមុខវាឡើយ ទ័ពខ្មាំងធ្វើល្បិចហាក់ដូចជាបរាជ័យ មិនគួរកៀងពលដេញតាមទេ កម្លាំងធាតុ រត្ប៉ូវគ្លា ទឹកចិត្តប្រយុទ្ធរបស់ទ័ពខ្មាំងកំពុងឡើងខ្ពស់ មិនត្រូវវាយប្រហារចំពោះមុខទេ ទ័ពខ្មាំងដែលយកពលទាហានមួយចំនួនតូច ធ្វើជានុយបញ្ឆោតយើង យើងមិនបាច់ចាប់អារម្មណ៍ឡើយ កងទ័ពខ្មាំងកំពុងដកថយទៅប្រទេសខ្លួនវិញ យើងកុំរាំងវា។ ហ៊ុមព័ទ្ធទ័ពខ្មាំង ចាំបាច់ត្រូវទុកច្រកចេញមួយ ទ័ពខ្មាំងស្ថិតក្នុងភាពទាល់ច្រក មិនគួររុញខ្ទប់ជញ្ជាំងទេ។ រាល់កត្តាទាំងនោះ សុទ្ធតែជាក្បួនពិជ័យសង្គ្រាម ក្នុងការដឹកនាំទ័ពប្រយុទ្ធ ដែលមេទ័ពម្នាក់ៗចាំបាច់ត្រូវក្ដាប់ឲ្យបានច្បាស់។


www.elibraryofcambodia.org

# ជំពូកទី៨
# ភាពប្រែប្រួលទ្វារប្រាំបួន

**ស៊ុនជឺ** និយាយថា ៖

ធម្មតា ក្នុងការដឹកនាំទ័ពចេញទៅសមរភូមិប្រយុទ្ធ មេទ័ពទាំងអស់តែងត្រូវបានទទួលបញ្ជា ពីព្រះរាជាជាម្ចាស់ផែនដី ឬពីសំណាក់ថ្នាក់ដឹកនាំប្រទេស ដើម្បីកេណ្ឌប្រមូលទាហានមកចាត់តាំងទៅជាកងទ័ព។ នៅពេលចេញដំណើរប្រតិបត្តិការសឹក កាលបើស្ថិតនៅទីដីជាឧបស័គ្គ មិនត្រូវបោះទ័ពតាំងជំរំទីនោះទេ បើស្ថិតនៅទីដីប្រសព្វមុខ ត្រូវចងសម្ព័ន្ធមិត្ត ជាមួយបណ្តាសាមន្តប្រទេស (ប្រទេសជិតខាង-ប្រទេសជាចំណុះ) នៅទីដីឆ្ងាយដាច់ស្រយ៉ាល កុំបង្អាក់ដំណើរទ័ព អែអង់ វេរង់នៅទីនោះឲ្យសោះ បើស្ថិតនៅទីដីគ្រោះថ្នាក់ ត្រូវចេះរិះរេ គិតរកកលឧបាយល្អចំណាន គេចផុតពីទីនោះ តែបើស្ថិតនៅទីដីមរណៈ ត្រូវប្តេជ្ញាចិត្តប្រយុទ្ធស្លាប់រស់



www.elibraryofcambodia.org

ដើម្បីបើកផ្លូវ ដែលគេតែងហៅថា "ប្រយុទ្ធបើកផ្លូវឈាម"។ មានផ្លូវខ្លះ អាចធ្វើដំណើរឆ្លងកាត់ មានកងទ័ពខ្មាំងខ្លះ មិនចាំបាច់ត្រូវពើបប្រយុទ្ធ មានក្រុងកំពែងខ្លះ មិនចាំបាច់ទន្ទ្រានយក មានមូលដ្ឋានខ្លះ មិនចាំបាច់ប្រជែងដណ្តើម ហើយមាន ព្រះរាជបញ្ជាឬបទបញ្ជាខ្លះ មិនចាំបាច់គោរព ឬ អនុវត្តតាមឡើយ។ ពីព្រោះក្នុងសមរភូមិពិត ខុសពីការពិតក្នុងបទបញ្ជា ដូច្នេះ មេទ័ពដែលយល់បានច្បាស់ អំពីគុណសម្បត្តិ និងគុណវិបត្តិ នៃភាពប្រែប្រួលទ្វារប្រាំបួន ក្នុងក្បាច់ប្រយុទ្ធខាងលើ បានន័យថា ចេះក្បួនដឹកនាំទ័ពទៅហើយ។ មេទ័ពណាដែល មិនយល់ចំណុចពូកែ ស្មៀតល្អ នៃភាពប្រែប្រួលខាងលើទេនោះ ទោះបីជាយល់ភូមិសាស្ត្រ ក៏ពុំអាចក្តោបក្តាប់ ឬ ទទួលនូវភាពអំណោយផលពីជ័យភូមិបាដែរ។ បញ្ជាទ័ពប្រយុទ្ធ តែមិនចេះវិធីនៃភាពប្រែប្រួលទាំងប្រាំបួនចំណុច ទោះបីបានយល់ដឹងអំពី



www.elibraryofcambodia.org

ផលប្រយោជន៍ទាំងប្រាំបួន យ៉ាងណាក្តី ក៏ពុំអាចបញ្ចេញអស់សមត្ថភាពប្រយុទ្ធរបស់កងទ័ពបានដែរ។ ដូច្នេះ សម្រាប់មេទ័ព ដែលឈ្លាសវាងវៃ ពេលត្រិះរិះពិចារណាទៅលើបញ្ហាអ្វីមួយ ត្រូវឈ្វេងយល់ឲ្យបានច្បាស់នូវផ្នែកទាំងពីររបស់វា គឺគុណសម្បត្តិនិងគុណវិបត្តិ ខាតនិងចំណេញ។ ក្នុងស្ថានភាពជាអំណោយផល ត្រូវគិតដល់ភាពដែលមិនអំណោយផល ពេលនោះកិច្ចការប្រព្រឹត្តទៅនឹងបានងាយស្រួលដោយរលូន។ ក្នុងស្ថានភាពដែលមិនអំណោយផលត្រូវគិត ដល់ភាពជាអំណោយផល ពេលនោះគ្រោះអាសន្ននឹងត្រូវ កំចាត់បង់។ ប្រការដែលអាចជាឥទ្ធិពលគ្របដណ្តប់ ទៅលើសាមន្តប្រទេស គឺយកកត្តាដែលគេខ្លបខ្លាចបំផុត មកគំរាមបង្ក្រាបពួកគេ។ ប្រការដែលអាចបញ្ជា ត្រីកញ្ជាក់ពួកសាមន្តប្រទេសបាន គឺប្រើប្រាស់កិច្ចការ ប្រកបដោយគ្រោះថ្នាក់បំផុត ដើម្បីចងបង្ខំពួកគេ។ ប្រការដែលអាចធ្វើឲ្យ



www.elibraryofcambodia.org

សាមន្តប្រទេសកោតគោរព គឺយកផលប្រយោជន៍ល្វងបញ្ឆោតពួកគេ។ ដូច្នេះ វិធីដឹកនាំទ័ព នៃក្បួនពិជ័យសង្គ្រាម មិនត្រូវធ្វើសេចក្ដីសង្ឃឹម ទៅលើការគិត ដែលថាទ័ពខ្មាំង មុខជាមកវាយប្រហារពុំខាននោះទេ ប៉ុន្តែ យើងត្រូវត្រៀមរៀបចំទីលានសមរភូមិប្រយុទ្ធ ដោយខ្លួនឯងជាស្រេច ដើម្បីរង់ចាំខ្មាំងសត្រូវ។ ត្រៀមប្រយុទ្ធគ្រប់កាលៈទេសៈ។ មិនត្រូវធ្វើសេចក្ដីសង្ឃឹមទៅលើការគិត ដែលថាទ័ពខ្មាំងវានឹងមិនមកវាយប្រហារនោះទេ ប៉ុន្តែ យើងត្រូវមានកម្លាំងទ័ពខ្លាំងពូកែ សម្រាប់យើង ដើម្បីធ្វើឲ្យទ័ពខ្មាំងមិនអាចមានវិធីបុកទម្លុះ វាយប្រហារយើងបាន ។ ជាភាពគ្រោះថ្នាក់ មហាអាសន្នដល់អាយុជីវិត សម្រាប់មេទ័ពដែលមានអត្តចរិតប្រាំយ៉ាង ដូចជា ៖ ដឹងតែពីប្រថុយស្លាប់ ប្រយុទ្ធទាំងកម្រោល ប្រាកដជានឹងត្រូវសម្លាប់។ គិតតែពីចង់រស់ ខ្លាចស្លាប់ ប្រាកដជានឹងត្រូវខ្មាំងចាប់រស់។ ក្រេវក្រោធ ឆាប់ខឹង ប្រាកដ



www.elibraryofcambodia.org

ជានឹងត្រូវខ្មាំងញុះញង់ អុជអាលឲ្យឆេះ ច្រឡោតតូង។ ភាពស្អាតស្អំ គោរពតម្លៃខ្លួនប្រកបដោយកិត្តិយស កិត្យានុភាព ប្រាកដជានឹងពុំអាចស៊ូទ្រាំចំពោះការបង្អាប់ បន្ថោក ធ្វើឲ្យអាម៉ាស ពីសំណាក់ខ្មាំងសត្រូវនោះឡើយ។ មានចិត្តអាណិតស្រឡាញ់មេត្តាធម៌ ចំពោះរាស្ត្រប្រជាខ្លាំងពេក ប្រាកដជានឹងត្រូវធ្វើឲ្យរំខាន ព្រោះតែចង់ការពារឲ្យប្រជារាស្ត្រនោះឯង។ លក្ខណៈចរិតប្រាំយ៉ាងខាងលើ ជាចំណុចខ្វះចន្លោះ ខុសឆ្គងទាំងប្រាំយ៉ាង ដែលមេទ័ពតែងទទួលរង ជាភាពគ្រោះថ្នាក់ មហន្តរាយ ក្នុងការដឹកនាំទ័ពប្រយុទ្ធ។ កងទ័ពទាំងមូលត្រូវកំទេច មេទ័ពត្រូវសម្លាប់ ក៏ព្រោះតែចំណុចខ្សោយ ប្រកបដោយគ្រោះថ្នាក់ទាំងប្រាំយ៉ាងនេះ ជាមូលហេតុបង្កើតឡើង។ ប្រការនេះ អ្នកជាមេទ័ព មិនអាចមើលរំលង ដោយមិនយកចិត្តទុកដាក់ ជាពិសេសបានឡើយ។

***



www.elibraryofcambodia.org

# ជំពូកទី៩
# ប្រតិបត្តិការសឹក

**ស៊ុនជឺ** និយាយថា៖

ជាទូទៅ ពេលកងទ័ពបើកយុទ្ធនាការប្រតិបត្តិការសឹក ក៏ដូចជាការ ពិនិត្យ អង្កេត ប៉ាន់ប្រមាណសភាពការណ៍ ទ័ពខ្មាំង នៅឯសមរភូមិ ចាំបាច់ត្រូវចាប់អារម្មណ៍ យកចិត្តទុកដាក់ ផ្តោតជាសំខាន់ចំពោះគោលការណ៍ខាងក្រោម ដូចមាន ៖

ពេលធ្វើដំណើរឆ្លងកាត់តំបន់ភ្នំ ត្រូវសរសៀរអែប តាមជ្រលងជើងភ្នំ និងធ្វើដំណើរឆ្ពោះទៅមុខជានិច្ច។ ពេលបោះជំរំទីតាំងឈរជើង ត្រូវរក្សាទិសខាងមុខឲ្យបានស្រឡះមើលបានឆ្ងាយ បើទ័ពខ្មាំងដណ្តើម បានមុននៅទីតាំងដីខ្ពស់ មិនត្រូវធ្វើការវាយលុក ពីក្រោមឡើងទៅលើខ្ពស់នោះទេ។ នេះជាគោលការណ៍ប្រតិបត្តិការសឹក យុទ្ធនាការប្រយុទ្ធនៅតំបន់ព្រៃភ្នំ។ ពេលឆ្លងកាត់ព្រែក ទន្លេ ត្រូវបោះទីតាំងទ័ព ឲ្យឆ្ងាយពីមាត់ព្រែក ឆ្ងាយច្រាំងទន្លេ។



www.elibraryofcambodia.org

ពេលទ័ពខ្មាំងកាត់ព្រៃក ទន្លេ ធ្វើដំណើរឆ្លងមក មិនត្រូវស្ទាក់វាយប្រហារវា ពេលនៅក្នុងទឹកភ្លាមនោះទេ ប៉ុន្តែ ត្រូវរង់ចាំឲ្យវាធ្វើដំណើរដល់ពាក់កណ្ដាលផ្លូវហើយ ទើបធ្វើការវាយប្រហារវា។ ដូចនេះទើបអំណោយផល។ ចង់ពើបប្រយុទ្ធជាមួយខ្មាំង មិនត្រូវរៀបចំក្បួនទ័ពក្បែរមាត់ទឹកទេ។ ពេលដែល ត្រូវបោះទីតាំងទ័ពតាមមាត់ទន្លេ ក៏ត្រូវបោះទីតាំងនៅដីខ្ពស់ ទុកទិសខាងមុខឲ្យស្រឡះ មើលឃើញច្បាស់បានឆ្ងាយទូលាយ មិនត្រូវបោះទីតាំងទ័ពរៀបចំក្បួនប្រយុទ្ធ នៅក្រោមប្រភពខ្សែទឹក របស់ទ័ពខ្មាំងទេ។ នេះជាគោលការណ៍ ប្រតិបត្តិការសឹក យុទ្ធនាការប្រយុទ្ធនៅតំបន់ព្រៃកទន្លេ។

ពេលធ្វើដំណើរឆ្លងកាត់តំបន់ភក់ល្បាប់ បឹងបួត្រូវធ្វើដំណើរឲ្យឆាប់រហ័ស ដើម្បីចេញផុតពីទីនោះ មិនត្រូវដំអក់ នៅទីនោះយូរទេ បើចៃដន្យប៉ះទង្គិចនឹងទ័ពខ្មាំងនៅតំបន់បឹងបួ ត្រូវច្បាមយកទីដែលមានស្មៅកក់ ព្រៃនាម ហើយបែរ ខ្នងទៅរកព្រៃឈើទាំងនោះ ឲ្យខានតែបាន។ នេះជាគោល



www.elibraryofcambodia.org

ការណ៍ប្រតិបត្តិការសឹក ប្រយុទ្ធនៅតំបន់ភក់ល្បាប់បឹងបួ។ នៅតំបន់វាលរាបដីស្មើ ចាំបាច់ត្រូវដណ្តើមយកទីតំបន់ ស្រឡះ ទូលាយ សំខាន់គឺស្លាបទាំងសងខាងឆ្វេងស្តាំនិងខាងក្រោយ ត្រូវផ្អែកទៅលើទីដីខ្ពស់ ខាងមុខទាប ខាងក្រោយខ្ពស់។ នេះជាគោលការណ៍ប្រតិបត្តិការសឹក ប្រយុទ្ធនៅតំបន់វាលរាប។

ក្តាប់បានចំណុចសំខាន់ នៃគោលការណ៍បោះទីតាំង ទាំងបួនខាងលើនេះ ជាមូលហេតុឆ្ពោះទៅកាន់ភាពជោគជ័យត្រចះត្រចង់។ ជាទូទៅ ការបោះទីតាំងទ័ព គេតែងចូលចិត្ត ជ្រើសយកទីដីខ្ពស់និងស្ងួត មិនចូលចិត្តទីដីទាបមានសំណើម ហើយជានិច្ចកាល ទាមទារត្រូវតែនៅខាងទិសដែលមានពន្លឺព្រះអាទិត្យ ចៀសកន្លែងដែលត្រូវបាំងបាត់ពន្លឺព្រះអាទិត្យ និង សើមប៉ប៉ិចប៉ាច់។ ការបោះទីតាំងទ័ពនៅតំបន់ដីខ្ពស់ វាងាយស្រួលក្នុងជីវភាពរស់នៅក្នុងជួរកងទ័ព មិនសូវជាកើតមានជំងឺដំកាត់ផ្សេងៗនោះគឺជា កត្តាមួយក្នុងបណ្តាកត្តាសំខាន់សម្រាប់



www.elibraryofcambodia.org

កងទ័ពទទួលបានជ័យជម្នះ។ ពេលបោះទីតាំងទ័ព លើភ្នំ លើទំនប់ ចាំបាច់ត្រូវបោះនៅខាងទិសដែលមានពន្លឺព្រះអាទិត្យ ហើយស្លាបទាំងសងខាង និងក្រោយខ្នង ត្រូវផ្អែកទៅទីនោះ។ ប្រការទាំងនេះសម្រាប់ដឹកនាំទ័ព សុទ្ធតែមានប្រយោជន៍ ពីព្រោះបានជំនួយពីភូមិសាស្ត្រ។ នៅខាងលើប្រភពខ្សែទឹកមេឃ ធ្លាក់ភ្លៀង ពពុះទឹកនឹងហូរតាមខ្សែទឹកចុះមក បើកងទ័ពត្រូវឆ្លងកាត់ព្រែក ត្រូវរង់ចាំឲ្យទឹក នឹងផ្ទៃទឹកស្ងប់រលកសិន ទើបឲ្យទ័ពឆ្លងកាត់។ ធម្មតាពេលជួបស្ថានភាពភូមិសាស្ត្រ ដូចជាភូមិសាស្ត្រផ្តាច់ចំណង គឺទឹកហូរចំកណ្តាលជ្រលងនៃជញ្ជាំងភ្នំសងខាងប្រកបដោយគ្រោះថ្នាក់។ ភូមិសាស្ត្រ អណ្តូងព្រះដែលទឹកព័ទ្ធជុំទាំងបួនទិស នៅចំកណ្តាលជាទីដីវាលរាប។ មានភូមិសាស្ត្រហៅថាគុកព្រះ សំណាញ់ព្រះ និងអន្លង់ព្រះជាដើម នោះចាំ បាច់ត្រូវប្រញាប់គេចចេញពីទីនោះ ទុកឲ្យទ័ពខ្មាំងនៅជិតនោះ យើងបែរមុខចំទីនោះ រីឯទ័ពខ្មាំងបែរខ្នងដាក់ទីនោះ។ ពេលកងទ័ព ធ្វើសកម្មភាពនៅទីដីមានផ្លូវតាមរងភ្នំខ្ពស់



www.elibraryofcambodia.org

មានបឹងបួ ទីដីទំនាប មានស្មៅ បបុសដុះស៊ុមទ្រុម ទីដីព្រៃភ្នំ ព្រៃស្រោង ឈើ វល្លិ៍ លតាជាតិដុះ ណែនណាន់ តាន់តាប់ មើលពុំយល់បានឆ្ងាយ ចាំបាច់ត្រូវពិនិត្យ អង្កេត រុកទន្ទ្រានរានរកឲ្យបាន ច្បាស់លាស់។ ព្រោះនៅទីនោះសុទ្ធតែជាទីកន្លែង ដែលខ្មាំងអាចបង្កប់ទ័ព ពួនស្ទាក់វាយប្រហារ ឬ ក៏ពួកចារបុរសពួនស៊ើបការជាដើម ។ ទ័ពខ្មាំងនៅជិត ទ័ពយើង តែវាហាក់ដូចមិនភិតភ័យ ស្លន់ស្លោ នោះក៏ ព្រោះតែវាអាងមានភូមិសាស្ត្រ ដែលជាជ័យភូមិ សម្រាប់វា។ ទ័ពខ្មាំងស្ថិតនៅឆ្ងាយពីទ័ពយើង តែ បានឲ្យទ័ពមកញុះញង់បបួលច្បាំងនោះ ក៏ព្រោះតែ ចង់បញ្ឆោតឲ្យយើងរុលទៅមុខ។ ដែលទ័ពខ្មាំងមិន ដណ្តើមយកទីតាំង ជាជ័យភូមិ តែបែរជាទៅបោះ ទ័ពនៅទីវាលរាបទៅវិញ នោះប្រាកដជាវាមាន ចំណុចអាងអ្វីមួយ ឬ ក៏មានកលគំនិតអ្វីពុំខាន។ កាលបើឃើញព្រៃឈើរំជើបរំជួលនោះ គឺទ័ពខ្មាំង កំពុងនៅក្រោមព្រៃឈើនោះធ្វើដំណើរមករកយើង។ នៅក្នុងកំប៉ូតព្រៃ ស្មៅ ស្បូវ ដែលច្រើនកន្លែងត្រូវ



www.elibraryofcambodia.org

បានបិទបាំងនោះ គឺខ្មាំងមានគំនិតធ្វើឲ្យយើងភ័យខ្លាចតក់ស្លុត។ ពេលឃើញបក្សីព្រៃ ស្រាប់តែ ស្លន់ស្លោស្ទុះហើរភិលៗ ក៏ព្រោះតែ ម្ដុំក្រោមព្រៃនោះមានបង្កប់ទ័ព។ ពេលឃើញម្រឹគ សត្វព្រៃ ស្លន់ស្លោរត់ឆ្វេចឆ្វាច ក៏ព្រោះតែខ្មាំងកំពុងរំកិលកម្លាំងទ័ពយ៉ាងច្រើនមកត្រៀមប្រយុទ្ធ។ ធូលីហើរខ្ពស់តែស្រួច នោះគឺមានរថសឹកកំពុងធ្វើដំណើរមក។ ធូលីហើរទាបតែទូលាយ នោះគឺទ័ពថ្មើរជើងកំពុងធ្វើដំណើរមក។ ធូលីហើររាត់រាយជាដុំតូចៗ ហើយវែងដូចផ្លូវនោះ គឺទ័ពខ្មាំងកំពុងកាប់ឧស។ ធូលីតិច តែពេលខ្លះហើរឡើងលើ ពេលខ្លះធ្លាក់ចុះទាប នោះគឺខ្មាំងកំពុងបោះជំរំទ័ព។ កាលបើបេសកជន មន្ត្រី ការទូតរបស់ខ្មាំងមកចរចា ប្រកបដោយសំដីទន់ភ្លន់ឱនលំទោន តែភាពពិតកំពុងស្រូតរូត ត្រៀមលក្ខណៈប្រយុទ្ធ គឺខ្មាំងនឹងធ្វើការវាយលុកយើងជាពុំខាន។ តែបើសំដីម៉ឺងម៉ាត់ រឹងប៉ឹង ហើយកងទ័ពមកនៅកៀកនឹងយើងទៀតនោះ គឺខ្មាំង ត្រៀមរៀបចំដកថយហើយ។ បើរថសឹកខ្មាំងបរចេញមកមុន ហើយ



www.elibraryofcambodia.org

ដណ្ដើមទីតាំងស្លាបឆ្វេងស្ដាំទាំងសងខាងនោះ គឺវាកំពុងត្រៀមរៀបចំទីលានប្រយុទ្ធ។ មិនបានណាត់ទុកមុន ប៉ុន្តែ ខ្មាំងបែរជាមកសុំចរចាសន្តិភាព នោះគឺវាមានកលឧបាយ។ ទ័ពខ្មាំងរត់ទៅប្រញាប់ប្រញាល់ ហើយបែរជាឲ្យរថសឹករៀបជាក្បួនប្រយុទ្ធ នោះគឺវាចង់ពើបប្រយុទ្ធជាមួយយើង ។ ទ័ពខ្មាំងរុលទៅមុខផង ថយក្រោយផង នោះគឺទ័ពខ្មាំងប្រើល្បិចកលបញ្ឆោតទ័ពយើង។ ទ័ពខ្មាំងឈរផ្អែកទៅលើអាវុធនោះជាបាតុភូតខ្វះស្បៀង ស្រេកឃ្លាន។ ទ័ពខ្មាំងដងក្បង់ទឹក ហើយផឹកដោយតក់ក្រហាល់ នោះគឺព្រោះតែស្រេកខ្លាំង ព្រោះតែខ្វះទឹក។ ទ័ពខ្មាំងឃើញប្រយោជន៍ តែមិនរុលទៅដណ្ដើម នោះក៏ព្រោះតែហេវហត់ខ្លាំងពេក។ នៅខាងលើបន្ទាយជំរំទ័ពខ្មាំង មានបក្សីទំច្រើន គឺទ័ពខ្មាំងបានបោះបង់បន្ទាយជំរំ។ កណ្ដាលយប់អធ្រាត នៅក្នុងបន្ទាយខ្មាំងមានមនុស្សភ័យខ្លាចស្រែកស្លន់ស្លោ សម្លេងធំៗ នោះបញ្ជាក់ថាទឹកចិត្តរបស់ទ័ពខ្មាំង កំពុងភ័យខ្លាច។ ទាហានទ័ពខ្មាំងអុកឡុក គឺព្រោះមេទ័ពខ្មាំងខ្វះភាព



www.elibraryofcambodia.org

ម៉ឹងម៉ាត់។ ទង់សញ្ញានៅបន្ទាយជំរំខ្មាំងទ្រេតទ្រោត គ្មានរបៀបរៀបរយ គឺដោយសារជួរទ័ពខ្មាំងច្របូកច្របល់។ នាយទាហានទ័ពខ្មាំងឆាប់ខឹងក្រេវក្រោធ គឺព្រោះតែកងទ័ពខ្មាំងទាំងមូលហេវហត់ខ្លាំងពេក។

ទ័ពខ្មាំងយកស្បៀងឲ្យសេះស៊ី ឬ កាប់សេះស៊ីសាច់ ប្រមែប្រមូលចានក្បាន ចង្ក្រាន ឆ្នាំង មិនវិលត្រឡប់មកជំរំវិញ នោះបញ្ជាក់ថា គេកំពុងស្ថិតក្នុងភាពទាល់ច្រក ត្រៀមប្រថុយស្លាប់ ប្រយុទ្ធបើកផ្លូវ។ មេទ័ពខ្មាំងហាក់ដូចមិនក្លាសំដី ពោលពាក្យស្រាលៗជាមួយពលទាហាន ក៏ព្រោះតែពួកគេបាត់បង់គុណធម៌។ ការផ្ដល់រង្វាន់ឲ្យទាហានជាបន្តបន្ទាប់ឥតឈប់ឈរ គឺព្រោះតែវាអស់មានជម្រើស។ ពិន័យទាហានជារៀងរហូត ក៏ព្រោះតែខ្មាំងកំពុងស្ថិតក្នុងភាពទាល់ច្រក។ មុនមាន ចរិតឃោរឃៅ ក្រោយមកហាក់ដូចជាខ្លាចញញើតថ្នាក់ក្រោម នោះគឺនាយទាហានខ្វះភាពភ្លឺស្វាង។ បេសកជនរបស់ ខ្មាំងបញ្ជូនមកចរចា ដែលមានសំដីសភាពរាបសារ ទន់ភ្លន់ ហើយមានឥរិយាបថ ឱនលំទោន គឺចង់ផ្អាកការប្រយុទ្ធ



www.elibraryofcambodia.org

បញ្ចប់សង្គ្រាម ទ័ពខ្មាំងបញ្ជូនមកទាំងភាពក្រេវក្រោធ ទាំងភាពក្តៀវក្លា ប៉ុន្តែ មិនព្រមពើបប្រយុទ្ធ ហើយក៏មិនព្រមដកថយនោះ ចាំបាច់ត្រូវពិនិត្យ អង្កេតដោយប្រុងប្រយ័ត្នបំផុត។ ពុំមែនកងទ័ពកាន់តែច្រើន កាន់តែខ្លាំងពូកែនោះទេ ប៉ុន្តែ កុំឲ្យតែប្រមាថ មើលងាយសត្រូវ មិនធ្វើការវាយលុកដោយប្រថុយប្រថាន ហើយអាចប្រមូលផ្តុំកងកម្លាំង ធ្វើការប្រមាណស្ថានភាពឲ្យ បានច្បាស់លាស់ ថាពិតណាស់ គឺអាចនឹងយកឈ្នះលើខ្មាំងសត្រូវបាន។ មានតែពួកមនុស្សដែលមិនចេះពិចារណាវែងឆ្ងាយ គ្មានគំនិតកលឧបាយ គឺជាក់ច្បាស់ នឹងត្រូវជាឈ្លើយសឹករបស់ខ្មាំង។ នាយទាហាន មេទ័ព ដែលដាក់ទណ្ឌកម្មពលទាហានពេលពួកគេមិនទាន់មានការស្និទ្ធស្នាល និងចេះពឹងផ្អែកលើខ្លួន ហើយពួកគេក៏មិនគោរពមេនោះដែរ។ ដូច្នេះ គឺពិបាកប្រើប្រាស់និងបញ្ជាណាស់។ ក្រោយពេល ពលទាហានដែលចេះពឹងផ្អែកលើមេ ហើយតែក្រឹត្យវិន័យនៅតែមិនគោរព មិនអនុវត្តនោះ កងទ័ពដូច្នេះក៏មិនអាចប្រើប្រាស់ ដើម្បីប្រយុទ្ធបាន



www.elibraryofcambodia.org

ដែរ។ ដូច្នេះ ត្រូវប្រើវិធីសាស្ត្រដែលយក "អក្សរសាស្ត្រ" ពោលគឺគោលនយោបាយគុណធម៌ ដើម្បី អប់រំកងទ័ព ប្រើវិធីសាស្ត្រដែលគេយក "គុន" ពោលគឺ យកច្បាប់អាជ្ញាសឹក ដើម្បីឯកភាពជួរទ័ព។ កងទ័ពប្រភេទនេះ ពេលចេញទៅសមរភូមិប្រយុទ្ធប្រាកដជាឈ្នះ។ រៀងរាល់ថ្ងៃ ត្រូវខិតខំអប់រំបំពាក់បំប៉ន់បទបញ្ជាបានជ្រួតជ្រាបក្នុងជួរ កងទ័ព នោះទើបពួកគេនឹងមានទម្លាប់ចេះគោរពបទបញ្ជា។ រាល់ថ្ងៃបទបញ្ជាអាចជ្រួតជ្រាប និងអនុវត្តទៅបាន គឺអាស្រ័យ ដោយទំនាក់ទំនង រវាងពលទាហាន និងនាយទាហានមានជំនឿទុកចិត្តចំពោះគ្នានិងគ្នាល្អប្រសើរ។

❊❊❊



www.elibraryofcambodia.org

## ជំពូកទី១០
## ភូមិសាស្ត្រ

**ស៊ុនជឺ** និយាយថា ៖

ភូមិសាស្ត្រមានប្រាំមួយប្រភេទគឺ ៖ ភូមិងាយ ភូមិអន្ទាក់ ភូមិឧបសគ្គ ភូមិមានប្រៀប ភូមិគ្រោះថ្នាក់ និង ភូមិឆ្ងាយស្រយ៉ាល។ ទីលានដែលយើងអាចទៅ ខ្មាំងក៏អាចមកបាន ហៅថាភូមិងាយ។ តំបន់ដែលមានភូមិងាយ ត្រូវប្រញាប់ដណ្ដើមយកឲ្យបានទីតាំងខ្ពស់ និងមានពន្លឺព្រះអាទិត្យ ធ្វើឲ្យស្រឡះ ស្រឡំ និងការពារផ្លូវជំនួយស្បៀង ធ្វើបានដូចនេះ ពេលពើបប្រយុទ្ធជាមួយខ្មាំង យើងនឹងមានអំណោយផលជាង។

ទីដីដែលទៅមុខងាយ ថយក្រោយពិបាក ហៅថា ភូមិអន្ទាក់។ នៅតំបន់ដីដែលមានភូមិអន្ទាក់ បើទ័ពខ្មាំងគ្មានការការពារ យើងអាចបញ្ជាទ័ពវាយប្រហារដោយឆ្មក់វាយ ដើម្បីយកឈ្នះលើទ័ពខ្មាំង



www.elibraryofcambodia.org

ប៉ុន្តែបើទ័ពខ្មាំងមានការការពារ យើងនាំទ័ពវាយប្រហារហើយពុំអាចយកឈ្នះបាននោះ វានឹងពិបាកដកថយ នេះហើយគឺមិនអំណោយផល។ ទីដីដែលយើងរុលទៅមិនអំណោយផល ទ័ពខ្មាំងរុលមកក៏មិនអំណោយផល ហៅថាភូមិឧបស័គ្គ ។ នៅតំបន់ដីដែលមានភូមិឧបស័គ្គ ទោះជាខ្មាំងយកផលប្រយោជន៍ ដើម្បីបញ្ឆោតយើង ក៏យើងមិនត្រូវចេញប្រយុទ្ធដែរ មានតែនាំទ័ពចៀសចេញ រង់ចាំទ័ពខ្មាំងចេញមកដល់ពាក់កណ្ដាលផ្លូវ ទើបយើងបែរទ័ពមកធ្វើការ ឆ្មក់វាយប្រហារ សង្គ្រប់យកឈ្នះ ដូចនេះទើបអំណោយផល។ ទីដីដែលមានលក្ខណៈជាភូមិមានប្រៀប បើទ័ពយើងទៅដល់មុន ដណ្ដើមបានច្រកទ្វារសំខាន់ប្រើប្រាស់ ដាក់កម្លាំងទ័ពពិសេសឈរជើងការពារ រង់ចាំទ័ពខ្មាំងមកដល់ វាយប្រហារភ្លាម ប៉ុន្តែ បើទ័ពខ្មាំងមកដល់មុន ដណ្ដើមច្រកទ្វារសំខាន់ ហើយដាក់ទ័ពពិសេសឈរជើងការពារ យើងមិនត្រូវធ្វើការវាយលុកទេ។ ប៉ុន្តែ បើខ្មាំងមិនបានដាក់ទ័ពពិសេសទេ យើងប្រញាប់វាយលុក ដើម្បី



www.elibraryofcambodia.org

ដណ្ដើមកាន់កាប់ឲ្យខានតែបាន។ នៅទីដីដែលមានលក្ខណៈជាភូមិគ្រោះនោះ បើទ័ពយើងដណ្ដើមកាន់កាប់បានមុន ត្រូវក្ដោបក្ដាប់តំបន់ដីខ្ពស់ហើយបែរទៅរកពន្លឺព្រះអាទិត្យ ដើម្បីរង់ចាំទ័ពខ្មាំង។ តែបើទ័ពខ្មាំង ដណ្ដើមបានមុនយើង យើងគួរដកថយដោយស្វ័យប្រវត្តិ មិនត្រូវវាយលុកវាទេ។ នៅតំបន់ដីជាភូមិឆ្ងាយ ស្រយ៉ាល ភាគីទាំងសងខាង ធ្វើការថ្លឹងកម្លាំងគ្នា មិនគួរបង្កប្រយុទ្ធ បង្ខំចិត្ត ច្បាំងគ្នា វានឹងមិនមានអំណោយផលសម្រាប់យើង។

ចំណុចទាំងប្រាំមួយខាងលើ គឺជាគោលការណ៍ទាញប្រយោជន៍ពីភូមិសាស្ត្រ។ នេះហើយជាកន្លែងដែល នាយទាហ៊ាន មេទ័ព ត្រូវមានភារកិច្ចដ៏ធំធេង ត្រូវសិក្សាយ៉ាងហ្មត់ចត់ដោយខានពុំបាន ។ ស្ថានភាពបរាជ័យរបស់កងទ័ព មានប្រាំមួយចំណុច គឺរត់ចោលជួរ គ្មានច្បាប់ទម្លាប់ បាត់ក្ដីសង្ឃឹម រលាយបង់ ច្របូកច្របល់ និងប្រថុយប្រថាន។ ប្រាំមួយចំណុចនេះ ពុំមែនជាគ្រោះមហន្តរាយ ដែលទេវតាទម្លាក់ពីលើចុះមកនោះទេ ប៉ុន្តែ គឺអាស្រ័យដោយ



www.elibraryofcambodia.org

តែភាពខុសឆ្គង ខ្វះចន្លោះ របស់នាយទាហាន មេទ័ព ទាំងឡាយបង្កឡើង។ពេលដែលល័ក្ខខ័ណ្ឌរវាងយើង នឹងខ្មាំងប្រហាក់ប្រហែលគ្នា កាលបើយើងតយុទ្ធវាយ លុកជាមួយទ័ពខ្មាំង ដែលលើសយើងដប់ដង ហេតុ នេះធ្វើឲ្យយើងបរាជ័យ ហៅថារត់ចោលជួរ។ ពល ទាហានខ្លាំងពូកែ តែនាយទាហានបែរជាខ្លបខ្លាច ហេតុនោះធ្វើឲ្យយើងបរាជ័យ ហៅថាគ្មានច្បាប់ ទម្លាប់ ។ នាយទាហាន មានអត្តភាពខ្ពស់ តែ ពលទាហានខ្លបខ្លាច ហេតុនោះធ្វើឲ្យចាញ់ ហៅថា អស់សង្ឃឹម។ ពួកនាយទាហានក្រេវក្រោធ មិន គោរពបទបញ្ជាថ្នាក់លើ ជួបខ្មាំងចូលវាយលុកដោយ ចិត្តឯង ក្នុងពេលដែលថ្នាក់លើពុំទាន់បានយល់ ច្បាស់ថា ពួកគេអាចត្រៀមយកឈ្នះបាន ឬ អត់ ហេតុនោះនាំឲ្យបរាជ័យ ហៅថាវិនាស។ ថ្នាក់លើ កំសាក ខ្លបខ្លាច ហើយខ្វះក្រឹត្យវិន័យម៉ឺងម៉ាត់ ហ្វឹកហ្វឺន អប់រំមិនបានច្បាស់លាស់ ឲ្យមន្ត្រីយោធា ពលទាហាន មិនដឹងធ្វើយ៉ាងណារៀបចំទីលានសមរ ភូមិប្រយុទ្ធ ច្របូកច្របល់មិនត្រូវបែបបទតាមក្បួន



www.elibraryofcambodia.org

យុទ្ធសាស្ត្រ ហេតុនោះបរាជ័យហៅថាច្របូកច្របល់។ ថ្នាក់លើពុំអាចប៉ាន់ស្មានស្ថានភាពខ្មាំង បានច្បាស់លាស់ យកតិចវាយច្រើន យកខ្សោយតទល់ នឹងខ្លាំង ហើយគ្មានកងទ័ពស្រួចជាស្នូលត្រី: ហេតុនោះ បរាជ័យ ហៅថាប្រថុយប្រថាន។

ស្ថានភាពទាំងប្រាំមួយ ដែលបានពោលមកខាងលើ វាពិតជានាំទៅដល់ភាពបរាជ័យរបស់កងទ័ព នោះជាភារកិច្ច ដ៏ធំធេងសម្រាប់មេទ័ពគ្រប់រូប។ ហេតុនេះមិនអាចមិនសិក្សា ឲ្យច្បាស់លាស់បានឡើយ។ ប្រមាណស្ថានភាពយ៉ាងច្បាស់លាស់ កសាងផែនការត្រៀមយកឈ្នះ សិក្សាអំពីភូមិសាស្ត្រជ័យភូមិ ឬ ភូមិគ្រោះយ៉ាងណានោះ គិតគូរចម្ងាយផ្លូវវែងខ្លី ។ល។ រាល់កត្តាទាំងនេះ គឺជាកិច្ចការដែលមេទ័ពត្រូវក្ដាប់ឲ្យច្បាស់។ យល់ដឹងបាននូវរាល់បញ្ហាទាំងនោះ រួចហើយយកវាមកប្រើប្រាស់ក្នុងកិច្ចការដឹកនាំទ័ពប្រយុទ្ធ ប្រាកដជាឈ្នះក្នុងសឹក សង្គ្រាម។ មិនដឹងមិនយល់ពីបញ្ហាទាំងនេះ ហើយដឹកនាំទ័ពប្រយុទ្ធ ប្រាកដជាបរាជ័យដោយចៀសមិនផុត។



www.elibraryofcambodia.org

កាលបើយោងតាមស្ថានភាពពិត នៃសមរភូមិ ក្តាប់បាននូវកត្តាឈ្នះហើយ ទោះបីព្រះរាជបញ្ជា របស់ស្តេចផែនដីបង្គាប់មិនឲ្យច្បាំង ក៏អាចបន្តការ ប្រយុទ្ធ ប៉ុន្តែកាលបើយោងលើស្ថានភាពពិតនៃ សមរភូមិ ឃើញថាពុំអាចយកឈ្នះបាននោះ ទោះ ព្រះរាជបញ្ជារបស់ស្តេចបង្គាប់ឲ្យច្បាំង ក៏អាចមិន ច្បាំងបានដែរ។ ដូច្នេះ សមដូចពាក្យថារុលទៅមុខ មិនដើម្បីឈ្មោះល្បី ដកថយក្រោយ មិនដើម្បី គេចវេះទោស កំហុស គឺគ្រាន់តែគិតគូរ ការពារ ប្រជានុរាស្ត្រ ស្របតាមផលប្រយោជន៍ ជាមូលដ្ឋាន នៃស្តេចផែនដី នៃទឹកដីបុរីនគរ។ មេទ័ព នាយកង ដូចនេះទើបជាវីរជន ដ៏ឆ្នើមរបស់ប្រទេសជាតិ។ មេ ទ័ព នាយកង ចំពោះពលទាហាន បើថែរក្សាពួកគេ ប្រៀបដូចកូនបង្កើត ដែលនៅក្មេងខ្ចី ពលទាហាន ដើរតាមមេទ័ព ហើយអាចលោតចូលក្នុងភ្នក់ភ្លើង-ទឹកក្តៅ ហើយរួមស្លាប់រស់ជាមួយមេកោយ ដោយ ឥតញញើតក្រែងស្តាយស្រណោះជីវិត។ ប៉ុន្តែ ចំពោះ ពលទាហាន រក្សាបីបាច់ហួសហេតុ ដល់ថ្នាក់មិន



www.elibraryofcambodia.org

យកទៅប្រើប្រាស់ គ្រាន់តែទំយើ ថ្នាក់ថ្នម មិន បង្គាប់បញ្ជា ល្មើសច្បាប់វិន័យមិនពិន័យដាក់ទោស ទ័ណ្ឌឲ្យបានម៉ឺងម៉ាត់នោះ កងទ័ពប្រភេទនេះ មិនខុស ណាកូនទំយើមួយ មិនអាចប្រើប្រាស់ ដើម្បីច្បាំង ប្រយុទ្ធបានឡើយ ។ មានតែការយល់ដឹងយ៉ាង ច្បាស់ អំពីកងទ័ពយើង-ទ័ពខ្មាំង ថាតើអាច ប្រយុទ្ធខ្លាំងពូកែយ៉ាងណានោះ លទ្ធភាពសម្រាប់ ជោគជ័យ គឺទទួលបានពាក់កណ្ដាលទៅហើយ។ យល់ដឹងច្បាស់ទ័ពខ្មាំងថាអាច វាយប្រហារបាន ហើយយល់ដឹងយ៉ាងច្បាស់អំពីកងទ័ពយើង ថា អាចច្បាំងប្រយុទ្ធបាន តែមិនយល់ច្បាស់អំពីភាព ជាឧបស័គ្គ នៃសមរភូមិ សម្រាប់យុទ្ធនាការសឹក គឺ លទ្ធភាពសម្រាប់ទទួលជ័យជម្នះ បានត្រឹមតែពាក់ កណ្ដាលប៉ុណ្ណោះ។ ហេតុនេះ អ្នកជំនាញជាញជ័យ ក្នុងការបញ្ជាទ័ពប្រយុទ្ធពិតប្រាកដ សកម្មភាពយោធា របស់គេដាច់ខាតមិនស្រពិចស្រពិល ការចាត់តាំង របស់គេប្រែប្រួលគ្មានដែនកំណត់ គ្មានកោះគ្មានត្រើយ។



www.elibraryofcambodia.org

ដូចនេះទើបពោលថា ៖ យល់អំពីយើង ដឹងអំពីខ្មាំង ច្បាំងប្រាកដជាឈ្នះមិនចេះចាញ់ - យល់មេឃស្គាល់ដី ជ័យជម្នះនឹងក្តាប់ណែននៅក្នុងកណ្តាប់ដៃ។



www.elibraryofcambodia.org

# ជំពូកទី១១
# សណ្ឋានដី ប្រាំបួនប្រភេទ

**ស៊ុនជឺ** និយាយថា៖

យោងតាមគោលការណ៍ដឹកនាំទ័ពប្រយុទ្ធ ក្នុងក្បួនពិជ័យសង្គ្រាម យុទ្ធភូមិនៃភូមិសាស្ត្រ អាចបែងចែកជាប្រាំបួនសណ្ឋានដី ដូចតទៅ ៖ ដីពង្រាយ ដីរាក់ ដីប្រជែង ដីជំនួប ដីប្រសព្វមុខ ដីជម្រៅ ដីឧបស័គ្គ ដីគ្រោះថ្នាក់ (ហ៊ុមព័ទ្ធ) និងដីមរណៈ។

ពួកសាមន្តប្រទេសច្បាំងគ្នាជាមួយទ័ពខ្មាំង នៅលើដែនអធិបតេយ្យរបស់យើង តំបន់នោះហៅថាដីពង្រាយ។ ការរុលចូលទៅក្នុងដែនដីរបស់ខ្មាំងមិនជ្រៅ ហៅថាដីរាក់។ តំបន់ដីដែលយើងដណ្ដើមកាន់កាប់បានមុន ជាប្រយោជន៍សម្រាប់ទ័ពយើង បើខ្មាំងដណ្ដើមបានមុន ជាប្រយោជន៍របស់ទ័ពខ្មាំង ហៅថាដីប្រជែង។ តំបន់ដីដែលយើងអាចទៅ ខ្មាំងអាចមក ហៅថាដីជំនួប។ តំបន់ដីស្ថិតនៅក្បែរយើង



www.elibraryofcambodia.org

ក្បែរខ្មាំង និងក្បែរបណ្តាសាមន្តប្រទេសឯទៀត បើទៅដល់មុន យើងអាចចងសម្ព័ន្ធភាពជាមួយសាមន្តប្រទេសទាំងនោះ ហើយនឹងបានពួកគេជួយយកអាសា ទីនោះហៅថាដីប្រសព្វមុខ។ តំបន់ដីដែលចូលជ្រៅទៅក្នុងទឹកដីរបស់ខ្មាំង ដែលត្រូវឆ្លងកាត់បន្ទាយជំរំរបស់ទ័ពខ្មាំងជាច្រើន ហៅថាដីជម្រៅ (ពិសេស)។ តំបន់ដីដែលមានព្រៃភ្នំ ក្រមថ្ម បឹងបួ ផ្លូវពិបាកធ្វើដំណើរ ហៅថាដីឧបស័គ្គ។ តំបន់ដីដែលរុលទៅមុខ ផ្លូវនោះតូចចង្អៀត ដកថយ ផ្លូវនោះក្រវិចក្រវៀន ពួកខ្មាំងអាចប្រើចំនួនទ័ពតិចតួច ដើម្បីពួនស្ទាក់វាយប្រហារ មកលើទ័ពយើង ដែលមានចំនួនច្រើនបាន ហៅថាដីគ្រោះថ្នាក់ ឬដីហ៊ុមព័ទ្ធ។ តំបន់ដីដែលត្រូវតែស្រួតប្រញាប់ ត្រូវបញ្ចេញកម្លាំងអស់ពីសមត្ថភាព ដើម្បីប្រយុទ្ធជាមួយខ្មាំង ទើបមានផ្លូវរស់ បើមិនប្រយុទ្ធគឺត្រូវកំទេចត្រូវស្លាប់ ទីនោះ ហៅថាដីមរណៈ។

ហេតុនេះពេលស្ថិតនៅលើដីពង្រាយ មិនត្រូវបើក យុទ្ធនាការប្រយុទ្ធឡើយ។ ពេលស្ថិតនៅដីរាក់



www.elibraryofcambodia.org

មិនត្រូវជំអក់នៅយូរ។ ពេលស្ថិតនៅលើដីប្រជែង ត្រូវដណ្ដើមកាន់កាប់ឲ្យបានមុនខ្មាំង បើខ្មាំងកាន់កាប់បានមុន មិនត្រូវវាយលុក ដោយបង្ខំចិត្តនោះទេ។ ពេលស្ថិតនៅដីជំនួប កិច្ចការចាត់តាំងកងទ័ពចាំបាច់ត្រូវតភ្ជាប់គ្នា ការពារកុំឲ្យទ័ពខ្មាំងកាត់ផ្ដាច់ផ្លូវគមនាគមន៍ ។ ពេលស្ថិតនៅលើដីប្រសព្វមុខ ចាំបាច់ត្រូវចងសម្ព័ន្ធភាព ជាមួយសាមន្តប្រទេស។ ពេលចូលជ្រៅ ក្នុងតំបន់ដីជម្រៅ ត្រូវតែប្លន់ រឹបអូសសម្ភារៈ បរិក្ខារនៅ នឹងកន្លែងដើម្បីផ្គត់ផ្គង់កងទ័ព។ បើជួបតំបន់ដីឧបស័គ្គ ចាំបាច់ត្រូវប្រញាប់ឆ្លងកាត់ឲ្យផុតពីទីនោះ។ បើធ្លាក់ក្នុងតំបន់ដីគ្រោះថ្នាក់ (ដីហ៊ុមព័ទ្ធ) ត្រូវឈ្លាសវៃប្រើកលឧបាយសង្គ្រាម។ តែបើទៅដល់ដីមរណៈ គឺត្រូវហានក្លា ប្ដេជ្ញា ប្រយុទ្ធរកផ្លូវរស់ក្នុងការស្លាប់ ។ បុរាណជំនាញជាញជ័យសម័យដើម លោកអាចធ្វើឲ្យទ័ពខ្មាំងពុំអាចជួបគ្នាបាន រវាងទ័ពជួរមុខនិងជួរក្រោយ ពុំអាចពឹងផ្អែកគ្នាបាន រវាងកងទ័ពធំ និងកងទ័ពតូច ពុំអាចជួយគ្នាបានរវាង នាយទាហាននិងពលទាហាន ខាងលើ



www.elibraryofcambodia.org

ខាងក្រោមត្រូវបានកាត់ផ្តាច់ គ្មានមធ្យោបាយណា ដែលអាចតភ្ជាប់បាន ពលសេនា បែកខ្ញែក រាយ ប៉ាយ មិនអាចប្រមូលផ្តុំបាន ដូចនេះ ទោះជាប្រមូល ផ្តុំវិញ ក៏ច្របូកច្របល់វឹកវរដែរ។ ស្ថិតក្នុងលក្ខណៈ ដូច្នេះ ក៏ត្រូវរក្សាឲ្យបានរឹងមាំ នូវគោលការណ៍ដែល មានអំណោយផល ទើបចាប់ផ្តើមធ្វើសកម្មភាព។ កាលបើគ្មានអំណោយផល គឺត្រូវតែផ្អាកសិន។ សួរ ថា ប្រសិនបើទ័ពខ្មាំងមានចំនួនច្រើនលើសលប់ ប្រៀប នៃសមរភូមិទៀតសោត ក៏រឹងមាំ ហើយត្រៀមវាយ លុកមកលើយើង តើយើងត្រូវធ្វើយ៉ាងណា ដើម្បីទប់ ទល់វាបាន? សូមឆ្លើយថាៈ ដំបូងបង្អស់ត្រូវដណ្តើម កាន់កាប់ចំណុចសំខាន់របស់ទ័ពខ្មាំង។ ធ្វើបាន ដូច្នេះ ខ្មាំងត្រូវតែបង្ខំចិត្តស្តាប់បញ្ជា តាមការត្រឹកញាក់ របស់យើង។ វិធីបញ្ជាទ័ពត្រូវតែរហ័សរហួន ឆ្លៀត ឱកាសដែលខ្មាំងរើខ្លួនមិនទាន់ រុលដំណើរទៅមុខ តាមផ្លូវ ដែលខ្មាំងមិននឹកស្មានដល់ វាយប្រហារ កន្លែងដែលខ្មាំងគ្មានការការពារ។ គោលការណ៍ បញ្ជាទ័ពប្រយុទ្ធ ពេលដែលសម្រុកចូលទៅក្នុងទឹក



www.elibraryofcambodia.org

ដីរបស់ខ្មាំងគឺ ៖ កាន់តែចូលជ្រៅក្នុងទឹកដីខ្មាំងប៉ុណ្ណា កាន់តែត្រូវរក្សាទឹកចិត្តកងទ័ព ឲ្យមានការឯកភាពខ្ពស់បំផុតប៉ុណ្ណោះ ហើយទ័ពខ្មាំង ក៏កាន់តែពិបាកវាយប្រហារយើងបានដែរ។ ពេលជួបទីកន្លែងដែលសម្បូរភោគផល គឺត្រូវរឹបអូសស្បៀងបរិក្ខារ ធ្វើឲ្យកងទ័ពទាំងមូល ទទួលបានការផ្គត់ផ្គង់យ៉ាងគ្រប់គ្រាន់ បរិបូរ ត្រូវយកចិត្តទុកដាក់ដល់ការឲ្យកងទ័ពបានឈប់សម្រាក មិនត្រូវទុកឲ្យកងទ័ពនឿយហត់ហួសពេក លើកកំពស់ទឹកចិត្ត សម្រិតសម្រាំងកម្លាំងប្រយុទ្ធ ចាត់តាំងកងទ័ព រៀបចំដាក់គម្រោងផែនការល្អៗ ដើម្បីធ្វើឲ្យទ័ពខ្មាំងមិនអាចប៉ាន់ស្មានបាន។ ដាក់កងទ័ពស្ថិតក្នុងស្ថានភាព ដែលគ្មានជម្រើស គ្មានផ្លូវណាផ្សេង ក្រៅពីការដែលថាទោះជាស្លាប់ ក៏មិនដកថយ ដោយសារតែបរាជ័យនោះដែរ ពេលដែលពលសេនាគិតថាទោះជាត្រូវស្លាប់ក៏មិនខ្លាចនោះ ពេលនោះគឺទាំងថ្នាក់លើ ថ្នាក់ក្រោម ទាំងមេ ទាំងកូន នឹងបញ្ចេញកម្លាំងអស់ពីសមត្ថភាពខ្លួន ដើម្បីប្រយុទ្ធ។ សេនា ទាហាន ពេលចូលជ្រៅ



www.elibraryofcambodia.org

ក្នុងសភាព គ្រោះថ្នាក់ ពួកគេនឹងមិនមានការភ័យខ្លាចអ្វីទៀតឡើយ ព្រោះគ្មានផ្លូវណាផ្សេងដែលត្រូវទៅ។ ទឹកចិត្តកងទ័ព នឹងក្លាយជារឹងមាំ ពេលចូលជ្រៅទៅក្នុងទឹកដីរបស់ខ្មាំង សកម្មភាពនឹងមិនមានការបែកខ្ញែកទៀតឡើយ ត្រូវជំរុញចូលក្នុងភាពមិនមានជម្រើស ពួកគេនឹងប្រថុយស្លាប់ ដើម្បីប្រយុទ្ធជាដាច់ខាត។ ហេតុនេះ សម្រាប់កងទ័ពដូចនេះ មិនចាំបាច់កែទម្រង់ផ្ទៃក្នុង ក៏ពួកគេចេះបង្កើត ការប្រុងប្រយ័ត្នខ្លួន ដោយខ្លួនឯងដែរ។ មិនចាំបាច់ទាមទារ ក៏ពួកគេបញ្ចេញកម្លាំងអស់ពីខ្លួន ដើម្បីប្រយុទ្ធដែរ។ មិនចំបាច់បង្ខិតបង្ខំ ក៏ពួកគេចេះជួយគ្នា ទៅវិញទៅមក ដោយភាពស្និទ្ធស្នាលទៀតផង។ មិនបាច់រិតបន្តឹងក្រឹត្យវិន័យ ក៏ពួកគេចេះគោរពវិន័យដោយខ្លួនឯងដែរ។ ហាមប្រាមដាច់ខាត នូវរាល់អបិយជំនឿផ្សេងៗ លប់បំបាត់ភាពមន្ទិលសង្ស័យក្នុងជួរកងទ័ព ទោះជាពួកគេត្រូវ ពលីជីវិតក៏ពុំ រត់ចោលជួរដែរ។ សេនាទាហានរបស់កងទ័ពយើងពុំមាន ប្រាក់កាសទ្រព្យសម្បត្តិច្រើន នោះពុំមែនពួកគេស្អប់ខ្ពើមលុយ



www.elibraryofcambodia.org

ទេ សេនាទាហានរបស់កងទ័ពយើង មិនចង់រស់ មិនខ្លាចស្លាប់ នោះ ពុំមែនពួកគេមិនចង់បានអាយុ វែងទេ។ ក្នុងពេលបទបញ្ជាប្រយុទ្ធដែលបានដាក់ចេញ ពួកសេនាទាហាន ដែលកំពុងអង្គុយ គេបង្ហូរទឹកភ្នែកទទឹកជោកអាវ ពួកទាហានដែលកំពុងដេកឯណោះវិញ ទឹកភ្នែកហូរសស្រាក់ ជោកថ្ពាល់។ ក្នុងពេលដែលដាក់ពួកគេស្ថិតក្នុងស្ថានភាព ដែលពុំមានផ្លូវជ្រើសរើស គេត្រូវតែប្រយុទ្ធយ៉ាងក្លាហានជាដាច់ខាត។

ហេតុនេះ អ្នកដែលពូកែបញ្ជាទ័ពប្រយុទ្ធ ប្រៀបដូចសត្វពស់នៅភ្នំឆាង គឺប្រយុទ្ធទាំងក្បាល ទាំងកន្ទុយ។ ពេលវាយចំក្បាល កន្ទុយវាបកមកជួយ ពេលវាយចំកន្ទុយ ក្បាលវាងាកមកចឹក កាលបើវាយចំពាក់កណ្តាលខ្លួន ទាំងក្បាល ទាំងកន្ទុយ បកមករកទាំងព្រម។ សំណួរសួរថា "អាចធ្វើឲ្យកងទ័ពក្លាយទៅជាសត្វពស់ក្បាលពីរ ដូចខាងលើបានដែរឬទេ?"។ សូមឆ្លើយថា "*បាន*" ។



www.elibraryofcambodia.org

អ្នកនគរ*ហ្គោ* និងនគរ*យៀក* ចងគំនុំសត្រូវសូវ ពូជនឹងគ្នា ក៏ប៉ុន្តែ មានពេលមួយ ពួកគេបានជិះទូក ជាមួយគ្នាឆ្លងព្រែក ចៃដន្យជួបខ្យល់បក់ រលកធំ ពួកគេនៅតែជួយសង្គ្រោះគ្នាទៅវិញទៅមក មិនខុស អីពីដៃឆ្វេងនិងដៃស្តាំ របស់មនុស្សយ៉ាងដូច្នេះឯង។ ដូច្នេះ ការដែលចង់យកខ្សែចងសេះឲ្យជាប់ ជីក បង្កប់កង់រថសឹកទៅក្នុងដី ដើម្បីស្តែរភាពកងទ័ពកុំ ឲ្យរត់ចោលជួរនោះ ពុំប្រាកដថានឹងធ្វើបានឡើយ។ ចង់ឲ្យកងទ័ពមានការឯកភាព ចិត្តមួយថ្លើមមួយ ក្លាហានក្នុងការប្រយុទ្ធ គឺស្ថិតនៅត្រង់ការចាត់តាំង បញ្ជាការពូកែ។ ចង់ឲ្យ ទាំងអ្នកខ្លាំងទាំងអ្នកខ្សោយ បញ្ចេញអស់កម្លាំងកាយចិត្តរបស់ខ្លួន ត្រូវចេះទាញ យកភាពជាអំណោយផលពីសមរភូមិ និងកត្តាជ័យ ភូមិសមស្រប មកបម្រើ ឲ្យការបញ្ជាប្រយុទ្ធ។ ហេតុ នេះ អ្នកដែលពូកែដឹកនាំទ័ពប្រយុទ្ធ បញ្ជាមហាទ័ព ក៏ងាយ ដូចជាបញ្ជាមនុស្សម្នាក់អ៊ីចឹងដែរ។ ប្រការ នោះ គឺព្រោះតែ គេមិនអាចមិនដូច្នោះបានឡើយ។ អ្នកជាមេទ័ព ពេលដែលមានជំណោះស្រាយ ត្រូវ



www.elibraryofcambodia.org

រក្សាភាពនឹងន ភាពជ្រាលជ្រៅ ដែលពិបាកនឹងស្មានត្រូវពីអ្នកដទៃ។ គ្រប់គ្រងកងទ័ពដោយស្មើភាព ហើយប្រកបដោយស្មារតីរឹងប៉ឹង ម៉ឺងម៉ាត់ជានិច្ច។ គេអាចបំបិទភ្នែកញ៉ុកត្រចៀក សេនាទាហាន ធ្វើឲ្យពួកគេមិនយល់ដឹងអ្វីទាំងអស់អំពីផែនការយោធា ឬផ្លាស់ប្តូរភារកិច្ច ផ្លាស់ប្តូរផែនការ ធ្វើឲ្យអ្នកទាំងឡាយ មិនមានវិធីណា ដើម្បីយល់បានច្បាស់ អំពីអាថ៌កំបាំងរបស់យុទ្ធសាស្ត្រផ្លាស់ប្តូរទីតាំងឈរជើង ធ្វើដំណើរដោយផ្លូវក្រវិចក្រវៀនកេលកុង ដើម្បីធ្វើឲ្យអ្នកទាំងឡាយ មិនអាចយល់បានគោលគំនិតកលឧបាយប្រយុទ្ធដែលយើងបម្រុងដាក់ចេញ។ មេទ័ពប្រគល់ភារកិច្ចឲ្យកងទ័ព ប្រៀបដូច ការដើរឡើងលើទីខ្ពស់ រួចហើយហូតជណ្តើរចេញយ៉ាងនោះឯង។ ធ្វើឲ្យពួកគេមានតែរុលទៅមុខ មិនអាចបកក្រោយបាន។ នាំទ័ពចូលជ្រៅទៅក្នុងទឹកដីរបស់សាមន្តប្រទេស បីដូចយឺតតំឡើងធ្នូដែលបាញ់ព្រួញចេញទៅយ៉ាងដូច្នោះដែរ ធ្វើឲ្យវាដឹងតែពីហោះទៅមុខម៉្យាងគត់។ ដុតសំពៅចោល វាយបំបែកឆ្នាំង



www.elibraryofcambodia.org

បាយ ដើម្បីសម្តែងការប្តេជ្ញាចិត្តស៊ូស្លាប់ ដើម្បីប្រយុទ្ធ ប្រៀបដូចជាការកៀងសត្វពពែមួយហ្វូងអ៊ីចឹង កៀងមកកន្លែងនេះ រួចកៀងទៅកន្លែងផ្សេង ដើម្បីធ្វើឲ្យវាពុំដឹង ថាយើងដេញវាទៅណា។ ប្រមូលផ្តុំកងទ័ពទាំងមូលមក រួចដាក់ពួកគេក្នុងស្ថានភាពគ្រោះថ្នាក់មួយ ឲ្យពួកគេប្រថុយស្លាប់ ដើម្បីប្រយុទ្ធ នោះជានាទីភារកិច្ចរបស់មេទ័ព។ យោងទៅ លើយុទ្ធភូមិផ្សេងគ្នា ដើម្បីសម្របស្ថានភាព អាចបន្ធូរបន្ថយតាមភាពជាក់ស្តែង ក្តាប់ឲ្យបានច្បាស់រាល់បាតុភាពចិត្តទាំងគ្រប់រូបបុគ្គល សុទ្ធសឹងតែជាកិច្ចការរបស់មេទ័ព ដែលត្រូវ ពិនិត្យ សិក្សាយ៉ាងហ្មត់ចត់ដោយខានពុំបាន។ ជាទូទៅ គោលការណ៍នៃយុទ្ធនាការសឹក ពេលចេញផុតពីទឹកដីខ្លួន ចូលជ្រៅទៅក្នុងទឹកដីខ្មាំង សេនាទាហានកាន់តែមានការឯកភាព ទឹកចិត្តប្រយុទ្ធកាន់តែខ្ពស់។ ចូលកាន់តែរាក់ កាន់តែងាយមានការរត់ចោលជួរ។ ចាកចេញពីទឹកដីខ្លួនសម្រុកចូលទៅក្នុងទឹកដីខ្មាំងដើម្បីប្រយុទ្ធ នោះគឺជាដីដាច់ស្រយាល ចំណែកនៅយុទ្ធភូមិ ដែលមាន



www.elibraryofcambodia.org

គមនាគមន៍ងាយស្រួល នោះគឺដីប្រសព្វមុខសម្រុក ចូលជ្រៅក្នុងទឹកដីខ្មាំងនោះគឺដីជម្រៅ ចូលទៅតែនៅ រាក់ហៅថាដីរាក់ ចូលជ្រៅឧបស័គ្គ ខាងមុខចង្អៀត គឺដីគ្រោះថ្នាក់ គ្មានកន្លែងណាត្រូវទៅបានទៀត គឺដីមរណៈ។ ហេតុនេះ ស្ថិតក្នុងដីពង្រាយត្រូវធ្វើឲ្យកងទ័ពមានឆន្ទៈ ឯកភាពខ្ពស់ នៅទីដីរាក់ ត្រូវរក្សាឲ្យកងទ័ពតភ្ជាប់គ្នាមុខក្រោយ ជួបដីប្រជែង ត្រូវសម្រុកទៅមុខឲ្យលឿន បិទគួចទ័ពខ្មាំង ជួបដីជំនួប ត្រូវប្រុងប្រយ័ត្ន ការពារ នៅដីប្រសព្វមុខ ត្រូវបង្កើនទំនាក់ទំនងការទូតជាមួយប្រទេស ភូមិផង ដែលស្ថិតលើដីជម្រៅ ត្រូវធានាការផ្គត់ផ្គង់ស្បៀង ឲ្យកងទ័ពកុំឲ្យដាច់ មកដល់ដីឧបស័គ្គ ត្រូវប្រញាប់ឆ្លងកាត់ឲ្យផុត ចូលមកដីគ្រោះថ្នាក់ (ដីហ៊ុមព័ទ្ធ) ត្រូវបិទជិតកន្លែងចន្លោះ ធ្លាក់ក្នុងដីមរណៈ ត្រូវស៊ូប្តូរស្លាប់ដើម្បីប្រយុទ្ធ។ បាតុភាពចិត្តសាស្ត្រពលទាហាន ពេលត្រូវហ៊ុមព័ទ្ធ នឹងបញ្ចេញកម្លាំងតទល់ ពេលអស់ជម្រើស នឹងស៊ូស្លាប់ដើម្បីប្រយុទ្ធ ពេលជួបគ្រោះអាសន្ន ចេះគោរពបទបញ្ជារបស់មេ។ ហេតុនេះ បើ



www.elibraryofcambodia.org

មិនយល់ទិសដៅ យុទ្ធសាស្ត្ររបស់សាមន្តប្រទេស មិនត្រូវចងសម័ន្ធភាពជាមួយទេ។ មិនយល់ភូមិសាស្ត្រ ដូចជាព្រៃភ្នំ ទីតាំងដែលជាឧបស័គ្គ បឹងបួជាដើម គឺ មិនអាចប្រតិបត្តិការសឹកបានឡើយ។ មិនប្រើប្រាស់ អ្នកនាំផ្លូវ មិនទទួលបានភាពអំណោយផលពីជ័យ ភូមិ ។ សម្រាប់គុណប្រយោជន៍ គុណវិបត្តិ នៃ សណ្ឋាន ដី៩យ៉ាងខាងលើ បើនៅមានចំណុចណា មួយមិនទាន់យល់ ដឹងបានច្បាស់ទេនោះ គឺមិនអាច ក្លាយជាកងទ័ព នៃព្រះរាជា ចក្រព័ត្តិបានឡើយ។ កងទ័ពនៃមហាចក្រពត្តិពេលវាយលុក មហាប្រទេស ណាមួយ អាចធ្វើឲ្យទាំងកងទ័ពទាំងប្រជារាស្ត្រ ប្រទេសនោះ ពុំអាចកេណ្ឌ ប្រមែបែមូលកម្លាំងទ័ព ឲ្យទាន់ពេលបានឡើយ។ កម្លាំងប្រៀបវាយលុក សង្គ្រប់ទៅលើក្បាលទ័ពខ្មាំង ធ្វើឲ្យវាពុំអាចចង សម្ព័ន្ធជាមួយប្រទេស ផ្សេងបាន។ ហេតុដូច្នេះ មិន ចាំបាច់ត្រូវចងសម្ព័ន្ធភាព ជាមួយប្រទេសដទៃណា មួយនោះទេ ហើយក៏មិនចាំបាច់រក្សាអំណាចរបស់ ខ្លួននៅប្រទេសនោះផងដែរ ។ គ្រាន់តែពឹងផ្អែកលើ



www.elibraryofcambodia.org

កម្លាំងរបស់ខ្លួន ប្រើប្រាស់កម្លាំងនិងអំណាចទាំងនោះ គ្របសង្កត់ទៅលើក្បាលខ្មាំង គឺអាចរុករានទន្ទ្រាន ដណ្ដើមក្រុងនគររបស់ខ្មាំង កំទេចប្រទេសរបស់ពួកគេបានហើយ។ អនុវត្តការលើកទឹកចិត្ត ប្រទានរង្វាន់ឲ្យហួសពីកម្រិតធម្មតា ចេញប្រកាសរាល់បទបញ្ជាខុសប្លែកពីធម្មតា បញ្ជាកងទ័ពដែលមានកម្លាំងច្រើន ប្រៀបដូចបញ្ជាមនុស្សម្នាក់យ៉ាងនោះឯង បញ្ជាពួកគេឲ្យទៅទទួលភារកិច្ច មិនចាំបាច់និយាយប្រាប់ពីហេតុផលនោះទេ ប្រើពួកគេឲ្យទៅរឹបអូសយកផលប្រយោជន៍ ក៏មិនចាំបាច់ប្រាប់ពីភាពគ្រោះថ្នាក់នោះដែរ។ ដាក់កងទ័ពស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ទើបអាចរក្សាបានភាពគង់វង់និត្យនៅ។ ធ្វើឲ្យពួកពល នាយសេនា ធ្លាក់ក្នុងដីមរណៈ ទើបរក្សាបានអាយុជីវិតរស់រាន។ ពេលពួកពល នាយសេនា ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ទើបពួកគេខិតខំដណ្ដើមយកជ័យជម្នះ។ ដូច្នេះ ក្នុងការបញ្ជាទ័ពប្រយុទ្ធមានពេលខ្លះ ធ្វើហាក់ដូចជា បណ្ដោយតាមកលឧបាយរបស់ខ្មាំង លុះដល់ពេលមានឱកាស ល្អភ្លាមនោះ គឺ



www.elibraryofcambodia.org

ត្រូវប្រមូលផ្តុំកងកម្លាំងទ័ពជាបន្ទាន់ ដើម្បីវាយលុក ឆ្ពោះទៅចំទីតាំងទ័ពខ្មាំង ដេញតាមសម្លាប់ និងចាប់ទាំងរស់មេទ័ពរបស់ខ្មាំងឲ្យខានតែបាន ទោះចម្ងាយរាប់យោជន៍ក៏ដោយ។ ប្រការនោះហៅថាភាពឈ្លាសវៃ គឺអាចធ្វើកិច្ចការធំបាន។ អាស្រ័យហេតុនេះ ពេលមានការសម្រេចចិត្ត ធ្វើសកម្មភាពសង្គ្រាម គឺត្រូវបិទច្រកព្រំដែនចេញចូលទាំងអស់ លប់បំបាត់ក្រដាសស្នាមលិខិតឆ្លងដែន ផ្អាកកិច្ចការទូតជាមួយខ្មាំង វិលមកអង្គុយក្នុងពន្លាជ័យ គិតការយោធា ពិគ្រោះកលយុទ្ធ សម្រេចកំណត់យុទ្ធសាស្ត្រ។ រាល់ការខ្វះចន្លោះណាមួយរបស់ទ័ពខ្មាំង ក៏ត្រូវរហ័សដៃរហ័សជើង ឆ្លៀតឱកាសដើម្បីជ្រៀតចូល។ ដំបូង គេត្រូវដណ្តើមកាន់កាប់គ្រប់រាល់ចំណុចជា យុទ្ធសាស្ត្ររបស់ទ័ពខ្មាំង ប៉ុន្តែ មិនត្រូវប្រថុយប្រថានណាត់ពេលប្រយុទ្ធជាមួយពួកគេ ពេលអនុវត្តផែនការ ត្រូវយោង ទៅតាមស្ថានភាពជាក់ស្តែង របស់ទ័ពខ្មាំង ដែលមានការផ្លាស់ប្តូរ យើងនឹងធ្វើការផ្លាស់ប្តូរតាមឲ្យសមស្រប។ ការសម្រេច ធ្វើសកម្មភាពយោធា



www.elibraryofcambodia.org

ត្រូវប្រកបដោយភាពវាងវៃ។ ហេតុនេះ ពេលដែលសង្គ្រាមមិនទាន់ផ្ទុះ គេត្រូវស្ងប់ស្ងៀមនឹងធឹងប្រៀបដូចស្រីទើបពេញក្រមុំចូលម្លប់ មិនបញ្ចេញឥរិយាបថកាយវិការអ្វីទាំងអស់ ដើម្បីធ្វើឲ្យខ្មាំងបណ្ដែតបណ្ដោយ ក្នុងការការពារ។ ក្រោយពេលសង្គ្រាមផ្ទុះឡើង ចាំបាច់ត្រូវលឿន រហ័សដូចសត្វទន្សាយរួចពីអន្ទាក់ សកម្មភាពមហាល្បឿន ធ្វើឲ្យទ័ពខ្មាំងមិនអាចទប់ទល់បានទាន់។



www.elibraryofcambodia.org

# ជំពូកទី១២
# វាយលុកដោយប្រើកម្លាំងភ្លើង

**ស៊ុនជឺ** និយាយថា៖

ការវាយប្រហារដោយប្រើភ្លើង មានប្រាំយ៉ាងគឺ ៖

ទីមួយ : ប្រើភ្លើង ដុតសម្លាប់មនុស្ស និងសេះរបស់ទ័ពខ្មាំង។

ទីពីរ : ប្រើភ្លើងដុតកំទេច ស្បៀង សម្ភារៈ ឃ្លាំងបម្រុងរបស់ខ្មាំង។

ទីបី : ប្រើភ្លើង ដុតកំទេចរថដឹកជញ្ជូន និង ឧបករណ៍សម្ភារៈ សំពីងសំពោង របស់ខ្មាំង។

ទីបួន : ប្រើភ្លើង ដុតកំទេចឃ្លាំងអាវុធ របស់ទ័ពខ្មាំង។ និង

ទីប្រាំ : ប្រើភ្លើង ដុតកំទេចផ្លូវដឹកជញ្ជូន ស្បៀងរបស់ទ័ពខ្មាំង។

ចង់អនុវត្តការវាយប្រហារដោយប្រើភ្លើង ត្រូវមានគ្រប់កត្តាចាំបាច់មួយចំនួន។ គ្រឿងចំហេះអំពីភ្លើងត្រូវមានគ្រប់គ្រាន់ជានិច្ច។ ចង់បង្ហោះភ្លើង ត្រូវ



www.elibraryofcambodia.org

មើលមេឃ មើលខ្យល់អាកាស ចង់បញ្ឆេះភ្លើងត្រូវរើសម៉ោងអំណោយផល ។ មេឃឱកាស គឺធាតុអាកាស មេឃរាំងស្ងួត ឬម៉ោងពេល គឺចង់និយាយថាពេលដែលព្រះច័ន្ទ្រ គោចរដល់ក្នុងវង្វង់ *ផ្កាយអា ស្ទីទែរ ផ្កាយអាល់ហ្វាក៏ត ផ្កាយអ៊ី និងផ្កាយឆេន* ធម្មតា ពេលព្រះច័ន្ទ្រធ្វើដំណើរគោចរ មកដល់កន្លែងផ្កាយទាំងបួន នោះ គឺមេឃនឹងមានខ្យល់បក់បោកខ្លាំង ។ ធម្មតា ការវាយប្រហារដោយប្រើភ្លើងត្រូវផ្អែកទៅលើ ស្ថានភាពវាយលុក ដូចដែលបានថែងទាំងប្រាំយ៉ាងខាងលើ ដើម្បីប្រើប្រាស់កម្លាំងទ័ពជំនួយទាន់ពេលវេលា ។ បង្ហោះភ្លើងពីក្នុងបន្ទាយជំរំរបស់ខ្មាំង គឺត្រូវចាត់កម្លាំងទ័ពជំនួយពីក្រៅជាបន្ទាន់។ ពេលឃើញភ្លើង បានឆេះហើយ តែទ័ពខ្មាំងនៅតែរក្សាភាពស្ងៀមស្ងាត់ ត្រូវពិនិត្យ អង្កេត ហើយរង់ចាំមិនត្រូវប្រញាប់វាយលុកភ្លាមនោះទេ ។ រង់ចាំដល់ពេលភ្លើងឆេះខ្លាំងពេញចំហោះ ហើយពិនិត្យមើលស្ថានភាព បើឃើញថាវាយលុកបានគឺវាយ តែបើមិនបាន គឺត្រូវផ្អាក។ ក៏អាចបង្ហោះភ្លើងពីក្រៅចូល



www.elibraryofcambodia.org

ក្នុងករណីនោះ មិនចាំបាច់រង់ចាំរនុកក្នុងជួយទេ គ្រាន់តែឃើញថាដល់ពេលសមស្រប គឺបង្ហោះភ្លើងតែម្តង។ ដុតភ្លើងពីខាងលើខ្យល់ មិនត្រូវវាយលុកពីក្រោមខ្យល់ ។ ពេលថ្ងៃ បើមានខ្យល់អូសបន្លាយយូរ គឺពេលយប់មេឃនឹងត្រូវស្ងប់ខ្យល់ ។ កងទ័ពចាំបាច់ត្រូវចេះអនុវត្តយ៉ាងឈ្លាសវៃ នូវរបៀបវាយលុកដោយកម្លាំងភ្លើងទាំងប្រាំយ៉ាងខាងលើ រង់ចាំដល់ពេលគ្រប់លក្ខណៈចាំបាច់ ទើបបង្ហោះភ្លើងវាយលុក។ ប្រើកម្លាំងភ្លើងវាយប្រហារ ដើម្បីជំនួយឲ្យកម្លាំងវាយលុកលទ្ធផលនឹងច្បាស់ក្រឡែត ។ ប្រើកម្លាំងទឹកវាយប្រហារ ដើម្បីជំនួយឲ្យការវាយលុក កម្លាំងប្រៀបនឹងកើនខ្លាំងក្លាឥតគណនា ។ ទឹកអាចកាត់ផ្តាច់ ធ្វើឲ្យទ័ព ខ្មាំងដាច់បាត់ទំនាក់ទំនងជាមួយគ្នា ប៉ុន្តែ ពុំអាចរឹបអូសយកសម្ភារៈ ។ ធម្មតា ពេលជោគជ័យសមរភូមិប្រយុទ្ធ រឹបអូសដីធ្លី ក្រុងនគរ តែមិនបានផ្តល់រង្វាន់ ដល់អ្នកដែលមានគុណបំណាច់ទាន់ពេលទេនោះ ប្រាកដជានឹងកើតគ្រោះ អាសន្នពុំលែងឡើយ នោះហើយហៅថា ការពន្យាចំណាយ



www.elibraryofcambodia.org

ពន្យាការខាតបង់។ ដូចនេះដើម្បីអាចក្លាយ " ជាព្រះរាជាក្លឺស្វាង " នៃប្រទេសមួយ ចាំបាច់ត្រូវមានភាពហ្មត់ចត់ ពិចារណាបញ្ហានេះ បើមិនមានប្រយោជន៍ មិនធ្វើសកម្មភាព បើមិនប្រាកដឈ្នះ មិនបញ្ជាទ័ពប្រយុទ្ធ បើមិនជាភាពបន្ទាន់ គឺមិនបើកយុទ្ធនាការ។ ស្តេចប្រទេសមួយ មិនដើម្បីការក្រេវក្រោធក្នុងខណៈមួយ ហើយកៀងពលទៅធ្វើសឹកសង្គ្រាម មេទ័ពនាយទាហាន ក៏មិនដើម្បីតែការខឹងសម្បារ ហើយក៏បញ្ជាទ័ពចេញប្រយុទ្ធនោះដែរ ។ សម្រាប់ប្រទេសជាតិមានប្រយោជន៍ ទើបធ្វើសកម្មភាព សម្រាប់ផលប្រយោជន៍របស់ប្រទេសជាតិ ទើបធ្វើសកម្មភាព បើមិនមាន ផលប្រយោជន៍ទេនោះគឺផ្អាក ។ ភាពខឹងសម្បារ អាចឆ្លងផុតទៅបាន ភាពសប្បាយរីករាយនឹងត្រឡប់មក ភាពក្រេវក្រោធអាចអស់ទៅ ដើម្បីវិលមកកាន់ភាពសប្បាយរីករាយ ។ ប៉ុន្តែ បើប្រទេសជាតិត្រូវបាត់ គឺពុំអាចស្តារឡើងវិញបានទេ មនុស្សដែលស្លាប់ហើយ ក៏ពុំអាចរស់ឡើងវិញបានដែរ ។ ហេតុនេះ ក្នុងនាមជាព្រះរាជាមួយ



www.elibraryofcambodia.org

អង្គ ចាំបាច់ត្រូវមានភាពអំណត់ហ្មត់ចត់ ក្នុងបញ្ហានោះ នាយទាហានមួយរូប ក៏ត្រូវហ្មត់ចត់ ចំពោះបញ្ហានោះដែរ ។ ប្រការនោះហើយ គឺជាមូលដ្ឋាននៃគុណធម៌ ដើម្បីរក្សាឲ្យប្រទេសជាតិមាន ស្នេហភាពគង់វង្ស រក្សាឲ្យកងទ័ពមានសុវត្ថិភាព ។



www.elibraryofcambodia.org

# ជំពូកទី១៣
# ការប្រើចារបុរស

**ស៊ុនជឺ** និយាយថា៖

ធម្មតា ពេលលើកទ័ពរាប់រយពាន់នាក់ ដោយធ្វើដំណើរផ្លូវឆ្ងាយរាប់ពាន់យោជន៍ ការខាតបង់របស់ប្រជារាស្ត្រ ការចំណាយរបស់ប្រទេសជាតិមួយថ្ងៃៗ ចាយរាប់ពាន់ត្រណោតមាស ពាសពេញទាំងប្រទេស ក្នុងក្រុង ក្រៅក្រុង កើតកលយុគច្របូកច្របល់មិនឈប់ឈរ។ ក្រុមតិតការងារដឹកជញ្ជូន យុទ្ធោបករណ៍ បរិក្ខារ កងទ័ពនឿយហត់លើគ្រប់ដងផ្លូវ ចំនួនគ្រួសារនៃប្រជារាស្ត្រ ដែលពុំអាចតិតគូរការងារបង្កបង្កើនផលឡើងដល់ ៧៦% នៃចំនួនគ្រួសារសរុបទូទាំងប្រទេស ។ ភាគីចម្បាំងខំប្រទង់ប្រទាញ ក្នុងសឹកសង្គ្រាមដ៏រ៉ាំរ៉ៃ អូសបន្លាយពេលវេលារាប់ឆ្នាំ ក៏ព្រោះតែត្រៀមយកឈ្នះក្នុងមួយថ្ងៃ ។ កាលបើរិះកំណាញ់ចំពោះផ្តេកបុណ្យស័ក្តិ ប្រាក់កាស ពុំហ៊ាន



www.elibraryofcambodia.org

ប្រើប្រាស់ចារកម្មទេនោះ នឹងនាំទៅដល់សភាព ដោយមិនយល់ដឹងបានពីស្ថានការខ្មាំង ហើយត្រូវទទួលបរាជ័យ នោះហើយ គឺពិតជាអមនុស្សធម៌ខ្លាំងពេកណាស់។ មេទ័ព នាយទាហាន ដូចនេះ មិនមែនជានាយទាហានល្អរបស់កងទ័ព មិនមែនជាជំនួយការល្អរបស់ព្រះរាជា ព្រះរាជាដូចនេះ ពុំមែនជាព្រះរាជាពូកែជំនាញជាញ ជ័យក្នុងសមរភូមិប្រយុទ្ធ។ ព្រះរាជាមួយអង្គ មេទ័ពមួយរូប ដែលល្អហើយពូកែ ដែលថាឲ្យតែចេញក្បួនទ័ព គឺឈ្នះមារសត្រូវគ្រប់ទិសទី ។ ភាពជោគជ័យលើសលប់ គ្មានគូប្រៀប ហួសពីអ្នកដទៃនោះ គឺស្ថិតនៅត្រង់កន្លែងដែលគេអាចដឹងបានសព្វរាល់កិច្ចការសារពើ មុនពេលគេធ្វើសកម្មភាព ។ ចង់ដឹងបានសព្វគ្រប់នូវរាល់ស្ថានភាព មិនអាចប្រើវិធីបែ បន់ បញ្ជាន់អារក្សអ្នកតា ខ្មោចព្រាយ បីសាច មិនអាចជឿផ្អែកទៅលើហោរាគុណគូរ ក្បួនអត្ថៈ រួចហើយវិភាគទៅជា រឿងអាក្រក់-ល្អនោះទេ ហើយក៏ពុំអាចប្រើវិធីអង្កេតមើលការធ្វើដំណើរគោចរ និងទីតាំងព្រះអាទិត្យ ព្រះច័ន្ទ



www.elibraryofcambodia.org

និង ពពួកហ្វូងតារា ដើម្បីកំណត់ជាព័ត៌មានពិត យកជាសាច់ការបាននោះដែរ ប៉ុន្តែ កិច្ចការនេះជាច់ខាតត្រូវបានមកពីមនុស្ស ដោយមនុស្សឈ្វេងយល់ស្ថានភាពខ្មាំង ទើបនឹងអាចដឹងបាន ។ ការប្រើចារបុរសអ្នកស៊ើបការសម្ងាត់ធម្មតា មានប្រាំប្រភេទគឺ ៖ ជនបទចារបុរស រនុកក្នុងចារបុរស ប្រតិកម្មចារបុរស មរណៈចារបុរស និងជីវិនចារបុរស។

កាលបើចារកម្មទាំងប្រាំប្រភេទនោះ ត្រូវបានប្រើប្រាស់ព្រមគ្នាហើយនឹងធ្វើឲ្យខ្មាំង មិនអាចយល់ដឹង និងពុំមានផ្លូវណា ស្ទង់ស្ទាបពីយើងបាននោះប្រការនេះហើយ ដែលហៅថា *"ទេពមន្ត"* គឺជាវេទមន្តដ៏វិសេសវិសាលដើម្បីព្រះ រាជាណាចក្រ ត្រៀមលក្ខណៈយកឈ្នះក្នុងសឹកសង្គ្រាម។

ជនបទចារបុរស បានដល់ចារបុរសដែលជាអ្នកស្រុកជនបទរស់នៅប្រទេសខ្មាំង។ រនុកក្នុងចារបុរសបានដល់ ពពួកបុគ្គលិក មន្ត្រីរាជការ របស់ប្រទេសខ្មាំងត្រូវបានយើងទិញយកធ្វើជាចារបុរសរបស់យើង។ ប្រតិកម្មចារបុរស ចារបុរសរបស់ខ្មាំង បញ្ជូនមក



www.elibraryofcambodia.org

យកព័ត៌មាន ស៊ើបការសម្ងាត់ពីយើង តែត្រូវយើងទិញក្បាលបាន ឲ្យធ្វើចារបុរសឲ្យយើង យកព័ត៌មានពីខ្មាំងត្រឡប់មកវិញ ។ មរណចារបុរស គឺពួកចារបុរសរបស់យើងបញ្ជូនទៅប្រទេសខ្មាំង ហើយយើងមានចេតនាធ្វើឲ្យបែកធ្លាយ នូវព័ត៌មានក្លែងក្លាយ ព័ត៌មានជាអកុសលណាមួយ ឲ្យចារបុរសយើងនោះទទួលបាន នៅពេលធ្វើបេសកកម្មត្រូវខ្មាំងចាប់បាន គេនឹងបង្ខំចិត្តឆ្លើយនូវព័ត៌មាន សម្ងាត់ក្លែងក្លាយទាំងនោះ ពេលនោះខ្មាំងនឹងសម្លាប់មន្ត្រីខ្លួន ដែលខ្លួនសង្ស័យនិងចារបុរសយើង ដែលខ្មាំងចាប់បាននោះតែម្តង ។ ជីវិនចារបុរស គឺមនុស្សដែលបញ្ជូនទៅប្រទេសខ្មាំង ដើម្បីស៊ើបការសម្ងាត់ពីស្ថានភាពខ្មាំង តែគេជាអ្នក អាចដើរហើរដោយសេរី ហើយនៅរស់រានមានជីវិត នឹងវិលត្រឡប់មកវិញរាយការណ៍ដោយសុវត្ថិភាព ។ ដូចនេះ បើនិយាយពីសមាសភាពក្នុងជួរកងទ័ព គ្មាននរណាស្និទ្ធស្នាល ជាជាងចារបុរស (ចារកម្មយោធា) នេះឯង រីឯការផ្តល់រង្វាន់លាភសក្ការៈ ក៏គ្មាននរណាទទួលបានពិសេសជាង



www.elibraryofcambodia.org

ពួកចារបុរសនេះដែរ ។ ចំពោះកិច្ចត្រូវធ្វើនោះវិញ ក៏គ្មាននរណាអាចកំបាំងស្ងៀមស្ងាត់ជាងពួកចារបុរសនោះដែរ ។ បើមិនមែនជាវីរបុរស ប្រាជ្ញបណ្ឌិតលើសផងជនទេនោះ គឺពុំអាចប្រើប្រាស់ចារបុរសបានទេ បើមិនមែនជាអ្នកប្រកបដោយគតិគុណធម៌ចិត្តមេត្តាធម៌ទូលំទូលាយទេនោះ ក៏ពុំអាចប្រើប្រាស់ចារបុរស ដោយប្រសិទ្ធភាពបានដែរ ។ បើមិនមែនជាបុគ្គលដែលមានគំនិត ជ្រាលជ្រៅ មានវិធីសាស្ត្រលំអិតសុខុមទេនោះ គឺពុំអាច ទទួលបានព័ត៌មានចារកិច្ចដ៏ពិតប្រាកដបានឡើយ។ ជ្រាលជ្រៅ លំអិតសុខុម ជាភាពអស្ចារ្យ ភាពមិនធម្មតា តែគ្មានទីណាឡើយដែលថាមិនអាចប្រើប្រាស់ចារបុរស ដើម្បីធ្វើចារកិច្ច បាននោះ។ ក្នុងពេលបេសកកម្ម ចារកិច្ចមិនទាន់បានអនុវត្ត ប្រព្រឹត្តទៅនៅឡើយ តែត្រូវបែកធ្លាយទៅក្រៅ គឺអ្នកដែលជាចារបុរស ឬអ្នកដែលស្តាប់ដឹងឮ ការបែកធ្លាយព័ត៌មាននោះ នឹងត្រូវសម្លាប់ចោលទាំងអស់។



www.elibraryofcambodia.org

ជាធម្មតាទ័ពខ្មាំងណា ដែលត្រូវវាយលុកក្រុងនគរណា ដែលត្រូវដណ្ដើមយក ពួកមនុស្សណាខាងទ័ពខ្មាំងដែលត្រូវធ្វើឃាត សុទ្ធតែត្រូវបានធ្វើការពិនិត្យ អង្កេត ឈ្វេងយល់ អំពីនាមត្រកូលមេកោយ អាណាព្យាបាល អ្នកគ្រប់គ្រង អ្នកជិតដិតស្និទ្ធស្នាល របស់គេឲ្យបានច្បាស់លាស់ ពិសេសពួកមន្ត្រីក្រោមឱវាទ មន្ត្រីព័ត៌មាន ពួកយាមទ្វារទៀតសោតក៏ត្រូវឈ្វេងយល់ផងដែរ ។ រហូតដល់អ្នកនយោបាយ មន្ត្រីជំនួយការទាំងអស់ ត្រូវឲ្យចារបុរសយើងស៊ើបអង្កេតទាំងអស់ ដើម្បីងាយស្រួលក្នុងការយោងតាមស្ថានភាពជាក់ស្ដែង នឹងធ្វើការទិញទឹកចិត្ត ទាញជាប្រយោជន៍ ឬ ត្រូវធ្វើឃាតចោលជាអសារបង់ ។ តាមរយៈដំណើរកិច្ចទាំងនេះនឹងអាចប្រគល់ភារកិច្ចឲ្យពួកគេរួចរាល់ ហើយលែងពួកគេ ឲ្យត្រឡប់ទៅវិញ សម្រាប់អ្នកជាប្រតិកម្មចារបុរសយ៉ាងនេះ គឺអាចប្រើការបានហើយ។ តាមរយៈស្ថានការណ៍ខ្មាំង តែយើងទទួលបានព័ត៌មានពីសំណាក់ប្រតិកម្មចារបុរស វាអាច ជាជំនួយឲ្យយើង



www.elibraryofcambodia.org

ប្រើប្រាស់នូវពួកជនបទចារបុរស និងរនុកក្នុងចារ-បុរសបានល្អប្រសើរជាង។

ដោយស្ថានការណ៍ខ្មាំង ដែលយើងទទួលបានពីសំណាក់ប្រតិកម្មចារបុរស វានឹងជួយដល់យើងសម្រាប់កិច្ចការបញ្ជូនព័ត៌មានក្លែងក្លាយ ងាយជ្រាបដល់ក្អែកច្រមុះរបស់ខ្មាំង។ ដោយស្ថានការណ៍របស់ខ្មាំង ដែលទទួលបានពីប្រតិកម្មចារបុរស វានឹងជួយឲ្យជីវិនចារបុរសយើង អាចវិលត្រឡប់មករាយការណ៍តាមកំណត់បាន ។ ការប្រើប្រាស់ចារបុរស ទាំងប្រាំប្រភេទខាងលើ អ្នកគ្រប់គ្រងចាំបាច់ត្រូវដឹងច្បាស់ដោយខានពុំបាន។ បញ្ហាជាគន្លឹះសម្រាប់យល់ច្បាស់សភាពការណ៍ គឺស្ថិតនៅលើប្រតិកម្មចារបុរស ។ ដូច្នេះចំពោះពួកប្រតិកម្មចារបុរស មិនអាចណាមិនមានការទំនុកបំរុងយ៉ាងពិសេសបានឡើយ ។ កាលពីបុរាណនាយរាជវង្ស *យីន* បានសាងឡើង ក៏ព្រោះតែចេះប្រើប្រាស់ *អី យីស* ជាអតីតមន្ត្រីនគរ *ស្លា* ។ រាជវង្ស *ជូ* សាងបានបុព្វហេតុនៃខ្លួន ក៏ព្រោះតែចេះប្រើប្រាស់ *លី ញ៉ា* ជាអតីតមន្ត្រី បម្រើការក្នុងរាជវង្ស



www.elibraryofcambodia.org

***អិន*** ។ ដូច្នេះ សម្រាប់ព្រះរាជា ដែលប្រកបដោយព្រះប្រាជ្ញាញាណ ដ៏ភ្លឺស្វាងមួយអង្គ នាយទាហានមេទ័ពមួយរូប ប្រកបដោយ ចិត្តមេត្តាធម៌ និងមានសមត្ថភាពខ្ពស់ កាលបើអាចប្រើប្រាស់បានអ្នកមានបញ្ញាបាធិខ្ពង់ខ្ពស់ ដើម្បីធ្វើជាចារបុរស គឺនឹងអាចសាងបានបុព្វហេតុធំធេង ។ នេះគឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងកិច្ចការដឹកនាំទ័ពប្រយុទ្ធ ហើយ ក៏ជាចំណុចដ៏សំខាន់ ជាអាយុជីវិតនៃក្បួនពិជ័យសង្គ្រាម ដែលពុំអាចខ្វះបាន ។ កងទ័ពទាំងមូលសុទ្ធតែត្រូវពឹងផ្អែកទៅលើប្រភពព័ត៌មាន ចារកម្មរបស់ចារបុរស ដើម្បីរៀបចំគម្រោងផែនការសកម្មភាព។

ប្រែសម្រួលពី
អត្ថបទដើម "**ស៊ុន ជឺ ពិជ័យសង្គ្រាម**" រួមមាន១៣
ជំពូក ដែលបានដកស្រង់ចេញពីសៀវភៅ
"អ្នកស្រាវជ្រាវ១១រូប
បកស្រាយអំពី **ស៊ុន ជឺ**"



www.elibraryofcambodia.org

# សំណួរ-ចម្លើយ
# បុរាណគម្រោសឹក

**សួរ** ៖ តើសិល្បៈនៃការដឹកនាំទ័ពមានអ្វីខ្លះ?

**ឆ្លើយ** ៖ ការដឹកនាំទ័ពជាសិល្បៈដែលគ្មានអ្វីលើសពី "មួយ" ក្តោបក្តាប់ "មួយ" បានច្បាស់ ហើយ ចាប់ពីចំណុចមួយនោះ ពង្រីកឥទ្ធិពលសាយភាយចេញទៅគ្រប់ទិសទី ។ ចំណុច "មួយ" នោះ គឺយកធម្មៈជាគ្រឹះ ជាដើមហេតុ យកភាពប្រែប្រួលជាចំណុច ជាចុង ជាត្រួយ ដែលជាផលនៃហេតុនោះ ។ យោងតាមស្ថានភាពនឹងប្រើប្រាស់វា យោងឱកាសអំណោយផល នឹងបង្ហាញ សកម្មភាព។ អាស្រ័យលើការដឹកនាំអ្វីៗវានឹងកើតមាន ។ ហេតុនេះទើបហៅកិច្ចការទ័ព ជាកិច្ចការសំខាន់ លុះអស់ជម្រើស ទើបប្រើប្រាស់។

**សួរ** ៖ ពេលទ័ពទាំងសងខាងប្រឈមមុខគ្នា ភាគីខាងទ័ពខ្មាំង មិន ចូលមក ទ័ពយើងក៏មិនទៅ



www.elibraryofcambodia.org

មុខ ។ ទ័ពទាំងសងខាងការពារ យ៉ាងប្រុងប្រយ័ត្ន ម៉ត់ចត់ ខាងណាក៏ពុំហ៊ានបញ្ចេញទ័ពមុនទាំងអស់ យើងចង់ធ្វើការឆ្មក់វាយលុកមុន ប៉ុន្តែក្តោបក្តាប់ ភាពអំណោយផលមិនទាន់បាន តើត្រូវធ្វើដូចម្តេច?

**ឆ្លើយ** ៖ ខាងក្រៅច្រូលច្របល់ ខាងក្នុងក្រឹត្យក្រម ។ ក្លែងធ្វើជាអត់ ឃ្លាន តែការពិតនោះឆ្អែត ។ ក្នុងច្បាស់ ក្រៅស្រពិចស្រពិល ។ ពេលខ្លះរួបរួម ពេលខ្លះបែកខ្ញែក ពេលរួមពេលរីក ។ កលឧបាយ ស្ងាត់កំបាំង កិច្ចការទ័ពស្ងាត់កំបាំង ។ កំពែងខ្ពស់ លេនដ្ឋានជ្រៅ កម្លាំងទ័ពស្ងប់ស្ងាត់ដូចផ្ទៃទឹក គ្មានរលក ខ្មាំងមិនដឹង ថាយើងធ្វើការការពារយ៉ាងដូចម្តេច ។ ជន្លខាងកើត តែវាយខាងលិច។

**សួរ** ៖ បើខ្មាំងយល់បានស្ថានភាពរបស់យើង ដឹងនូវកលឧបាយ របស់យើង តើយើងត្រូវធ្វើដូចម្តេច?



www.elibraryofcambodia.org

**ឆ្លើយ** ៖ ក្នុងសិល្បវិធីកាន់ទ័ព ឈ្នះត្រង់រក្សាការសម្ងាត់ តាមដាន ស្ថានភាពខ្មាំង រហ័សរហួនក្នុងការក្តោបក្តាប់ឱកាស ដែលជាអំណោយផល ធ្វើការវាយលុយឲ្យទាន់ពេល កុំឲ្យឱកាសកន្លងផុត ។ ហេតុនេះទើបមានពាក្យថា ៖ មាគ៌ា (ធម្មៈ) ប្រសើរ ស្ថិតនៅត្រង់ដែលមិនអាចមើលឃើញដោយភ្នែក ។ កិច្ចការប្រសើស្ថិតនៅត្រង់ ដែលពុំអាចស្តាប់ឮដោយត្រចៀក ។ ឈ្នះប្រសើរស្ថិតនៅត្រង់ដែលពុំអាចដឹងបាន។

សត្វស្ទាំង មុនពេលចាប់ចំណីវាតែងបង្អង់ហើរដោយ សម្លបស្លាបទាំងសងខាងហើយទម្លាក់ខ្លួនយ៉ាងលឿន ទៅរកគោលដៅ។ សត្វខ្លាមុនពេលចាប់សត្វម្រឹគជាចំណីវាតែងពួនលបលាក់ខ្លួន ហើយសម្លបត្រចៀកទាំងសងខាងរង់ចាំ ឱកាសសមស្រប ស្ទុះវាយប្រហារក្រញិកយកយ៉ាងប្រសិទ្ធិភាព។ រីឯមហាបុរសមុនពេលធ្វើសកម្មភាព លោក



www.elibraryofcambodia.org

តែងសម្តែងចេញនូវភាពល្ងង់ខ្លៅ ប៉ុន្តែដល់ពេលប្រឡូកក្នុងការងារពិត គំនិតបញ្ញាស្តែងចេញលើសលប់ឥតមានគូប្រៀប។

**សួរ** ៖ កត្តាសំខាន់ក្នុងការដឹកនាំទ័ពប្រយុទ្ធរួមមានអ្វីខ្លះ?

**ឆ្លើយ** ៖ តាំងពីបុរាណនាយ អ្នកដែលជំនាញក្នុងការធ្វើសឹកសង្គ្រាម គឺពុំមែនច្បាំងនៅលើមេឃ ហើយក៏ពុំមែនច្បាំងនៅក្រោមដីនោះដែរ ប៉ុន្តែរាល់កិច្ចការឈ្នះចាញ់ស្ថិតនៅលើ " ប្រៀប " ទាំងអស់។

មានប្រៀបគឺចម្រើន បាត់ប្រៀបគឺវិនាស។ ធម្មតានៅ ក្នុងចន្លោះពេលប្រយុទ្ធ តែងពង្រាយទ័ព ដោះអាវក្រោះ ឲ្យ ទាហានឈប់សម្រាក គិតគូរការអនុវត្តផែនការ នៃសមរភូមិប្រយុទ្ធ ។ ដាក់ទ័ពនៅតំបន់ព្រៃស៊ុមទ្រុម ដើម្បីមានកន្លែង លាក់ខ្លួន នៅទីវាងថ្ម ល្អាងភ្នំ ដើម្បីទប់ទល់រថសឹក ទ័ពសេះ របស់សត្រូវ ដាក់ទ័ពនៅព្រៃភ្នំ ព្រៃស្រោង ដើម្បី



www.elibraryofcambodia.org

យកតិច ច្បាំងនិងច្រើន នៅទីបឹងបួរ ទំនាប ល្បាប់ ដើម្បីលាក់បាំង រូបភាព រីនៅទីវាល រាប ល្ហឹងល្ហើយ ដើម្បីប្រើកម្លាំងប្រដែង ប្រៀបអំណាច។ ធ្វើសកម្មភាពដោយល្បឿន លឿន ដូចព្រួញ ហោះគ្រាប់ហើរ ដើម្បីកំទេច ទីតាំងប្រណិតរបស់ទ័ពខ្មាំង បង្កើតកលឧបាយ លាក់ខ្លួនបំបាំងកាយ ប្រើទាហានជន្ល បញ្ឆោត ដើម្បីបំផ្លាញទ័ព ចាប់មេ (បំបែកកូនចាប់មេ)។ ពុះជាបួនហែកជាប្រាំ ដើម្បីបំបែកមូលភាព របស់ទ័ពខ្មាំង។ បង្កភាពភ័យខ្លាច តក់ស្លុតឲ្យ ទ័ពខ្មាំង ដើម្បីយកមួយវាយនឹងដប់ ។ ឆ្លៀត ឱកាសពេលខ្មាំងហេវហត់ ដើម្បីយកដប់ វាយនឹងមួយរយ។ ប្រើប្រាស់បច្ចេកវិធី ដើម្បី ឆ្លងព្រែកទន្លេ។ ប្រើគ្រាប់ ព្រួញរឹង ដាវវែង លំពែងស្រួច ដើម្បីវាយទ័ពជើងទឹក ។ ស៊ើប ពិនិត្យតំបន់ព្រៃស្ងាត់ សម្រុកចូលដោយល្បឿន លឿន រហ័ស ដើម្បីដណ្តើមទីតាំង កំទេច ក្រុងបន្ទាយទ័ពខ្មាំង ទូង ស្គរជ័យ ដើម្បីប្រើ



www.elibraryofcambodia.org

កលយុទ្ធចំឡែក។ ភ្លៀងធំខ្យល់ខ្លាំង ជាឱកាស វាយពីមុខ ស្កាត់ពីក្រោយ ។ ក្លែងបន្លំធ្វើជា ប្រេសិត របស់ទ័ពខ្មាំង ដើម្បីស្ទាក់ផ្លូវដឹក ជញ្ជូនស្បៀង។ ក្លែងបន្លំ សញ្ញាបញ្ជា ស្លៀក ពាក់ដូចទ័ពខ្មាំង ដើម្បីបង្ការពេលត្រូវរត់ដក ថយ ។ យកគុណធម៌ជំរុញលើកទឹកចិត្តកង ទ័ព ដើម្បីប្រយុទ្ធយកឈ្នះលើខ្មាំង។ តំឡើង បុណ្យស័ក្ក ប្រទានរង្វាន់ ដើម្បីកងទ័ពគោរព បទបញ្ជា ។ សុក្រឹតភាពក្នុងការពិន័យ ដាក់ ទោសទណ្ឌ ដើម្បីកម្លាដល់ពួកទាហានដែល ខ្ជិលច្រអូស។ មានពេលសប្បាយ ពេលខឹង ពេលទទួល ពេលឲ្យ ពេលប្រើនយោបាយ ពេលប្រើកម្លាំងបាយ ពេលលឿន ពេល យឺត ដើម្បីសម្រួលក្នុងជូរកងទ័ព ត្រូតបញ្ជា ដល់ថ្នាក់ក្រោម។ នៅទីតាំងខ្ពស់ទូលាយ ដើម្បី ងាយដល់កិច្ចការការពារ ស្ថិតក្នុងសភាព គ្រោះថ្នាក់ ងាយស្រួលក្នុងការសម្រួលពង្រឹង កម្លាំងឡើងវិញ ។ ស្ថិតនៅតំបន់ភ្នំ ព្រៃ



www.elibraryofcambodia.org

ស៊ុបទ្រុប ដើម្បីបិទបាំងការ ធ្វើដំណើរទៅមក ។ កំពែងខ្ពស់ លេនដ្ឋានជ្រៅ ស្បៀងគ្រប់គ្រាន់ ដើម្បីតតាំងយូរអង្វែង។ ហេតុនេះ បើមិនចេះ កលយុទ្ធវាយលុក មិនអាចនិយាយថាគ្មានគូប្រៀបបានឡើយ។ មិនចេះរបៀបបែងចែក ប្តូរផ្លាស់ មិនអាចនិយាយថាអស្ចារ្យបានដែរ ។ មិនចេះរបៀបបង្ក្រាបចលាចល មិនអាចនិយាយថា ចេះទប់ទល់និងសភាពការណ៍នោះដែរ។ ហេតុនេះ ទើបមានពាក្យថា ៖ មេទ័ពគ្មានមេត្តាធម៌ ពលទាហានមិនស្និទ្ធ , មេទ័ពគ្មានភាពក្លៀវក្លា កងទ័ពគ្មានភាពស្រួចស្រាវ, មេទ័ពអ័ព្វបញ្ញា ជួរទ័ពកើតមន្ទិល, មេទ័ពខ្វះភាពឈ្លាសវៃ ជួរទ័ពប្រែក្រឡាស់ មេទ័ពខ្វះភាពហ្មត់ចត់លំអិតសុខុម ជួរទ័ព ព្រងើយហី, មេទ័ពមិនបានហ្វឹកហាត់ណែនាំជាប្រចាំ កងទ័ព ខ្វះការប្រុងប្រយ័ត្ន , មេទ័ពគ្មានភាពដាច់ខាត ជួរទ័ពនឹងខកខានយឺតយ៉ាវ។



www.elibraryofcambodia.org

អាស្រ័យហេតុនេះ មេទ័ព គឺជាបញ្ហាការរបស់កងទ័ព គេអាចធ្វើឲ្យកងទ័ពស្ងប់ស្ងាត់ គេអាចធ្វើឲ្យកងទ័ព ចលាចល។ មេទ័ពពូកែ កងទ័ពខ្លាំងក្លាប្រទេសជាតិរឹងមាំ, មេទ័ពអន់កម្លាំងខ្សោយ ប្រទេសជាតិអាសន្ន។

**សួរ** ៖ ពេលមិនទាន់ពើបប្រយុទ្ធ ប៉ុន្តែយើងចង់ដឹងមុនអំពីស្ថានភាព ខ្លាំងខ្សោយរបស់ទ័ពខ្មាំង និងប្រផ្ទោលចាញ់ឈ្នះ តើយើងត្រូវធ្វើដូចម្តេច ?

**ឆ្លើយ** ៖ ប្រផ្ទោលឈ្នះចាញ់យើងអាចមើលឃើញនៅត្រង់ស្មារតី។ មេទ័ពដែលមានភាពភ្លឺស្វាងឈ្លាសវៃ ចេះពិនិត្យអង្កេតសភាពការយ៉ាងដិតដល់នោះការបរាជ័យគឺជារបស់អ្នកដទៃ។ ភាពម៉ត់ចត់របស់យើង វាអាស្រ័យដោយការចេញចូលទៅមុខ ថយក្រោយរបស់ទ័ពខ្មាំង ពិនិត្យអង្កេតភាពកម្រើក ភាពស្ងប់ ពាក្យសំដីអាក្រក់ល្អ ដែលពលទាហានក្នុងជួរទ័ពខ្មាំងបានឆ្លោយមាត់ពោលចេញមកក្រៅ។



www.elibraryofcambodia.org

សួរ ៖ ពេលត្រូវទ័ពខ្មាំងហ៊ុមព័ទ្ធ ហើយកាត់ផ្តាច់ផ្លូវមុខ ផ្លូវក្រោយ រាំងស្កាត់ផ្លូវដឹកជញ្ជូនស្បៀងរបស់យើង តើយើងត្រូវធ្វើដូចម្តេច ?

ឆ្លើយ ៖ នេះហើយ ដែលទ័ពយើងជួបអាសន្ន ។ បញ្ជាទ័ពឲ្យលឿនរហ័ស ហើយក្លៀវក្លាបំផុតគឺឈ្នះ យឺតយ៉ាវគឺចាញ់ ។ ក្នុងស្ថានភាពនេះត្រូវអនុវត្តគោលការណ៍វាយលុកប្តូរស្លាប់រស់ទើបបាន ។ ប្រើកងទ័ពសឹក និងទ័ពសេះក្លាហានលុកលុយចូលអុកឡុកបង្កភាពជ្រួលច្របល់ក្នុងជួរទ័ពខ្មាំង ឆ្លៀតឱកាសនោះវាយលុកដោយល្បឿនលឿនដូចផ្លេកបន្ទោរ គឺអាចមានសេរីភាពក្នុងភាពម្ចាស់ការ ។

សួរ ៖ ពេលរួចផុតពីរង្វង់ហ៊ុមព័ទ្ធហើយ យើងចង់ឆក់ឱកាសនោះ ធ្វើការវាយលុកសង្គ្រប់យកឈ្នះទៅលើទ័ពខ្មាំងតើត្រូវធ្វើយ៉ាងដូចម្តេច ?

ឆ្លើយ ៖ ទ័ពឆ្វេងវាយលុកទៅឆ្វេង ទ័ពស្តាំវាយលុកទៅស្តាំ ដោយល្បឿនលឿន មិនដណ្តើមផ្លូវ



www.elibraryofcambodia.org

ជាមួយទ័ពខ្មាំង ។ ទ័ពកណ្តាលត្រូវផ្លាស់ប្តូរវេនគ្នា ពេលមុនពេលក្រោយ ។ ដូចនេះទ័ពខ្មាំងថ្វីត្បិតតែមានចំនួនច្រើនក៏ពិតមែន ក៏ប៉ុន្តែទ័ពខ្មាំងក៏អាចរត់ចោលជួរដែរ ។

**សួរ** ៖ ពេលនាំទ័ពចូលទៅជ្រៅ ក្នុងទឹកដីខ្មាំង ហើយត្រូវខ្មាំងឡោមព័ទ្ធទាំងបួនទិស រាំងស្កាត់ផ្លូវដកថយ កាត់ផ្តាច់ផ្លូវដឹកជញ្ជូនស្បៀងរបស់យើង ។ ទ័ពខ្មាំងមានចំនួនច្រើនមានស្បៀងគ្រប់គ្រាន់ ចំណែកទ័ពយើងវិញស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ តែបើចង់គេចចេញឲ្យផុតពីទីនោះ យើងត្រូវធ្វើដូចម្តេច ?

**ឆ្លើយ** ៖ វិធីដែលអាចគេចបាន គឺយកអាវុធជាសំខាន់ យកការប្រយុទ្ធហានក្លាជាចំបង យល់ដឹងច្បាស់អំពី ចំណុចខ្សោយរបស់ទ័ពខ្មាំង និងកន្លែងដែលគ្មានមនុស្ស គឺអាចចាកចេញបាន ។ នាយទាហាន ពលទាហានកាន់ទង់សញ្ញាពណ៌ខ្មៅ បំពាក់អាវុធគ្រប់ដៃមាត់ខាំ



www.elibraryofcambodia.org

ស្មៅវង់ចាំដល់ពេលយប់ នាំកងកម្លាំងទាំង
អស់ចេញធ្វើប្រតិបត្តិការណ៍។ នាយទាហាន
ពលទាហានទាំងអស់ ត្រូវមានភាពក្លាហាន
នៅជួរមុខរៀបជាជួរទទឹង វាយបើកផ្លូវឲ្យ
កងទ័ពខាងក្រោយរុលទៅមុខតាម ។ ទ័ព
ជំនាញបាញ់ធ្នូរធ្វើជាទ័ពបង្កប់ដើរខាងក្រោយ
ទ័ពខ្សោយ និងកងរថសឹកដើរកណ្ដាល ។
រៀបចំសមរភូមិរួចរាល់ ចាប់ផ្ដើមយុទ្ធដំណើរ
ការ ទ័ពយ៉ាងធម្មតា ប្រយ័ត្នប្រយែង មិនត្រូវ
តក់ស្លុត ភ័យខ្លាច ឲ្យរថសឹកសម្រាប់ប្រយុទ្ធ
ទៅមុន និងនៅខាងក្រោយ សម្រាប់ ទប់ទល់
ការពារ រីឯរថសឹកការពារទុកសម្រាប់វាយលុក
ស្លាប ឆ្វេងស្ដាំ។ កាលបើទ័ពខ្មាំងដឹងបាន គឺ
ក្រុមនាយទាហាន ពលទាហាន រក្សាស្មៃគ្រ
ដែលក្លាហានទាំងនោះ ត្រូវធ្វើការវាយប្រហារ
យ៉ាងឆាប់រហ័សទៅមុខ ទ័ពខ្សោយ និងកង
រថសឹក ទៅតាមក្រោយ ទ័ពបាញ់ព្រួញធ្វើ
ការបង្កប់ខ្លួន ពួនស្ទាក់ កន្លែងមួយ ដើម្បី



www.elibraryofcambodia.org

តាមដានសភាពការណ៍ រង់ចាំទ័ពខ្មាំងដេញតាមមកដល់ គឺវាយស្គរ ដុតភ្លើង វាយប្រហារ សង្គ្រប់យកយ៉ាងខ្លាំងពីក្រោយខ្នងប្រៀបដូចពីក្នុងដីផុសឡើង ពីលើមេឃទំលាក់ចុះ កងទ័ពទាំងអស់ ប្រយុទ្ធក្នុងក្តីអង់អាចក្លាហាន ពេលនោះទ័ពខ្មាំងពុំអាច តទល់បានឡើយ។

**សួរ** ៖ ខាងមុខមានទន្លេជ្រោះជ្រៅ យើងចង់ឆ្លងកាត់ ប៉ុន្តែ ពុំបានត្រៀមលក្ខណៈដូចជា ទូកសំពៅ ឬ ក្បូនជាមុន ។ ទ័ពខ្មាំងដាក់ប៉ុស្តិ៍ស្កាត់មុខស្កាត់ក្រោយ គ្រប់ទីកន្លែងសំខាន់ៗ សុទ្ធតែទាហានយាមកាមតឹងរឹងគ្រប់ពេល មានទាំងរថសឹក ទ័ពសេះ ចាំស្ទាក់វាយប្រហារពីមុខ ហើយមានទាំងកងស៊ើគ្រស្លាប់របស់ ទ័ពខ្មាំងដេញតាមពីក្រោយទៀតផង ស្ថិតក្នុងស្ថានភាពនោះ តើត្រូវធ្វើដូចម្តេច?

**ឆ្លើយ** ៖ ទីកន្លែងដែលមានព្រៃក មានទន្លេធំ មានអន្លង់ជ្រៅ មាន ទន្លេធំទូលាយ មានជ្រោះ



www.elibraryofcambodia.org

ជ្រៅ ទ័ពខ្មាំងតែងមិនសូវយកចិត្តទុកដាក់ការពារប៉ុន្មានទេ បើមានក៏ចំនួនតិចតួចដែរ ស្ថិតក្នុង ករណីនេះ ត្រូវប្រើគ្រប់រាល់មធ្យោបាយ ដើម្បីឆ្លងកាត់ឲ្យខានតែបាន ។ កងទ័ពខ្លាំងពូកែ ដែលស្ថិតក្រោមការបញ្ជារបស់យើងត្រូវហ៊ានស្ម័គ្រស្លាប់ វាយសម្រុកចូលទៅក្នុងសមរភូមិរបស់ទ័ពខ្មាំង។ ជាដំបូងត្រូវដុត រាល់សម្ភារៈបរិក្ខាទ័ពចោលទាំងអស់ បន្ទាប់មកកំទេចស្បៀងអាហារចោលឲ្យអស់រួចហើយ និយាយឲ្យច្បាស់ប្រាប់ដល់សេនាទាហាន ក្នុងជួរកងទ័ពទាំងមូលថា បើយើងទាំងអស់គ្នារួមប្រយុទ្ធដាច់ខាតគឺឈ្នះ គឺរស់ មិនប្រយុទ្ធគឺស្លាប់ ។ ពេលដែលចាកចេញពីរង្វង់ហ៊ុមព័ទ្ធបានហើយ បញ្ជាឲ្យកងទ័ពជួរក្រោយដុតភ្លើងបំភ្លឺ ដើម្បីធ្វើការ យាមល្បាតនៅទីកន្លែងដែលមានស្មៅ មានកំពោតព្រៃដែលជាភូមិគ្រោះនោះ ពេលនោះ រថសឹកទ័ពសេះ របស់ទ័ពខ្មាំង ប្រាកដជាពុំហ៊ាន



www.elibraryofcambodia.org

ដេញតាមឆ្ងាយទេ។ ដោយមានភ្លើងជាសញ្ញា យើងគួរតែចេញបញ្ជា ឲ្យទ័ពធ្វើដំណើរមក កាន់ទីកន្លែងដែលមានភ្លើង សញ្ញានោះឈប់ សម្រាក នេះហើយ ដែលហៅថា ប្រយុទ្ធប្តូរ ស្លាប់ដើម្បីរស់ក្នុងសមរភូមិគ្រោះអាសន្ន ។ ដូចនោះ កងទ័ពប្រយុទ្ធក្លៀវក្លាទាំងព្រម ស្មារតី ប្រយុទ្ធដោយកំរិតខ្ពស់ គ្មានអ្វីនឹងអាចរារាំង កម្លាំងប្រយុទ្ធនេះបានឡើយ។

**សួរ** ៖ នាំទ័ពចូលជ្រៅទៅក្នុងទឹកដីខ្មាំង ជួបអូរជ្រៅជ្រោះធំ ខ្សែទឹកហូរចាក់ខ្ទរខ្ទាញ់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលទ័ពពុំទាន់ឆ្លងផុតអស់ ស្រាប់តែមានភ្លៀងធំ ទឹកហូរចាក់ខ្លាំង ខាងក្រោយមិនអាចទាក់ទងខាងមុខបាន យើងក៏ពុំបានត្រៀមទូក ឬក្បូនចម្លងទុកជាមុន ខាងក្រោមទឹកក៏គ្មានដើមឈើ ឬ វល្លិ៍អ្វីដែលអាចជំនួយឲ្យយើងឆ្លងបាន តើយើងត្រូវធ្វើយ៉ាងដូចម្តេច?



www.elibraryofcambodia.org

**ឆ្លើយ** ៖ ពេលដឹកនាំទ័ពចេញច្បាំង ភាពជាមេទ័ពដែលមិនបានគិតទុកមុន អាវុធយុទ្ធភ័ណ្ឌមិនគ្រប់គ្រាន់ ការហ្វឹកហាត់មិនបានស្ទាត់ជំនាញ ពលសេនាមិនស្ទឹកនឹងក្បាច់ប្រយុទ្ធ ដូចនេះពុំមែនជាទ័ពនៃព្រះខត្តិយរាជនោះទេ ។ ពេលកងទ័ពពើបប្រយុទ្ធ ទាហានទាំងអស់ត្រូវតែចេះប្រើប្រាស់អាវុធគ្រប់ប្រភេទ ។ វាយលុកក្រុង ហ៊ុមព័ទ្ធបន្ទាយត្រូវយកកងរថសឹកវាយបុកទម្លុះក្រុងមុនពេលវាយលុក កាលបើចង់មើលឲ្យបានច្បាស់រាល់សកម្មភាពក្នុងក្រុងត្រូវមានជណ្ដើរខ្ពស់ ។ កងទ័ពធ្វើយុទ្ធដំណើរ ឬឈប់សម្រាក ត្រូវមានកងរថសឹកការពារមុខក្រោយ។ ជួបផ្លូវទល ជួបច្រកចង្អៀត ត្រូវមានទ័ពពិសេសមានធ្នូរឹងការពារសងខាងផ្លូវ សាងសង់បន្ទាយជុំវិញត្រូវមានសំណាញ់ដែករបងឬស្សីស្មៅបន្លា រាំងស្កាត់ទ័ពសេះ ពេលថ្ងៃឡើងជណ្ដើរ ឬ ប៉មខ្ពស់មើលឲ្យបានឆ្ងាយ តំឡើងទង់សញ្ញាប្រាំពិណ ពេលយប់ដុតចង្កៀងកោម



www.elibraryofcambodia.org

ឲ្យច្រើន ទូងស្គរ វាយរគាំង ផ្លុំស្រឡាយ ដាស់ស្មារតីប្រយុទ្ធ ។ ពេលឆ្លងកាត់ទីដែលមានរណ្ដៅជ្រៅត្រូវមានកង្វារ មានចប មានជ្រនីក ពេលឆ្លងព្រៃក ទន្លេ ត្រូវមានទូក មានសំពៅ ធ្វើដំណើរច្រាស់ទឹក ត្រូវមានស្ពានអណ្ដែត ។ កងទ័ពមានសម្ភារៈគ្រប់គ្រាន់ មេទ័ពមិនព្រួយអ្វីសោះឡើយ។

**សួរ** ៖ ទ័ពយើង និងទ័ពខ្មាំងប្រយុទ្ធគ្នានៅជាប់ព្រំប្រទល់ ទ័ពខ្មាំងអាចមកកន្លែងទ័ពយើង ទ័ពយើងក៏អាចទៅដល់ទីតាំងទ័ពខ្មាំង។ ភាគីទាំងសងខាង បានត្រៀមរៀបចំសមរភូមិរៀងខ្លួនយ៉ាងហ្មត់ចត់រឹងមាំ គ្មានខាងណាហ៊ានចល័តទ័ពមុនទាំងអស់ ប៉ុន្តែយើងចង់ធ្វើការវាយលុកទ័ពខ្មាំង ហើយទ័ពខ្មាំងក៏ចង់ធ្វើការវាយលុកមកលើទ័ពយើងដែរ ក្នុងស្ថានភាពនោះយើងត្រូវធ្វើយ៉ាងដូចម្ដេច?

**ឆ្លើយ** ៖ ចែកទ័ពចេញជាបីក្រុម។ បញ្ជាឲ្យទ័ពមុខជីកលេនដ្ឋានទប់កំពែងការពារ តែមិនឲ្យចេញ



www.elibraryofcambodia.org

ប្រយុទ្ធដាច់ខាត រួចហើយបញ្ជាឲ្យតំឡើងទង់សញ្ញាប្រយុទ្ធ ទូងស្គរ ដាស់ចម្បាំង តែត្រៀមការពារ ។ បញ្ជាឲ្យទ័ពជួរក្រោយប្រមូលសន្សំស្បៀង ស្តុកទុកឲ្យច្រើនមិនឲ្យខ្មាំងដឹងគំនិតបំណងរបស់យើង។ បញ្ជាទ័ពស្រួច ទ័ពពិសេសបង្កប់ខ្លួនលាយឡំចូលទៅក្នុងជួរទ័ពខ្មាំង បញ្ឆោតទ័ពខ្មាំងហើយវាយប្រហារពេលដែលទ័ពខ្មាំងមិនបានចាប់អារម្មណ៍ វាយលុកពេលខ្មាំងមិនបានធ្វើការការពារ ។ ខ្មាំងមិនដឹងមិនយល់សភាពការណ៍របស់យើងទើបពុំអាចទប់ទល់នឹងយើងបាន។

ស្ទួរ ៖ ខ្មាំងដឹងសភាពការណ៍របស់យើង ថែមទាំងយល់ច្បាស់ ពីកលយុទ្ធរបស់យើងទៀតផងក្រោយពីស៊ើបអង្កេត ដឹងពីសភាពការណ៍របស់យើង ហើយខ្មាំងក៏យកទ័ពស្រួចមកពួនស្ទាក់នៅទីព្រៃស្រោង ទីតាំងដែលប្រកបដោយគ្រោះថ្នាក់ ដើម្បីធ្វើការវាយប្រហារមកលើ



www.elibraryofcambodia.org

ចំណុចខ្សោយរបស់ទ័ពយើង តើពេលនោះ
យើងត្រូវធ្វើដូចម្ដេច?

**ឆ្លើយ** ៖ បញ្ជាឲ្យធ្វើការចល័តទ័ពនៅពេលថ្ងៃ ទៅបបួលខ្មាំងចេញមកច្បាំង ធ្វើការអុកឡុក អុចអាលឲ្យទ័ពខ្មាំងហេវហត់ ។ ឲ្យទ័ពចាស់ៗកម្លាំងខ្សោយ កាន់ឈើវាយស្គរ ស្រែកហូរកញ្ជ្រៀវ ទាំងសងខាងផ្លូវ ដើរទៅដើរមកមិនឲ្យឃ្លាតឆ្ងាយពីគ្នាមួយរយជំហាន ។ មេទ័ពខ្មាំងប្រាកដជានឿយហត់ កងទ័ពខ្មាំងប្រាកដជាភ័យខ្លាច ដូចនេះខ្មាំងវានឹងពុំអាចហ៊ានមកកន្លែងយើង ចំណែកយើងអាចឆ្លងទៅកន្លែងទ័ពខ្មាំង ដោយមិនមានការ រារាំង ឬ យើងឆ្មក់វាយខាងក្នុង ឬ ឆ្មក់វាយខាងក្រៅ ខណៈនោះកងទ័ពយើងទាំងមូល ឆក់ឱកាសអំណោយផល ធ្វើការវាយលុកសង្គ្រប់យ៉ាងលឿនយ៉ាងរហ័សយកឈ្នះលើទ័ពខ្មាំងជាបន្ទាន់ ។ ទ័ពខ្មាំងត្រូវតែចាញ់។



www.elibraryofcambodia.org

**សួរ** ៖ នាំទ័ពចូលជ្រៅទៅទឹកដីខ្មាំង ពើបប្រទះទ័ពខ្មាំង ភាគីទាំងសងខាងគ្រហឹមដាក់គ្នា ភាពខ្លាំងខ្សោយស្មើគ្នា ប៉ុន្តែមិនទាន់ មានខាងណាហ៊ានធ្វើការវាយប្រហារមុន ។ យើងចង់ឲ្យមេទ័ពខ្មាំងភ័យខ្លាច ពលទាហានខ្មាំងព្រួយបារម្ភនៅពេលចេញទៅសមរភូមិប្រយុទ្ធ ស្មារតីពួកគេមិនរឹងមាំ ជួរក្រោយចង់តែរត់ ជួរមុខគិតតែពីមើលមកក្រោយ យើងឆក់ឱកាសស្រែកហូរកញ្ជៀវធ្វើឲ្យទ័ពខ្មាំងរត់ចោលជួរ តើដើម្បីធ្វើបានដូចនេះ យើងត្រូវធ្វើដូចម្តេចខ្លះ?

**ឆ្លើយ** ៖ ចង់ធ្វើបានដូចនោះ យើងត្រូវនាំទ័ពធ្វើការវាយប្រហារខ្មាំងចម្ងាយប្រហែលដប់ (១០) លីពួនស្ទាក់សងខាងផ្លូវ រួចបញ្ជាទ័ពសេះឲ្យឆ្លងកាត់ពីមុខ និងពីក្រោយទ័ពខ្មាំងប្រហែលមួយរយ(១០០)លី ប្រើប្រាស់ទង់សញ្ញាឲ្យបានច្រើន និងរតាំងស្គរផង។ ពេលចូលប្រយុទ្ធត្រូវវាយស្គរស្រែកហូរកញ្ជៀវ មេទ័ពខ្មាំងប្រាកដជាតក់ស្លុត កងទ័ពខ្មាំងប្រាកដជាភ័យខ្លាច ស្លន់



www.elibraryofcambodia.org

ស្លោពុំអាចជួយគ្នាបាន ទាំងអ្នកធំ ទាំងអ្នកតូច មិនរង់ចាំគ្នា ពួកគេគិតតែពីរត់ប្រាស់អាយុយកតែរួចខ្លួន នោះហើយដែល ទ័ពខ្មាំងត្រូវចាញ់ត្រូវបរាជ័យ។

**សួរ៖** ប្រសិនបើភូមិសាស្ត្រខាងទ័ពខ្មាំងមិនអំណោយផលឲ្យយើង មិនអាចធ្វើការពួនស្ទាក់សងខាងផ្លូវបាន ចំណែកទ័ពសេះរបស់យើង ក៏ពុំអាចចល័តឆ្លងកាត់ពីមុខ ពីក្រោយទ័ពខ្មាំងបាន ។ ខ្មាំងយល់ដឹងគំនិតរបស់យើង ម្លោះហើយខ្មាំងក៏ធ្វើការការពារយ៉ាងរឹងមាំជាមុន ។ កងទ័ពយើងមានការភ័យស្លន់ស្លោ មេទ័ព នាយទាហានខាងយើងក៏មានការភ័យបារម្ភ ដោយមិនអាចវាយប្រហារយកឈ្នះលើទ័ពខ្មាំងបាន ក្នុងសភាពដូចនេះយើងត្រូវ ធ្វើដូចម្តេច?

**ឆ្លើយ៖** សំណួរនេះពិតជាទន់ភ្លន់មែន ហើយក៏ជាសំណួរដ៏ល្អផង ។ ក្នុងស្ថានភាពដូចនេះមុនពេលប្រយុទ្ធប្រាំថ្ងៃ ត្រូវមានចារជនទៅស៊ើបការណ៍យកពត៌មានឲ្យច្បាស់ការណ៍ អំពីស្ថាន



www.elibraryofcambodia.org

ភាពខ្មាំង ដើម្បីបានដឹងច្បាស់ទីតាំងដែលទ័ពខ្មាំងមកកាន់កាប់ឈរជើង រួចហើយរៀបចំកម្លាំងទ័ព ធ្វើការពួនស្ទាក់រង់ចាំមុនជាស្រេច បន្ទាប់មក ធ្វើការជន្លបញ្ឆោតទ័ពខ្មាំងឲ្យចូលក្នុងអន្ទាក់របស់យើង ពោលគឺ ឲ្យទ័ពខ្មាំងចូលក្នុងភូមិមរណៈនោះឯង។ យើងត្រូវចៀសវាងកុំពើបប្រយុទ្ធជាមួយទ័ពខ្មាំង ។ ហើយបញ្ជូនកង កាន់ទង់សញ្ញាឲ្យចេញឆ្ងាយពីកម្លាំងទ័ពពិតរបស់យើង ដើម្បីឲ្យខ្មាំងមើលឃើញទ័ពយើង ដូចជាមានភាពធូរលុង រាយប៉ាយ ពេលនោះ ទ័ពខ្មាំងប្រាកដជាដេញតាមពុំខាន ខណៈនោះ យើងបកក្រោយធ្វើការវាយប្រហារទប់ទល់ តែប្រយុទ្ធ តែមួយប្រាវបានហើយ រួចហើយរត់ចោលសមរភូមិប្រយុទ្ធ ប៉ុន្តែ កុំផ្អាកការទូងស្គរ វាយរគាំងឲ្យសោះ ពេលរត់បានប្រហែល បី បួនលី យើងបញ្ជាទ័ពឲ្យបកក្រោយវិញទៀត ពេលនោះ កងទ័ពបង្កាប់របស់យើងផុសចេញមក ឬ ទាំងសងខាង ឬ



www.elibraryofcambodia.org

ទាំងពីមុខពីក្រោយ កងទ័ពយើងទាំងមូលធ្វើការប្រយុទ្ធកៀក វាយប្រហារសង្គ្រប់យកឈ្នះយ៉ាងលឿនបំផុត ពេលនោះ ទ័ពខ្មាំងប្រាកដជាចាញ់រត់យកតែរួចខ្លួនពុំខានឡើយ។

**សួរ** ៖ ដឹកនាំទ័ពចូលទៅជ្រៅក្នុងទឹកដីខ្មាំង ពើបប្រទះទ័ពខ្មាំង ជួននឹងធាតុអាកាសត្រជាក់ខ្លាំងក្តៅខ្លាំង ភ្លៀងរលឹមទាំងថ្ងៃទាំងយប់ ពីមួយថ្ងៃទៅមួយថ្ងៃ ។ កំពែងរបងលេនដ្ឋានខូចខាតច្រកទ្វារ បាត់បង់ការការពារ ពលទាហាននាយទាហាន បាត់បង់ភាពម្ចាស់ការ ពេលយប់ទ័ពខ្មាំងមកដល់កៀក ទ័ពយើងពុំអាច ការពារបាន ផ្ទាក់ក្រោម ផ្ទាក់លើ ច្របូកច្របល់ ស្ថិតក្នុងសភាពការណ៍ដូចនេះ តើត្រូវធ្វើដូចម្តេច?

**ឆ្លើយ** ៖ ធម្មតាក្នុងជួរកងទ័ព ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ជានិច្ច ភាពខ្នីខ្នា ភាពធ្វេសប្រហែសគឺចាញ់ ចេញបញ្ជាឲ្យពួកទាហាននៅលើកំពែងក្រុង ម្នាក់ៗត្រូវកាន់ទង់សញ្ញា ដើម្បីផ្សាយបទបញ្ជា ដោយមិនប្រើការនិយាយជាសម្លេងដាច់



www.elibraryofcambodia.org

ខាត ។ ទាហាន ទាំងអស់ត្រូវបែរមុខទៅក្រៅ ចំនួនបីពាន់នាក់ចងជាប៉ុស្តិ៍មួយ ដាស់រំលឹកទៅវិញទៅមកជានិច្ច ម្នាក់ៗត្រូវរក្សាទីកន្លែងដែលខ្លួនឈរជើងឲ្យបានហ្មត់ចត់ រឹងមាំ។ បើកងទ័ពខ្មាំងមកដល់ ពេលដែលឃើញកងទ័ពយើង មានការការពារដោយប្រុងប្រយ័ត្ន រឹងមាំ នោះទ័ពខ្មាំងប្រាកដជាដកថយពុំខាន ខណៈពេលនោះ កងទ័ពខ្មាំងក៏អស់កម្លាំងហេវហត់ ហើយថែមទាំង រវើយចិត្តទៀតផងនោះ វាជាឱកាសសម្រាប់កងទ័ពយើង យើងត្រូវយកទ័ពស្រួចដេញតាមទ័ពខ្មាំង ធ្វើការវាយប្រហារជាបន្ទាន់ ។ ស្ថានភាពនោះ យើងនឹងឈ្នះជាប្រាកដ ។

**សួរ ៖** បើខ្មាំងដឹងថាទ័ពយើងដេញតាម ទ័ពខ្មាំងធ្វើការបង្កប់ទ័ពស្រួចរបស់ខ្លួន ដើម្បីពួនស្ទាក់ ហើយធ្វើកលជាចាញ់ រត់ទៅកន្លែងទ័ពបង្កប់របស់វារួចហើយបែរក្រោយតទល់នឹងទ័ព យើងវិញ ខណៈនោះ ទ័ពបង្កប់របស់ខ្មាំងផុះឡើង



www.elibraryofcambodia.org

វាយប្រហារទ័ពយើងពីគ្រប់ទិសទី ។ កងទ័ពយើងភ័យខ្លាចច្របូកច្របល់ បាត់បង់សណ្ដាប់ធ្នាប់ បោះបង់ទីកន្លែងដែលខ្លួនឈរជើង តើពេលនោះយើងត្រូវស្រោចស្រង់សភាពការណ៍តាមបែបណា?

**ឆ្លើយ** ៖ ចែកទ័ពចេញជាបីក្រុម ដើម្បីដេញតាម ប៉ុន្តែកុំឆ្លងកាត់កន្លែង ខ្មាំងបង្កប់ទ័ព ។ ពេលដែលទ័ពយើងទាំងបីក្រុម មកដល់ព្រមគ្នា ហើយពេលនោះ ត្រូវធ្វើការវាយប្រហារទៅលើទ័ពខ្មាំងទាំងពីមុខ ទាំងពីក្រោយ ឬ វាយប្រហារដោយគាបទាំងសងខាង ផ្អឹងជំនីទ័ពខ្មាំង រួចចេញបទបញ្ជាជាសញ្ញាច្បាស់លាស់ វាយលុកដោយល្បឿនលឿនរហ័សបំផុត វាយបានមុនគឺឈ្នះ។

**សួរ** ៖ នាំទ័ពចូលជ្រៅក្នុងទឹកដីខ្មាំង ទប់ទល់ជាមួយខ្មាំង ត្រូវខ្មាំងធ្វើការស្ទាក់ស្កាត់ បិទផ្លូវដឹកជញ្ជូនស្បៀងរបស់ទ័ពយើង ហើយទ័ពខ្មាំងថែមទាំងបានស្ទាក់ពីមុខ ស្កាត់ពីក្រោយទ័ព



www.elibraryofcambodia.org

យើងទៀត ។ ក្នុងខណៈនោះប្រសិនបើយើង ពើបប្រយុទ្ធ គឺពិតជាមិនឈ្នះ ប៉ុន្តែបើការពារ ក៏ពុំអាចរក្សាបានយូរដែរ តើសភាពដូចនេះ យើងត្រូវធ្វើដូចម្តេច?

**ឆ្លើយ ៖** ពេលចូលជ្រៅក្នុងទឹកដីខ្មាំង យើងត្រូវពិនិត្យ ស្ថានភាពដី ស្វែងរកទីតាំងដែលអំណោយផល ត្រូវផ្អែកទៅរកព្រៃភ្នំ ដែលជាដីឧបសគ្គ អាច ជាជ្រោះ ជាជ្រលងដងអូរ មានឈើព្រៃ ដើម្បី ពង្រឹងការពារឲ្យបានហ្មត់ចត់ ចំពោះទីតាំងសំ ខាន់ៗទាំងឡាយ ហើយត្រូវចេះឈរជើងនៅ ទីតាំងភូមិសាស្ត្រ ដែលមានប្រៀបដូចជាកំពែត ព្រៃ ដីដំបូកជាដើម ។ ធ្វើដូចនេះទ័ពយើង នឹង មានភាពរឹងមាំ, ទ័ពខ្មាំងមិនអាចឆ្លងកាត់ពីមុខ ឬខាងក្រោយទ័ពយើងបានឡើយ។

**សួរ ៖** ពេលកងទ័ពឆ្លងកាត់តំបន់ខ្ពង់រាប តំបន់វាល ទំនាប ឬ ទីតាំងរាបស្មើ ហើយទ័ពយើងត្រូវ វង្វេងផ្លូវ ពេលនោះចៃដន្យត្រូវពើបប្រយុទ្ធជា មួយទ័ពខ្មាំង បើប្រយុទ្ធមិនអាចឈ្នះ បើការពារ



www.elibraryofcambodia.org

មិនរឹងមាំ។ ទ័ពខ្មាំងចាត់កម្លាំងគាបសង្កត់សង ខាងឆ្អឹងជំនីទ័ពយើង ស្កាត់មុខ ស្កាត់ក្រោយ ទ័ពយើង តើយើងត្រូវធ្វើដូចម្ដេច?

**ឆ្លើយ** ៖ ធម្មតាការដឹកនាំទ័ពធ្វើសឹកសង្គ្រាម ពេលនៅឆ្ងាយពីទ័ពខ្មាំងចម្ងាយមួយរយលី ត្រូវឲ្យកម្លាំងស៊ើបការណ៍ដើរមុន ដើម្បីបានច្បាស់ភូមិសាស្ត្រ ដែលជាទីតាំងឧបសគ្គរបស់ទ័ពខ្មាំង រួចហើយយកកងរថសឹក ធ្វើជាកំពែង ជារនាំងបាំង ដើម្បីឲ្យកងទ័ពរុលទៅមុខ ដាក់កម្លាំងជំនួយពីរផ្នែកនៅខាងក្រោយ ផ្នែកឆ្ងាយគឺចម្ងាយមួយរយលី ផ្នែកជិតហាសិបលី ។ បើមានសភាពការណ៍បន្ទាន់ គឺមុខក្រោយអាចជួយគ្នាបាន ក្នុងជួរកងទ័ពជានិច្ចកាលត្រូវការពារឲ្យរឹងមាំ គឺមិនខាតបង់ មិនទទួលរងការវាយប្រហារពីទ័ពខ្មាំងឡើយ។

**សួរ** ៖ ពេលប្រយុទ្ធឈ្នះ រុលចូលជ្រៅទៅក្នុងទឹកដីខ្មាំងជួបនឹងក្រុងធំ កំពែងខ្ពស់ ពុំអាចវាយប្រហារបាន ហើយបែរជាមានទ័ពពិសេសរបស់



www.elibraryofcambodia.org

ខ្មាំងឈរជើង នៅចំណុចសំខាន់ ប្រយុទ្ធតទល់ ជាមួយទ័ពយើងវិញ ។ យើងចង់វាយប្រហារក្រុងបន្ទាយ តែខ្លាចក្រែងមានទ័ពខ្មាំងមកពីក្រៅ លបវាយឆ្មក់ គឺក្នុងក្រៅរួមគ្នា ហ៊ុមព័ទ្ធវាយប្រហារទ័ពយើង ធ្វើឲ្យកងទ័ពយើងជ្រួលច្របល់ ថ្នាក់លើ ថ្នាក់ក្រោយភ័យខ្លាច តើពេលនោះយើងត្រូវធ្វើដូច ម្ដេច?

**ឆ្លើយ ៖** ធម្មតាពេលវាយលុកក្រុង ក៏ដូចជាការសាងបន្ទាយបោះជំរុំ យើងត្រូវឲ្យទ័ពសេះ រថសឹកបោះទីតាំងនៅឆ្ងាយ ដើម្បីត្រៀមការពារ ទប់ស្កាត់ការទំនាក់ទំនងរវាងទ័ពក្នុង និងទ័ពក្រៅរបស់ខ្មាំង ទើបពេលខាងក្នុងអស់ស្បៀង ខាងក្រៅមិនអាចមកជួយបាន មនុស្សក្នុងក្រុងភ័យខ្លាច មេទ័ពខ្មាំងត្រូវតែចុះចាញ់។

**សួរ ៖** បើខាងក្នុងអស់ស្បៀង ខាងក្រៅពុំអាចនាំចូលមកជួយបាន ប៉ុន្តែ ទ័ពខ្មាំងលបលួចណាត់គ្នាដោយកលឧបាយសម្ងាត់ណាមួយ ហើយដល់ពេលយប់ ឲ្យកងស្ម័គ្រស្លាប់ចេញប្រយុទ្ធ ប្ដូរ



www.elibraryofcambodia.org

ស្លាប់ឬរស់ជាមួយទ័ពយើង រីឯទ័ពសេះកង
រថសឹករបស់ខ្មាំង រុលសំរុកចូលមកចំទីតាំង
សមរភូមិរបស់កងទ័ពយើង ឬ វាយប្រហារពី
ក្រៅចូលធ្វើឲ្យពលសេនាទ័ពយើង ស្លន់ស្លោ
ជួរកងទ័ពបែកខ្ញែកចលាចល ស្ថិតក្នុងសភាព
បែបនេះយើងត្រូវធ្វើដូច ម្តេច?

**ឆ្លើយ** ៖ ស្ថិតក្នុងស្ថានភាពដូច្នោះ ត្រូវចែកទ័ពជាបី
ក្រុម ពិនិត្យអង្កេតឲ្យច្បាស់លាស់ពីភូមិសាស្ត្រ
ហើយធ្វើការប្រយុទ្ធដោយភាពក្លៀវក្លាបំផុត ។
ស៊ើបអង្កេតមើលទីតាំងជំរុំទ័ព និងកំពែងរបង
របស់ទ័ពខ្មាំង តាមរយៈនោះចាត់កម្លាំងដើម្បី
ទៅជន្លបញ្ឆោតទ័ពខ្មាំង ដោយធ្វើការប្រុងប្រយ័ត្ន
យ៉ាងហ្មត់ចត់ កុំឲ្យផ្តេះផ្តោយ។ ទ័ពខ្មាំងភ័យ
ខ្លាច បើមិនរត់ចូលព្រៃក៏រត់ចូលភូមិ អ្នកស្រុក
ដែរ ។ ទុកឲ្យទ័ពខ្មាំងរត់ចេញទៅ ហើយទើប
យើងយកទ័ពសេះរត់ទៅស្កាត់ពីមុខ ធ្វើការ
វាយប្រហារកុំឲ្យពួកវារត់រួចឲ្យសោះ ។ រីឯពួក
មនុស្សក្នុងក្រុង គិតស្មានថាក្រុមទ័ពទៅមុន



www.elibraryofcambodia.org

បានរកឃើញច្រកចេញគេចខ្លួនរួចហើយ នោះពួកគេ ប្រាកដជាឲ្យទ័ពចេញដំណើរតាម ទុកនៅក្នុងក្រុងសុទ្ធតែពួក ទាហានចាស់ៗកំលាំងខ្សោយឲ្យចាំការពារក្រុងបន្ទាយ ។ ពេលនោះយើងយកទ័ពសេះ កងរថសឹក ដេញតាមឲ្យបានឆ្ងាយបន្តិច ធ្វើឲ្យទ័ពខ្មាំងពុំហ៊ានចេញមកទៀត។ ប៉ុន្តែចៀសវាង កុំពើបប្រយុទ្ធជាមួយទ័ពខ្មាំងឲ្យសោះ គ្រាន់តែធ្វើការហ៊ុមព័ទ្ធការពារខាងក្រៅ ដើម្បីរាំងស្ទាត់ផ្លូវដឹកជញ្ជូនស្បៀងរបស់ទ័ពខ្មាំងបានហើយ ។ ចៀសវាងកុំដុតបំផ្លាញរបស់របរសម្ភារៈផ្សេងៗ ពិសេសគឺផ្ទះសំបែងកុំដុត កុំបំផ្លាញឲ្យសោះ កុំកាប់ព្រៃឈើកុំសម្លាប់ពួកមនុស្សដែលមកចុះចូល កុំធ្វើទុកបុកម្នេញពួកមនុស្ស ដែលយើងចាប់បាន ។ ចេញផ្សាយបទបញ្ជា ដែលជាគុណធម៌ និងមេត្តាធម៌ឲ្យបានទូលំទូលាយ បញ្ជាប្រាប់ឲ្យបានច្បាស់ ដល់ពួកទាហាន និងប្រជានុរាស្ត្រខាងជួរទ័ពខ្មាំងឲ្យបានដឹងថា ទោសកំហុស



www.elibraryofcambodia.org

គ្រាន់តែចំពោះមនុស្សម្នាក់ណានោះតែប៉ុណ្ណោះ។ ដូចនេះមហាជននឹងបានសុខស្ងប់ចុះចូលដោយស្មោះស្ម័គ្រ។

**សួរ ៖** នាំទ័ពចូលជ្រៅទៅក្នុងទឹកដីខ្មាំងជួបតំបន់ស្មៅកក់ស៊ិបទ្រុបព័ទ្ធជុំវិញកងទ័ពយើងទាំងបួនទិស ធ្វើឲ្យការធ្វើដំណើរទ័ព បានតែមួយរយៈខ្លីក៏នឿយហត់ ទាំងមនុស្សទាំងសត្វត្រូវបង្ខំចិត្តឈប់សំរាក។ ខណៈនោះទ័ពខ្មាំងក៏ឆក់ឱកាសមេឃក្តៅ ខ្យល់ខ្លាំង ក៏ដុតភ្លើងពីខាងលើខ្យល់ រួចឲ្យទ័ពពិសេស និងកងរថសឹកពួនស្ទាក់ពីក្រោយ ធ្វើឲ្យទ័ពយើងមានការភ័យខ្លាច រត់ចោលជួរបែកខ្ញែក តើក្នុងស្ថានភាពវឹកវរដូចនេះ យើងត្រូវមានដំណោះស្រាយយ៉ាងណា?

**ឆ្លើយ ៖** ដូចនេះយើងត្រូវប្រើជណ្តើរ ឬ ជញ្ជាំងខ្ពស់ដើម្បីមើលបានឆ្ងាយទាំងសងខាង ឆ្វេង ស្តាំ ពិនិត្យមើលពីមុខពីក្រោយ ពេលឃើញភ្លើងឆេះភ្លាមនោះ យើងត្រូវដុតខាងមុខឲ្យឆេះបានធំទូលាយ ហើយក៏ដុតខាងក្រោយតែម្តង។ បើ



www.elibraryofcambodia.org

ទ័ពខ្មាំងមកពីមុខ យើងត្រូវនាំទ័ពថយក្រោយទៅកាន់ទីកន្លែងដីខ្មៅ ដែលទើបនឹងឆេះរួច ។ បើទ័ពខ្មាំងមកក្រោយឃើញភ្លើងឆេះ នោះប្រាកដជាបកក្រោយវិញពុំខាន ។ យើងត្រូវស្វែងរកទីដីដែលឆេះខ្មៅ សំរាប់ឈរជើង ។ ឲ្យទ័ពបាញ់ព្រួញការពារស្លាបឆ្វេង ស្តាំងនិងទីតាំងទាំងខាងមុខទាំងខាងក្រោយ នោះទ័ពខ្មាំងពុំអាចវាយប្រហារយើងបានឡើយ។

**សួរ** ៖ ទ័ពខ្មាំងដុតភ្លើងទាំងសងខាងស្លាបឆ្វេងស្លាបស្តាំរបស់យើង ហើយថែមទាំងដុតខាងមុខខាងក្រោយទៀតផង ផ្សែងហុយងងឹតមេឃគ្របដណ្តប់លើជួរកងទ័ពយើង។ មហាទ័ពខ្មាំងក៏ស្វែងរកទីតាំងដីដែលឆេះខ្មៅ ដើម្បីរុលទៅមុខសំរុកមករកទ័ពយើង ក្នុងករណីនេះ តើយើងត្រូវមានវិធានការដោះស្រាយ យ៉ាងដូចម្តេច?

**ឆ្លើយ** ៖ ដូចនេះ ត្រូវអនុវត្តការប្រយុទ្ធប្តូរស្លាប់រស់ដើម្បីបុកទំលុះ ទាំងបួនទិស ឲ្យទ័ពបាញ់



www.elibraryofcambodia.org

ព្រួញការពារស្លាបឆ្វេងស្តាំឲ្យរឹងមាំ ។ ធ្វើយ៉ាង
នេះមិនឈ្នះ ប៉ុន្តែក៏មិនចាញ់ដែរ។

**សួរ** ៖ ធ្វើយ៉ាងម៉េចនឹងអាចដឹងបានភាពពិត ភាព
មាយាការ ការទៅ ការមកក្នុងក្រុងបន្ទាយរបស់
ទ័ពខ្មាំង?

**ឆ្លើយ** ៖ ជាមេទ័ពត្រូវតែ ខាងលើច្បាស់អំពីមេឃ
ខាងក្រោមស្គាល់ភូមិសាស្ត្រ នៅកណ្តាល
យល់ពីសភាពមនុស្ស។ ឡើងទៅទីខ្ពស់សម្លឹង
មើលមកក្រោម ដើម្បីពិនិត្យ អង្កេតភាព ប្រែ
ប្រួលរបស់ទ័ពខ្មាំង មើលក្រុងបន្ទាយ គឺដឹង
ភាពពិត ឬ មាយាការ មើលពលសេនាគឺដឹង
ការទៅ ការមករបស់កងទ័ពខ្មាំង។

**សួរ** ៖ ធ្វើយ៉ាងម៉េចទើបដឹងបាន?

**ឆ្លើយ** ៖ ស្តាប់មិនឮសម្លេងស្គរ សម្លេងរគាំង មើលទៅ
លើក្រុង បន្ទាយឃើញបក្សីហិចហើរត្រសង
ដោយមិនមានការភ័យ ខ្លាចអ្វីសោះ មើលទៅ
មិនឃើញធាតុកម្រោល នៃអាវុធយុទ្ធភណ្ឌ
ទិដ្ឋភាពទាំងនោះ គឺទ័ពខ្មាំងក្លែងភេទដាក់



www.elibraryofcambodia.org

## ស៊ឺម៉ាពិជ័យសង្គ្រាម

ក្នុងការធ្វើសឹកសង្គ្រាម៖

- គឺវាយប្រហារទីដែលស្ងប់ ខ្សោយ ចៀសមិនវាយកន្លែងស្ងប់តែខ្លាំង។
- គឺវាយប្រហារកន្លែងដែលនឿយហត់ ចៀសមិនវាយកន្លែងដែល មានការសម្រាកបានល្អ។
- គួរវាយប្រហារកន្លែង ដែលភ័យខ្លាចខ្លាំង ចៀសមិនវាយកន្លែង ដែលភ័យខ្លាចតិត។

នោះគឺជាក្បួនសឹកសង្គ្រាមពីបុរាណ។ តាមក្បួនបុរាណតម្រាសឹក ការប្រើចំនួនមនុស្សតិច ដើម្បីភាពរឹងមាំឃ្លូវអង្វែង ។ ការប្រើចំនួន មនុស្សច្រើន

ឡុក។ បែងចែកកម្លាំង ទ័ពជាក្រុម ដើម្បីប្តូរវេនគ្នាធ្វើការវាយប្រហារ ។ យើងគ្រាន់តែធ្វើការ វាយប្រហារមួយចំណែកតូចនៃទ័ពខ្មាំង ដើម្បីរង់ចាំទ័ពខ្មាំងយកកម្លាំងទ័ពច្រើនមកដល់ ហើយខណៈនោះ បើខ្មាំងមានការសង្ស័យថាទ័ព យើងមានចំនួនតិច គឺខ្មាំងវានឹងអាងចំនួនទ័ពច្រើនរបស់ខ្លួន ដេញតាមវាយប្រហារទ័ពយើងពុំខាន។ ប្រសិនបើខ្មាំងមានភាពលោភលន់និងផលប្រយោជន៍យើងត្រូវបត់ទង់សញ្ញា ហើយធ្វើការស្ទាក់ផ្លូវវាយប្រហារទ័ពខ្មាំងវិញ បើខ្មាំងមានចំនួនទ័ពច្រើន ប្រាកដជានាំទ័ពមក ដើម្បីឲ្យយើងហ៊ុំទ័ព ។ បើខ្មាំងមានចំនួនទ័ពតិច ឬ មានភាពខ្លាចញញើត វាប្រាកដជាគេចចេញពុំខាន ពេលនោះយើងត្រូវតែបើកច្រកហ៊ុមព័ទ្ធ ទុកឲ្យទ័ពខ្មាំងរត់ចេញ។ កុំធ្វើឲ្យវាទល់ច្រក ។ ពេលប្រយុទ្ធគួរបែរខ្នង ទៅខាងលើខ្យល់ បែរខ្នងទៅរកទីទួលខ្ពស់ ស្លាបស្តាំក៏ប្រកាន់យកទីទួលខ្ពស់ដែរ រីឯស្លាបឆ្វេងប្រកាន់យកទីតាំងដែលជាភាពឧបសគ្គ ។ ពេលដែលត្រូវឆ្លងកាត់ស្មៅបបុស ភក់ ល្បាប់ ត្រូវនាំទ័ពទាំងអស់



www.elibraryofcambodia.org

ទៅកាន់ ទីទួលឈរជើងនៅជុំវិញដីជំបូក ទីទួលខ្ពង់ អណ្ដើកនោះកុំខាន ។ ពេលធ្វើសឹកត្រូវរៀបចំពិនិត្យ សង្កេតមើលកិច្ចការរបស់ទ័ពខ្មាំង ពិនិត្យមើលស្ថាន ភាពរបស់ទ័ពខ្មាំង ដើម្បីឲ្យទ័ពយើងចលនាធ្វើសកម្ម-ភាពក្នុងពេលរង់ចាំឱកាស ត្រូវចាត់ឲ្យទាហានយាម ល្បាត ប៉ុន្តែ រក្សាភាពស្ងប់ស្ងាត់រង់ចាំទ័ពធ្វើសកម្ម-ភាព ។ បើទ័ពខ្មាំងវាយប្រហារយើងមុន យើងត្រូវ ប្រើកម្លាំងទ័ព ទៅពិនិត្យតាមដានឲ្យច្បាស់ការណ៍ ។ ពេលធ្វើសឹកសង្គ្រាម យើងត្រូវប្រើចំនួនទ័ពច្រើន ហើយប្រើចំនួនទ័ពតិច ដើម្បីពិនិត្យមើលសភាពប្រែ ប្រួលរបស់កងទ័ពយ៉ាងដូចម្ដេច ៖ ហេតុនេះត្រូវ រំកិលទ័ពទៅមុខ រួចហើយដកថយក្រោយវិញ ដើម្បី ពិនិត្យមើលសភាពកងទ័ពរឹងមាំប៉ុណ្ណា ពេលជួប គ្រោះអាសន្ន ពិនិត្យមើលសភាពទ័ពភ័យខ្លាចដូច ម្ដេច ពេលសុខស្ងប់ពិនិត្យមើលភាពខ្ជីខ្ជា និងការ ប្រមាថ ធ្វេសប្រហែសរបស់កងទ័ពយ៉ាងដូចម្ដេច ពេលចលាចល តើទ័ព មានការសង្ស័យដូចម្ដេច ពេលត្រូវសត្រូវវាយសង្គ្រប់ តើជួរទ័ពរក្សា សណ្ដាប់



www.elibraryofcambodia.org

ផ្ទាប់បានដូចម្ដេច? វាយប្រហារទ័ពខ្មាំង ពេលខ្មាំងកំពុងមានភាពសង្ស័យ យកពលសេនាទ័ពខ្មាំងបញ្ចូលក្នុងជួរកងទ័ពយើង លើកស្ទួយពួកទ័ពដែលចុះចូលនឹងយើង ធ្វើតាមក្រិត្យក្រមរបស់ទ័ពខ្មាំង ឆក់ឱកាសទ័ពខ្មាំង មិនទាន់គេចរត់ពីយើង យើងត្រូវតែទប់ស្កាត់ គោលបំណង កលឧបាយរបស់វា បំផ្លាញនូវរាល់គម្រោងផែនការរបស់ខ្មាំង។ ត្រូវចេះឆក់ឱកាសខ្មាំងកំពុងភ័យខ្លាច ធ្វើការវាយប្រហារជាបន្ទាន់ ។ ពេលទ័ពខ្មាំងគេចរត់ យើងត្រូវដេញតាមជានិច្ចមិនត្រូវឈប់បង្អង់ទេ ប៉ុន្តែបើទ័ពខ្មាំងផ្អាកដំណើរនៅពាក់កណ្ដាលផ្លូវ យើងត្រូវប្រុងប្រយ័ត្ន។ ពេលចូលកៀកកងទ័ពខ្មាំង ត្រូវស្វែងរកផ្លូវរុលទៅមុខ ប៉ុន្តែបើចង់បកក្រោយ ត្រូវរកផ្លូវដកថយតាមក្បួនយុទ្ធសាស្ត្រ។ វាយប្រហារមុនគឺអាក្រក់ វាយប្រហារក្រោយទទួលរងនូវការភ័យខ្លាច ឈប់សម្រាកកើតភាពខ្ជិលច្រអូស មិនឈប់សម្រាកក៏អាក្រក់ដែរ ឈប់សម្រាកយូរពេក នាំឲ្យមានការភ័យខ្លាចឡើងវិញ។ ផ្ញើសារលិខិត ដើម្បីចងសម្ពន្ធភាព ឬ ផ្ដាច់



www.elibraryofcambodia.org

ទំនាក់ទំនង នោះហើយដែលហៅថា ការគិតគូរដល់កម្រិត ជ្រើសរើសទ័ពល្អ ឬ អាក្រក់ នោះហើយដែលថា ការធ្វើឲ្យមនុស្សខ្លាំងក្លាបន្ថែម បោះបង់ចោល ឬ ទុកប្រើប្រាស់ ឲ្យស៊ី ឬ បង្អត់ នោះហើយដែលហៅថា ការស្ទង់ស្ទាបចិត្តមនុស្ស ។ ទាំងនោះហើយជាក្បួនជាតម្រានយោបាយសឹកសង្គ្រាម នៃសម័យបុរាណ។



www.elibraryofcambodia.org

## ល្បិចចៅក្រម

ល្បិចរបស់ចៅក្រមអ្នកជំនុំជម្រះក្តី។ ក្នុងសតវត្សរ៍ទី២៣ នៃពុទ្ធសករាជ ត្រូវគ្នានឹងសតវត្សរ៍ទី១៧ នៃគ្រិស្តសករាជ ព្រះបាទសម្តេច ព្រះជ័យចេស្តាព្រះមហាក្សត្រិយ៍នៃប្រទេសកម្ពុជា ទ្រង់មានព្រះរាជបញ្ជាឲ្យពួកបណ្ឌិតរៀបចំរបៀប ជាល្បិចចៅក្រមអ្នកជំនុំជម្រះក្តីឲ្យបានទៀងទាត់ តាមសុចរិតយុត្តិធម៌ឲ្យងាយពិនិត្យ ពិភាក្សារកការណ៍ពិត ដោយល្បិច៤យ៉ាង ដែលហៅជាពាក្យបាលីសន្មតថា **មន្ថលេន**, **សេនបទ**, **មណ្ឌកជ**, **សីហលោ**។ ល្បិចចៅក្រមទាំងបួនយ៉ាងនេះ មានសេចក្តីអធិប្បាយថា៖

**១- មន្ថលេន** (មន់-ទៈលេន) ន (បាស.មន្ថ " ទន់, ទន់ភ្លន់, ស្រទន់, សន្សឹមៗ, តិច") + លេន "សន្ទុះ, ល្បឿន, ការស្ទាបស្ទង់") ល្បិចឈ្មោះ **មន្ថលេន** នេះមានអត្ថន័យថា ចៅក្រមត្រូវពិចារណា នូវអធិករណ៍ គឺ រឿងក្តីតាមពាក្យចោទ និង ចម្លើយ ដែលស្ទាបស្ទង់ឃើញថា មុនបង្អស់ មិនគួរកញ្ឆក់កញ្ឆែងទេ ក៏ប្រើ



www.elibraryofcambodia.org

ល្បិចសុភាពទន់ភ្លន់សន្សឹមៗ ប្រៀបប្រដូចនឹងទឹក ដែលហូរវិញៗមិនហូរគំហុកខ្លាំង ហូរធ្លាក់ចុះទៅក្នុង ស្រះ ឬ ត្រពាំង ដក់បានជាទឹកពេញទីនោះគួរដល់ ការប្រើប្រាស់ដូច្នោះឯង បើចៅក្រមប្រើល្បិចនេះទៅ ឃើញការណ៍ពិតសព្វគ្រប់ហើយ ក៏សម្រេចឲ្យអធិ-ករណ៍នោះ ចប់ស្រេចដោយប្រពៃបានត្រឹមប៉ុណ្ណោះ ទៅ។

**២-សេនបទ** (សេនៈបត់ ឬ សែនៈបត់) ន ( បា. សេន "សត្វខ្លែង" + បទ "ដំណើរ, ផ្លូវ, កន្លែង, ហេតុ, ឧបាយ" សំ. ឝ្យេន +បទ) ល្បិច ឈ្មោះសេនបទនេះ មានអត្ថន័យថា ចៅក្រមត្រូវពិនិត្យពិចារណានូវរឿងក្តីតាមពាក្យចោទ និងចម្លើយ ដោយប្រើល្បិចស្ទាបស្ទង់មើល យកតម្រាប់សត្វខ្លែង ដែលវាចាប់អ្វីៗ មានកូនមាន់ជាដើម ជាចំណីរបស់វា, ធម្មតាសត្វខ្លែងមុននឹងឆាបកូនមាន់ជាដើម វាត្រូវហើរវេរៗ កេលកុងស្ទង់មើលសិន បើលុះតែឃើញមានទំនង ឱកាសល្មមឆាបឆក់បានទើបវាសម្លបស្លាប ឆាបចុះ ហើយវាហើរប៉េវឡើងទៅ បើចៅក្រមយល់ឃើញថា



www.elibraryofcambodia.org

ត្រូវប្រើល្បិចរិះរបៃបសត្វខ្លែង ហើយត្រញិច សម្រេចសេចក្ដីឲ្យអធិករណ៍បានចប់ដោយសុចរិត យុត្តិធម៌ហើយ ក៏ទុកជាស្រេចត្រឹមប៉ុណ្ណោះទៅ។

**៣-មណ្ឌុកគជ** (ម័ន-ឌុកត់ ឬ ម៉ន់) ន (បា.មណ្ឌុក ឬ មណ្ឌុក "កង្កែប + កត" កជ "ដែលធ្វើគឺការលោត" ) ល្បិចឈ្មោះមណ្ឌុកជនេះ មានអត្ថន័យថា ចៅក្រមត្រូវពិនិត្យពិចារណា នូវអធិករណ៍តាមពាក្យចោទ និង ចម្លើយ ដែលលៃស្ទង់មើលឃើញថា រឿងនេះត្រូវប្រតិបត្តិតាមតម្រាប់កង្កែបលោត , ធម្មតាកង្កែបវាមិនលោតឥតឈប់បង្អង់សោះទេ , វាតែងលោតផ្លោតៗ ហើយឈប់បង្អង់ម្តងៗបន្តិចៗ ហើយទើបវាលោតផ្លោតៗតៗទៅទៀត, ចៅក្រមក៏ត្រូវធ្វើយ៉ាងនោះដែរ គឺត្រូវស្ទាបស្ទង់មើល កុំប្រញាប់ប្រញាល់រួសរាន់ពេក បើអធិករណ៍ហុច ដំណើរឲ្យមក ឃើញថាគួរវិនិច្ឆ័យបានហើយ សឹមសម្រេចសេចក្ដីឲ្យរឿងនោះចប់ស្រេច ដោយសុចរិតយុត្តិធម៌ត្រឹមប៉ុណ្ណោះទៅ។



www.elibraryofcambodia.org

**៤-សីហលោ** (សីហៈលោ) ន (បា.សីហ "សត្វសីហៈ"+លោ<លា "កាត់, កាត់ផ្តាច់, កាន់, កាន់យក" ជា បា.ស ថាសីហលោ) ល្បិច ឈ្មោះសីហលោនេះ មានអត្ថន័យថា កាលបើចៅក្រមពិនិត្យ ពិចារណាឃើញរឿងនោះ មានភ័ស្តុតាងច្បាស់ក្រឡែត មិនគួរឲ្យសង្ស័យទេ ប៉ុន្តែបុគ្គលអ្នកជាប់ចោទអង់អាចរបឹងរបាញក្អេងក្អាងហួសហេតុពេក មិនព្រមទទួលសារភាពតាមការពិតសោះ, ចៅក្រមត្រូវប្រើអាការគំរាមសម្លុតតាមមាត្រាច្បាប់ឲ្យបុគ្គលនោះ ស្លុតគាំងកៀងក្រទាំង ហើយធ្វើឲ្យការណ៍តាមពិតត្រង់ ដោយចៅក្រមយកតម្រាប់តាមសីហៈ ដែលវាពន្លឺសីហនាទស្រែកសន្ធាប់ម្រឹក ហើយវាខាំសម្លាប់យកជាចំណីវាចូរចោះដែរ, ហើយចៅក្រមវិនិច្ឆ័យសម្រេចសេចក្តីដោយសុចរិត យុត្តិធម៌ឲ្យចប់ស្រេចត្រឹមប៉ុណ្ណោះទៅ ។ ( ល្បិចចៅក្រមទាំង៤យ៉ាងនេះ ហៅថាល្បិចព្រះជ័យចេស្តា ឬ ច្បាប់ព្រះជ័យចេស្តា, កាលពីដើមយើងពុំបានឃើញច្បាប់ដើម ក៏ចេះតែអានខុសខ្លះលុះយើងស្រាវជ្រាវឃើញ សាស្ត្រាស្លឹករឹតចាស់ខ្មៅ



www.elibraryofcambodia.org

ជាច្បាប់ដើម ទើបយើងស្រង់យកមកចុះក្នុង វចនា-នុក្រមខ្មែរនេះ ដោយត្រឹមត្រូវហើយ)។

(**ភាព្យសម្រាប់ឲ្យខាយចាំល្បិចចៅក្រម**)

**មន្ទលេន សេនបទ ទាំងមណ្ឌកជ និង សីហលោ** ទាំងបួននេះជា រាជោវាទោ នៃក្សត្រិយ៍សេដ្ឋោ ព្រះជ័យចេស្តា ។ មហាក្សត្រយ៍ខ្មែរយើងស្តេចមានឫទ្ធិថ្កើង ទ្រង់បានប្រាជ្ញា ភិសេកហើយស្រេច ស្តេចទ្រង់បញ្ញា ឲ្យប្រាជ្ញព្រឹទ្ធា តែងល្បិចចៅក្រម។ ជាពាក្យបាលី សន្មត់សេចក្តី ដោយការផ្សៃផ្សំក្រឹត្យទុកជាច្បាប់ សម្រាប់ចៅក្រម កាត់ក្តីឲ្យសមនឹងយុត្តិធម៌។ (មិនមែនសម្រាប់ចៅក្រមគ្រហស្ថទេ នោះទាំងចៅក្រមបព្វជិត ក៏គួរប្រើល្បិចចៅក្រមទាំង ៤យ៉ាងនេះបានដែរ)។

ល្បិចចៅក្រម ទាំងបួនយ៉ាងនេះ កាលបើពិចារណាទៅ យើងគួរដល់ការយកមកគិតគូរក្នុងក្បួនយុទ្ធសាស្ត្រ សម្រាប់ក្នុងសមរភូមិវាយលុកទីតាំងបច្ចាមិត្ត ដោយល្បិចនិមួយៗ ក្នុងល្បិចចៅក្រមទាំងបួនយ៉ាង តាមស្ថានភាពជាក់ស្តែង ។ ពុំនោះ



www.elibraryofcambodia.org

សោត ល្បិចចៅក្រមទាំងបួនយ៉ាងនេះ យើងក៏អាចយកមកពិចារណាក្នុងទីលានជីវិតពិតបានដែរ ពិសេសសម្រាប់ទីផ្សារប្រកួតប្រជែង ម្លោះហើយពេលអានវចនានុក្រមខ្មែរ ដែលជាព្រះរាជស្នាព្រះហស្តនិពន្ធរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ដល់ទំព័រទី ១១៣៧ ដែលមានល្បិចចៅក្រមនេះ ក៏សូមស្រង់យកមកដាក់ ក្នុងទំព័រក្រាំងសៀវភៅពិជ័យសង្គ្រាមបុរាណតម្រាសឹក សម្រាប់មិត្តអ្នកអានសិក្សាតាមការគួរ។



www.elibraryofcambodia.org

# ឆាកប្រយុទ្ធ

ឆាកប្រយុទ្ធ គឺជាការប៉ះទង្គិចគ្នារវាងទាហានពីរក្រុមទំនាស់ផលប្រយោជន៍កើតវិវាទប្រឆាំងគ្នា នៅពេលដែលក្រុមទាំងនោះជាកម្លាំងដ៏សំខាន់ នៃភាគីសងខាង ឬ យ៉ាងហោចណាស់ក៏ពួកគេធ្វើសកម្មភាពឯករាជ្យនៅលើសមរភូមិប្រយុទ្ធរបស់ខ្លួនដែរ ។ មុនពេលមានគ្រាប់រំសេវសម័យនោះ ឆាកប្រយុទ្ធនានាត្រូវបានដោះស្រាយ ដោយការប្រយុទ្ធទល់មុខ ខ្លួនទល់ខ្លួនជាមួយនឹងការប្រើជំពុះទង់ ដាវ លំពែង ចំពោះកងទ័ពអ៊ីតាលី ឆាកប្រយុទ្ធបានដោះស្រាយដោយការវាយលុករបស់ក្រុមវាយប្រហារ ដែលបំពាក់ដោយលំពែង ហើយបន្ទាប់មក ក៏មានឆាកប្រយុទ្ធដោយដាវ យ៉ាងស្ទាត់ជំនាញរហ័សរហួនទៀតផង។ ចំណែកជនជាតិរ៉ូមាំងវិញ ឆាកប្រយុទ្ធតែងរៀបចំក្បួនទ័ពជា រូបភាពបីជួរតាមរូបភាពនេះ កងទ័ពមានអំណោយផលក្នុងការវាយលុក បានជាប់ជាបន្តបន្ទាប់ដោយកម្លាំងនៃជួរទ័ពទីពីរ និងអនុវត្តការចល័ត មាន



www.elibraryofcambodia.org

លក្ខណៈសម្រេចយកឈ្នះ សម្រាប់ជួរទ័ពទីបី ។ ទម្រង់ក្បួនទ័ព ជារូបភាពបីជួររបស់កងទ័ពរ៉ូមាំង គឺនៅពេលចូលកៀកសត្រូវចម្ងាយពី ១០ ទៅ ១៥ y-a ទើបប្រើប្រាស់លំពែងយក្សយ៉ាងធ្ងន់ ដើម្បីប្រយុទ្ធ បន្ទាប់មកប្រើដាវ សម្រាប់ការប្រយុទ្ធកៀក ខ្លួនទល់ខ្លួន ប្រសិនបើជួរទី១ ត្រូវខ្មាំងវាយប្រហារ ដោយពុំអាចសម្រេចយកឈ្នះបាន ជួរទីពីរបន្តវាយសម្រុកចូលទៅចន្លោះជួរទីមួយបន្តការប្រយុទ្ធទៀត តែប្រសិនបើពេលនោះ ការប្រយុទ្ធតតាំងមិនទាន់បានសម្រេចទៀតនោះទើបជួរទីបី ឬ ហៅថាជួរទ័ពបម្រុងនឹងធ្វើការវាយប្រហារចូលមណ្ឌលនៃកងទ័ពសត្រូវ ឬវាយប្រហារពីឆ្អឹងជំនីឆ្វេងស្តាំរបស់ទ័ពខ្មាំងតែម្តង ។ ពីសម័យមជ្ឈិមកាលរហូតមកលទ្ធផល នៃឆាកប្រយុទ្ធតែងដោះស្រាយ ដោយការវាយលុករបស់កម្លាំងទ័ពសេះ ពួកទាហានទ័ពសេះ តែងបានបំពាក់អាវក្រោះរហូតដល់ពេលប្រើប្រាស់កាំភ្លើងធំ និង កាំភ្លើងដៃក្នុងភាពប្រទុងប្រទាញ ដើម្បីរុញច្រានដណ្តើមប្រៀបគ្របដណ្តប់របស់កងទ័ពថ្មើរជើង រាប់ចាប់



www.elibraryofcambodia.org

តាំងពីពេលនោះមក ប្រៀបខ្លាំងអំពីចំនួន និងការផលិតអាវុធផ្គត់ផ្គង់ឲ្យកងទ័ព បានក្លាយជាកត្តាសំខាន់ក្នុងឆាកប្រយុទ្ធ ។ ដរាបណានៅសតវត្សទី ១៨ កងទ័ពនានានៅទ្វីបអឺរ៉ុប នៅមិនទាន់បានបំពាក់អាវុធនិងគុណភាពអាវុធទាំងនោះ ទៅឲ្យកងទ័ពថ្មើរជើងរបស់ខ្លួនទេ ដរាបនោះកត្តាសម្រេចក្នុងឆាកប្រយុទ្ធគឺចំនួនគ្រាប់កាំភ្លើងបាញ់ចេញ ក្នុងថេរវេលាកំណត់ណាមួយ ជាមួយនឹងការបាញ់ចំគោលដៅក៏នៅមានកម្រិតយ៉ាងនោះដែរ ។ ទ័ពថ្មើជើងបានចាប់ផ្ដើមចាត់តាំងទៅជាក្បួនទ័ព ដែលមានរូបភាពទ័ពបីជួរវែងៗ និងបានហ្វឹកហាត់យ៉ាងហ្មត់ចត់យ៉ាងស្ទាត់ជំនាញ ដើម្បីធ្វើយ៉ាងណាបាញ់បានជាប់គ្នាជាបន្តក្នុងល្បឿនប្រាំគ្រាប់ក្នុងមួយនាទី។ ជួរទ័ពវែងរបស់ភាគីនីមួយៗ រំកិលទៅមុខដោយដំណើរយឺតៗដើរបណ្ដើរបាញ់បណ្ដើរ ស្ថិតនៅក្រោមការបាញ់គាំទ្ររបស់ហ្វូងកាំភ្លើងធំ ដែលបានបាញ់រះ នៅខាងមុខជាញឹកញាប់។ ទីបញ្ចប់នៅពេលភាគី ម្ខាងត្រូវទទួលរងការវាយលុកយ៉ាងដំណំពីភាគីម្ខាង ហើយត្រូវបាត់



www.elibraryofcambodia.org

បង់ភាពម្ខាស់ការទៀតនោះ ទើបភាគីដែលមានប្រៀប ឆក់ឱកាសនោះ សម្រុកចូលធ្វើការវាយប្រហារដោយ ជំពុះទង់ ដើម្បីសម្រេចបញ្ចប់ឆាកប្រយុទ្ធតែម្តង។

ប្រសិន មុនពេលប្រយុទ្ធបានចាប់ផ្តើម មានភាគី ទ័ពណាមួយ បានដណ្តើមយកទីតាំងគោលដៅបាន មុននោះភាគីម្ខាងទៀតក៏ ព្យាយាមវាយលុកចូលជ្រុង ណាមួយ ដែលជាចំណុចខ្សោយរបស់ខ្មាំង ប្រយោជន៍ ធ្វើយ៉ាងណាហ៊ុមព័ទ្ធពីឆ្អឹងជំនី រួចធ្វើការឡោមព័ទ្ធ មួយផ្នែក នៃកងទ័ពសត្រូវ ។ បើចំណុចខ្លាំងរបស់ ទ័ពខ្លួនធ្វើឲ្យទ័ពខ្មាំង ដែលត្រូវហ៊ុមព័ទ្ធ និងទ័ពខ្មាំង នៅក្បែរៗនោះច្របូកច្របល់ ចលាចល ក្លាយជា ហ្វូងមនុស្ស ស្លន់ស្លោ ជាឱកាសឲ្យទ័ពខាងភាគី វាយលុក ប្រើប្រាស់ អាវុធធុនធ្ងន់ បាញ់សំដៅចូល ក្នុងជួរទ័ពខ្មាំងតែម្តង ។ នោះគឺជាវិធី ស្ទាត់ជំនាញ របស់អធិរាជ Phridrich ជាពិសេសក្នុងឆាកប្រយុទ្ធ នៅ Layten លោកបានប្រើប្រាស់វិធីវាយខាងលើ បាននាំមកភាពជោគជ័យត្រចះត្រចង់ ។ ក្រៅពីនេះ ជួនកាលគេនៅប្រើកម្លាំងទ័ពសេះ វាយចូលហ្វូង



www.elibraryofcambodia.org

មនុស្សឆ្លេឆ្លាទាំងនោះ ហើយក៏ទទួលបានជោគជ័យ ដូចគ្នាដែរ។ ប៉ុន្តែ ជារួមឆាកប្រយុទ្ធត្រូវបានបញ្ចប់ ភាគច្រើន គឺអាស្រ័យលើសព្វាវុធដែលបាញ់លឿន បាញ់ត្រង់ចំគោលដៅរបស់ទ័ពថ្មើរជើងជាកត្តាសម្រេច។ អាវុធទាំងនោះមានប្រសិទ្ធិភាពដល់កម្រិត ដែលធ្វើឲ្យឆាកប្រយុទ្ធនាសម័យនោះ ជាឆាកប្រយុទ្ធបង្ហូរឈាមយ៉ាងប្រល័យ យ៉ាងសាហាវក្រៃកន្លង ។ ក្នុងសមរភូមិ Colin កងទ័ពរបស់អធិរាជ Phridrich បានធ្វើឲ្យបាត់បង់ទ័ពចំនួន ១២០០០នាក់ ក្នុងចំណោម ១៨០០០នាក់ រីឯក្នុងសមរភូមិនៅ Cunec Sdocpher (គូណែកស្តុកភើរ) ចំនួនទ័ពបាត់បង់ជីវិតគឺ ១៧០០០ នាក់ ក្នុងចំណោម ៣០០០០នាក់ ។ ក្នុងពេលនោះ សមរភូមិនៅ Borodino ជាសមរភូមិប្រយុទ្ធ បង្ហូរឈាមខ្លាំងបំផុត នៃយុទ្ធនាការសឹករបស់ Napoleon កងទ័ពរបស់រុស្ស៊ីស្លាប់ និងរបួសពុំដល់ពាក់កណ្តាល នៃចំនួនទ័ពរបស់ពួកគេផង ។ សភាពការណ៍បដិវត្តនៅប្រទេសបារាំង និងវត្តមានរបស់ Napoleon បានធ្វើឲ្យផ្លាស់ប្តូរទាំងស្រុងនូវបរិបទនៃឆាកប្រយុទ្ធ។



www.elibraryofcambodia.org

កងទ័ពត្រូវបានចាត់តាំង ជាកងពលដែលមានចំនួនទ័ពប្រមាណ ១០០០០នាក់ រួមមានទ័ពថ្មើរជើង ទ័ពសេះ និងទ័ពកាំភ្លើងធំ ។ កងទ័ពទាំងនោះមិនត្រឹមតែប្រយុទ្ធក្រោមរូបភាព ជាជួរដូចមុនទេ ថែមទាំងរូបរួមប្រមូលផ្តុំបួនជ្រុង និងរូបភាពចេញជាក្រុមតូចៗទៀតផង។ ដោយមានរូបភាពប្រយុទ្ធដូចបានពោលខាងលើ ទើបសមរភូមិប្រយុទ្ធនីមួយៗ មិនចាំបាច់ស្ថិតនៅលើតែវាលរាបប៉ុណ្ណោះទេ វាអាចជាដីព្រៃកសិដ្ឋាន ភូមិករ ឬ ភូមិសាស្ត្រដីក្រឡុកក្រលៀតក្តុកឡើងចុះ ក៏អាច ធ្វើជាសមរភូមិប្រយុទ្ធបានដែរ។ នៅពេលរូបភាពប្រយុទ្ធថ្មីនោះបានរីករាលដាល ជាទូទៅសម្រាប់កងទ័ព ទើបរាល់ឆាកប្រយុទ្ធទាំងឡាយក៏បានប្រព្រឹត្តឡើងខុសពីពេលមុនៗផងដែរ ។ វាពុំដូចនៅសតវត្សទី ១៨ទៀតឡើយ ។ ទោះបីក្បួនទ័ពរៀបចំជាបីជួរទ័ពក៏ពិតមែន ក៏ប៉ុន្តែ វាសនាឆាកប្រយុទ្ធ ត្រូវបានដោះស្រាយដោយការវាយលុកពីរ ឬ បី លើកជាបន្តបន្ទាប់យ៉ាងរហ័សជាទីបំផុត។ នៅសតវត្សទី XIX ឆាកប្រយុទ្ធមួយអាចអូសបន្លាយ



www.elibraryofcambodia.org

ពេញមួយថ្ងៃ ពុំនោះសោតអាចទៅពី ពីរ ឬ បីថ្ងៃក៏មាន ។ ម្យ៉ាងទៀតនូវរាល់ការប៉ះទង្គិចគ្នា ការវាយបក ឬ ការចល័តទ័ព តែងនាំមកនូវលទ្ធផលខុសៗគ្នា ហើយសភាពការណ៍ក៏កើតឡើងថ្មីជាបន្តបន្ទាប់ផងដែរ ។ បច្ចុប្បន្ន ( ស.វ XIX ) ឆាកប្រយុទ្ធតែងចាប់ផ្តើមដោយកងទាហានជួរមុខនៃភាគីទាំងពីរ ធ្វើការវាយសម្រុក បញ្ជូនពួកទាហានប្រដាប់ដោយអាវុធទៅជួរមុខ និងក្រុមទាហានគាំទ្រ ទៅក្រោយ។ ក្នុងពេល ពួកទាហានប្រដាប់ដោយអាវុធនៅជួរមុខជួបការតតាំងដ៏ខ្លាំងក្លា (ការតតាំងនេះតែងកើតឡើងនៅភូមិសាស្ត្រដែល មានអំណោយផលដល់ការការពារ) ។ រួចកងកាំភ្លើងធំធន់ស្រាល ក៏បានបោះជំហ៊ានទៅមុខ ក្រោមការគាំទ្ររបស់ក្រុមទាហានមានអាវុធគ្រប់ដៃ និងមានទាហានទ័ពសេះខ្លះៗទៀតផង ។ ចំពោះកម្លាំងពិសេស របស់ទ័ពជួរមុខ (half back) ត្រូវធ្វើការដណ្តើមយកទីតាំង បន្ទាប់មកចាប់ផ្តើម បាញ់គ្រាប់ផ្លោងរណ្តើនចូលជារៀយៗ ប៉ុន្តែចំនួនគ្រាប់ផ្លោង ដែលត្រូវបាញ់គឺមានកំណត់



www.elibraryofcambodia.org

ដើម្បីបង្កភាពងាយស្រួលដល់កម្លាំង សៀបការណ៍ និងជាការបង្ខំឲ្យទ័ពខ្មាំងបង្ហាញខ្លួនផង ។ ស្របនឹងពេលវេលានោះ កងពលនានាក៏ឈានចូលកៀកគោលដៅ ហើយច្បាមយកទីតាំង ឬ ចំណុចខ្លះទៀត។ យោងតាមលក្ខណៈព័ត៌មាន អំពីសកម្មភាពរបស់ភាគីម្ខាងទៀត ដែលបានមកពីកម្លាំងសៀបការណ៍ ផ្ដល់ឲ្យ ភាគីត្រៀមវាយលុកបានដឹងច្បាស់ចំណុចងាយស្រួល សម្រាប់ការវាយលុក ពេលនោះ ទាហានប្រដាប់ដោយអាវុធ ត្រូវបានចាត់តាំងទៅខាងមុខ ក្រោមការគាំទ្ររបស់ទ័ពថ្មើជើង និងក្រុមកាំភ្លើងធំគាំទ្រ នៅកន្លែងចាំបាច់ ។ ការវាយលុកពីឆ្អឹងជំនី ត្រូវបានរៀបចំជាមុន ទាហានក៏ត្រូវបានប្រមូលផ្ដុំ ដើម្បីវាយលុកចូលចំណុចសំខាន់ៗរបស់ទ័ពសត្រូវ រីឯទ័ពសត្រូវ ក៏កំពុងអនុវត្តនូវរាល់វិធីសាស្ត្រប្រហាក់ប្រហែលបែបនេះដែរ ។ សកម្មភាពគំរាមកំហែងទីតាំងការពារត្រូវបានបំផុសបំផុលឡើង ឬ ក៏បានធ្វើឲ្យពួកកងទ័ពខ្មាំង ត្រូវប្រឈមមុខនឹងការវាយប្រហារ ខិតជិតមកដល់ ។ កងទ័ពបានចូល



www.elibraryofcambodia.org

ដល់កៀកទ័ពសត្រូវ បណ្ដាចំណុចដែលត្រូវវាយប្រហារ ក៏ត្រូវបានបញ្ជាក់យ៉ាងច្បាស់ដែរ កងកម្លាំងវាយលុកធំ បានចាកចេញពីកន្លែងលាក់ខ្លួន ដែលពួកគេបានដណ្ដើមកាន់កាប់ពីមុន ដើម្បីចេញដំណើរឆ្ពោះទៅសមរភូមិប្រយុទ្ធ។ ក្នុងដំណាក់កាលនេះ កាំភ្លើងគាំទ្ររបស់ទ័ពថ្មើជើងនៅខ្សែត្រៀមជួរមុខ និងកងកាំភ្លើងធំដែលកំពុងមានប្រៀប ធ្វើដំណើររុលទៅមុខសំដៅចូលកាន់ចំណុចដែលបម្រុងនឹងវាយលុក ទន្ទឹមនោះក៏មានការប៉ះទង្គិចបន្តិចបន្តួចរវាងទ័ពសេះដែលជាក្រុមតូចៗម្ដងម្កាលដែរ។ ការ ប្រយុទ្ធដើម្បីប្រជែងដណ្ដើមយកទីតាំងចំណុចសំខាន់ៗ បានចាប់ផ្ដើមចំណុច សំខាន់ៗទាំងនោះមានការប្រទង់ប្រទាញ ដណ្ដើមគ្នាទៅវិញទៅមក ក្នុងខណៈនោះភាគីទាំងសងខាង តែងបញ្ចេញកម្លាំងថ្មីជាបន្តបន្ទាប់។ នៅចន្លោះនៃចំណុចដែលប្រទង់ប្រទាញនោះ ឥឡូវបានក្លាយជាសមរភូមិ នៃបណ្ដាកងកម្លាំងថ្មើជើងពើបប្រយុទ្ធគ្នា ជួនកាលក៏ជាកន្លែងដែលកើតឡើងនូវឆាកប្រយុទ្ធកៀក វាយលុកដោយទល់មុខ ខ្លួន



www.elibraryofcambodia.org

ទល់ខ្លួនយ៉ាងពិតប្រាកដ។ ចំពោះតំបន់ភូមិករប្រជា-ជនតំបន់កសិដ្ឋាន ឬ តំបន់មានលេនដ្ឋានច្រើន គឺការប្រយុទ្ធដោយចំពុះទង់ តែងកើតឡើងជាញឹកញាប់។ នៅលើភូមិសាស្ត្រវាលរាបល្ហល្ហេវកងកម្លាំងទ័ពសេះត្រូវរកវិធី ដើម្បីធ្វើដំណើរទៅមុខជានិច្ចពិសេសនៅពេល ដែលមានឱកាសជាអំណោយផល រីឯកងកាំងភ្លើងធំ នៅតែបាញ់ ផ្លោងជាបន្តបន្ទាប់ ហើយធ្វើចលនាឆ្ពោះទៅមុខជានិច្ច ដើម្បីទៅកាន់ទីតាំងថ្មីដែលត្រូវទៅ ។ ដូច្នេះ ដរាបណាឆាកប្រយុទ្ធកំពុងតែនៅប្រទង់ប្រទាញគ្នា គោលគំនិតនិងការចាត់តាំងកម្លាំង ចូលរួមប្រយុទ្ធត្រូវបានប្រើប្រាស់ច្រើនឡើងៗទៅក្នុងសមរភូមិនោះ ដរាបនោះពុំទាន់អាចបំភ្លឺបានថា ភាគីខាងណាមានកម្លាំងរឹងមាំជាងខាងណា សម្រាប់ការវាយលុកចុងក្រោយនិងសម្រេចជោគវាសនា នៃសមរភូមិប្រយុទ្ធនេះបានឡើយ ។ ក្នុងខណៈនោះប្រសិនបើ ភាគីវាយលុកបានដណ្ដើមយកឈ្នះ ទើបពួកគេអាចបញ្ជូនកម្លាំងត្រៀមបម្រុងរបស់ខ្លួន ចូលមកចំកណ្ដាលសមរភូមិ



www.elibraryofcambodia.org

ឬ ពីខាងឆ្អឹងជំនីខ្សែត្រៀមការពារ ដើម្បីវាយសង្គ្រប់យកឈ្នះ បញ្ចប់ដោតវាសនាឆាកប្រយុទ្ធតែម្តង ប៉ុន្តែប្រសិនបើការវាយសម្រុកនានាមិនបានសម្រេច ហើយក៏គ្មានកម្លាំងថ្មីមកជួយបន្ថែមទៀតនោះ ភាគីខាងការពារ ឬ ត្រូវវាយលុក អាចនឹងបញ្ចូនកម្លាំងត្រៀមបម្រុងចេញមកប្រយុទ្ធតតាំង ដោយសន្ទុះយ៉ាងខ្លាំងក្លាធ្វើឲ្យសភាពការណ៍ ប្រែប្រួលពីការការពារទប់ទល់សត្រូវ ទៅជាការវាយប្រហារកំទេចសត្រូវទាំងស្រុងវិញ ។ ក្នុងករណីជាច្រើន ការវាយលុកតែងសំដៅទៅ លើចំណុចណាមួយលើខ្សែត្រៀមរបស់សត្រូវដើម្បីបុកទម្លុះ នៅត្រង់ចំណុចដែលបានជ្រើសរើស សម្រាប់វាយលុកបុកទម្លុះនោះ ត្រូវការ ប្រមូលផ្តុំកងកម្លាំងធំដល់កម្រិតខ្លាំងបំផុត រីឯកងទ័ពថ្មើរជើងក៏ត្រៀមលក្ខណៈ វាយលុកតាមរូបភាពបួនជ្រុង ដ៏ក្រាស់សន្ធឹកសន្ធាប់ផងដែរ ។ ពេលដែលការវាយលុកអាចដណ្តើមបានជ័យជំនះ ទើបកម្លាំងទ័ពសេះសម្រុកចូលកន្លែង ដែលបានបុកទម្លុះនោះរួចហើយធ្វើការឡោមព័ទ្ធ ពីខាងឆ្វេង និងខាងស្តាំ វាយលុក



www.elibraryofcambodia.org

ចូលពីឆ្អឹងជំនី និងពីក្រោយខ្នងនៃខ្សែត្រៀម របស់សត្រូវ ។ បង្ខំពួកវាត្រូវតែរេកម្លាំងទៅខាង (ងាយស្រួលនឹងការវាយកំទេច) ។ ក៏ប៉ុន្តែ បើចង់ឲ្យការវាយលុកក្លាយជាឆាកប្រយុទ្ធ មានលក្ខណៈសម្រេចបានយ៉ាងពិតប្រាកដនោះ ដាច់ខាតត្រូវប្រើកម្លាំងយ៉ាងច្រើន ក្រោយពីពេលសត្រូវបានបញ្ចេញកម្លាំងត្រៀមបម្រុង ជាចុងក្រោយរបស់ពួកវា ។ បើពុំនោះទេការខាតបង់ដែលត្រូវទទួលរង មិនតុល្យភាពទៅនឹងលទ្ធផលដែលទទួលបាននោះឡើយ ពុំនោះសោតវាក៏អាចក្លាយជាមូលហេតុនៃភាពបរាជ័យក៏ថាបាន។

ក្នុងករណីជាច្រើន មេបញ្ជាការជារឿយៗ តែងបញ្ឈប់ការប្រយុទ្ធ ហើយអនុវត្តពិធីដកថយដោយភាពមិនអំណោយផល ព្រោះគេមិនព្រមបញ្ចេញកម្លាំងត្រៀមចុងក្រោយរបស់ខ្លួន គេបែរជាទន្ទឹងរង់ចាំឆាកប្រយុទ្ធសម្រេចដោយភាគីខាងសត្រូវឯនោះវិញ ។ ស្ថិតក្នុងការចាត់តាំង និងយុទ្ធសាស្ត្រទំនើបគឺប្រការដកថយខាងលើ អាចប្រព្រឹត្តទៅបានលុះត្រាណា ការខាតបង់កើតមានតែបន្តិចបន្តួច ពីព្រោះ



www.elibraryofcambodia.org

ក្រោយពី ការប្រយុទ្ធដ៏ខ្លាំងក្លានោះ កងទ័ពសត្រូវក៏ទទួលរងនូវការខូចខាត និង ធ្លាក់ក្នុងសភាពវឹកវរច្របូកច្របល់ដែរ។ កងកម្លាំងត្រៀមបម្រុង និង កងកាំភ្លើងធំដែលដណ្ដើមយកបានទីតាំងថ្មី នៅខាងក្រោយខ្នង និង ក្រោមការជួយគាំទ្រនៃកម្លាំងខាងលើនេះ កម្លាំងទ័ពថ្មើជើងដកចេញ ពីឆាកប្រយុទ្ធជាបណ្ដើរៗ និងការដកថយតាមក្បួនយុទ្ធសាស្ត្រ។ ក្នុងករណីនេះ ការដកថយមានសណ្ដាប់ធ្នាប់ ឬ អត់នោះគឺអាស្រ័យទៅ លើល្បឿន នៃការដេញតាមវាយប្រហារពីសំណាក់ទ័ពខ្មាំង ។ ដើម្បីទប់ស្កាត់បណ្ដាអង្គភាព ដែលបម្រុងនឹងដករត់ចេញពីសមរភូមិប្រយុទ្ធ នោះកងទ័ពសត្រូវក៏តែងតែបញ្ចេញកម្លាំងទ័ពសេះ សម្រាប់ដេញតាម ប្រយុទ្ធជាការពិត ។ ហេតុនេះ ដើម្បីជួយដល់អង្គភាពទាំងនោះចាំបាច់ត្រូវមានកម្លាំងទ័ពសេះ ត្រៀមជាជំនួយឲ្យស្រេចដែរ។ ប៉ុន្តែ បើសិនកងទ័ពសេះខាងភាគីដកថយ ត្រូវបានវាយកំទេច រីឯទ័ពថ្មើជើងវិញ ក៏ត្រូវបានឃ្លាតឆ្ងាយដោយប្រញាប់ប្រញាល់ពេក សភាពបែបនេះភាគ



www.elibraryofcambodia.org

ច្រើន គឺត្រូវបានកំទេច ចំពោះឯកងទ័ពការពារខាងក្រោយក៏ពិបាក នឹងទទួលបានលេនដ្ឋានការពារដែរ ប្រសិនបើមេឃមិនទាន់យប់។

ការរៀបរាប់ខាងលើ ជារបៀបធម្មតានៃឆាកប្រយុទ្ធនាសម័យទំនើប(សតវត្សទី១៩)ក្នុងល័ក្ខខ័ណ្ឌភាគីទ័ពទាំងសងខាង មានចំនួនទ័ពនឹងកម្រិតនៃសមត្ថភាពដឹកនាំទ័ពប្រយុទ្ធប្រហាក់ប្រហែលគ្នា ។ ក្នុងករណីភាគីម្ខាងមានប្រៀបខ្លាំងជាង ច្បាស់ជាគ្មានអ្វីស្មុគស្មាញឡើយ ហើយវានឹងប្រព្រឹត្តទៅដោយរូបភាពប្រយុទ្ធ មានការគួបផ្សំគ្នាយ៉ាងសំបូរបែប ។ ទោះជាយ៉ាងណាក៏ដោយ នៅគ្រប់កាលៈទេសៈឆាកប្រយុទ្ធនាសម័យទំនើប រវាងកងទ័ពនៃបណ្ដាប្រទេសអភិវឌ្ឍ និយាយជារួម គឺមានលក្ខណៈមិនខុសពីអ្វីដែលបានពណ៌នាខាងលើឡើយ។

បកប្រែពី ប្រជុំនិក្ខេបទយោធា

Ph. Angghel សរសេរនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៨៥៧

បោះពុម្ពក្នុង "New American Cyclopaedia" ឆ្នាំ១៨៥៨



www.elibraryofcambodia.org

# ក្បួនយុទ្ធសាស្ត្រ

ក្បួនយុទ្ធសាស្ត្រ (ភាសាក្រិច Taktike សិល្បៈចាត់តាំងនៃកងទ័ពមួយ ) ។ ជាឈ្មោះរួបនៃបណ្ដាវិធីសាស្ត្រពើបប្រយុទ្ធ និងការវាយប្រហារ ទៅលើភាគីសត្រូវក្នុងសមរភូមិមួយ។ រាល់ការផ្លាស់ប្ដូរក្នុងទ្រឹស្ដី និងបច្ចេកទេសយោធា តាមរយៈនៃពេលវេលា និងសម័យកាលត្រូវបានឆ្លុះបញ្ចាំង ដោយការផ្លាស់ប្ដូរ ក្បួនយុទ្ធសាស្ត្រទាំងឡាយនៃសម័យកាលនោះ។ រហូតមកដល់សតវត្សរ៍ទី១៩ ក្បួនយុទ្ធសាស្ត្រជាច្រើន ដែលបានកើតឡើង ពីទ្រឹស្ដីសង្គ្រាម និងបានឆ្លងកាត់ការឆ្លុះបញ្ចាំង ដោយសមរភូមិពិតក៏ពិតមែន ប៉ុន្តែនៅមានកម្រិតនៅឡើយ។ ដូចជាក្នុងសមរភូមិប្រយុទ្ធមានបញ្ហាវិធីសាស្ត្រ នៃការដឹកនាំបញ្ហានៃការចាត់តាំងបណ្ដាអង្គភាព នៅនាសមរភូមិពិសេសនៅលើសមរភូមិជើងគោក (ទ័ពថ្មើរជើង) ។ ក្នុងគំនិតចក្ខុវិស័យយោធានាបច្ចុប្បន្ន យុទ្ធវិធីរួមមានៈ



www.elibraryofcambodia.org

កិច្ចការទាំងឡាយដូចជា ការប្រើប្រាស់កម្លាំងធ្វើយុទ្ធនាការសឹកក្នុងស្ថានភាពសមរភូមិជាក់ស្តែង ។

យុទ្ធវិធីផ្សេងពីយុទ្ធសាស្ត្រ ។ រាល់វិធីសាស្ត្រដែនការដាក់ឡើងឲ្យការអនុវត្តន៍ ដើម្បីដណ្តើមជ័យជំនះធំធេង យូរអង្វែង ហើយក៏ផ្សេងពីសិល្បៈ នៃយុទ្ធនាការសឹកក្នុងកម្រិតជាមធ្យមមួយដែរ ដោយគោលដៅគឺការធ្វើនយកម្មយុទ្ធសាស្ត្រឲ្យក្លាយទៅជាយុទ្ធវិធី។

យុទ្ធវិធីគឺ ជំនាញស៊ីជម្រៅ ដែលអនុវត្តសម្រាប់គ្រប់ស្ថានភាពសម្បូរបែប តាំងពីការការពារបន្ទុបមួយ ឬអាគារមួយខ្នង រហូតដល់យុទ្ធនាការសឹកក្នុងទ្រង់ទ្រាយធំ ដូចជាការដណ្តើមប្រៀបលើដែនអាកាស ឬ លើដែនទឹក នៃតំបន់មួយជាដើម ។ បច្ចុប្បន្នយុទ្ធសាស្ត្រយោធាត្រូវបានប្រើប្រាស់នៅគ្រប់កម្រិតបញ្ហាការទ័ព។ ចាប់តាំងពីបុគ្គលប្រយុទ្ធ ក្រុមប្រតិបត្តិការរហូតដល់យុទ្ធនាការសឹក នៃកងកម្លាំងប្រដាប់អាវុធមួយទាំងមូល ។ ជាការពិតណាស់បណ្តាអង្គភាពដែលបានប្រើប្រាស់ក្នុងសឹកសង្គ្រាម ក៏ដូចជាក្នុងជម្លោះ ឬវិវាទផ្សេងៗ តែងបានឆ្លុះបញ្ចាំងនូវរាល់យុទ្ធសាស្ត្រ



www.elibraryofcambodia.org

ទាំងបច្ចុប្បន្នភាព ទាំងទ្រង់ទ្រាយទៀតផង ។ ការ គួបផ្សំទាំងនោះ តែងប្រែប្រួលទៅតាមកាលៈទេសៈ គ្មានទីបញ្ចប់។

ជាទូទៅបណ្ដាយុទ្ធវិធីរួមមានៈ ការវាយលុកចំពីមុខ ការវាយឆ្មក់ពីស្លាបឆ្វេង ស្ដាំ ការវាយប្រហារពីក្រោយដោយវិធីបិទគួចតាមរូបភាពស្នែងក្របី ឬហៅមួយបែបទៀត គឺវិធីវាយឆ្មក់តាំងខ្ទប់ និងវិធីវាយលុកដកថយ ពោលគឺ វាយបណ្ដើរ ដកថយបណ្ដើរ។ រីឯយុទ្ធវិធី ដែលជាកលឧបាយក្នុងការប្រយុទ្ធមានដូចជា ការរក្សាការពារ កងកម្លាំងទ័ពបម្រុង និងការធ្វើការពួនស្ទាក់ ការបោកបញ្ឆោតក្នុងរូបភាពក្លែងភេទ ឬធ្វើឲ្យខ្មាំងបាត់បង់ទិសដៅ ដោយវិធីសំញែងទ័ពបំបាក់ស្មារតីប្រយុទ្ធជាដើម។ យុទ្ធវិធីជាមូលដ្ឋានមួយទៀតគឺ សង្គ្រាមលេណដ្ឋាន។ យុទ្ធវិធីនេះត្រូវបានប្រើប្រាស់ក្នុងសង្គ្រាមលោកលើកទីមួយ ក្នុងសមរភូមិ Galipli និងរណសិរ្ស បស្ចិមទិស។ សង្គ្រាមលេណដ្ឋានតែងនាំទៅដល់ការទល់ច្រក ពីព្រោះដើម្បីធ្វើការវាយលុកបានទៅលើភាគីខ្មាំង ដែល



www.elibraryofcambodia.org

មានលេណដ្ឋានការពារ គឺពួកពលទាហានកងទ័ពភាគីខាងវាយលុកទាំងនោះ ត្រូវឆ្លងកាត់ខ្សែត្រៀមការពារមួយដ៏រឹងមាំ ដោយស្ថិតនៅក្រោមហ្វូងគ្រាប់ផ្លោងបាចសាច ពួនជ្រំរបស់កាំភ្លើងធំទ័ពខ្មាំង យ៉ាងប្រល័យទើបអាច ឬពុំអាចសម្រេចដល់គោលដៅបាន។

បណ្តាយុទ្ធវិធីយោធា ដែលជាកលយុទ្ធត្រូវបានប្រើប្រាស់ក្នុងពេលពើបប្រយុទ្ធ ដើម្បីយកឈ្នះលើគូរសត្រូវមានវិធីជាមូលដ្ឋានពីរយ៉ាង ដើម្បីវាយប្រហារកំទេចកងទ័ពខ្មាំង៖ ធ្វើការវាយកំទេចទ័ពខ្មាំងតាមរយៈពើបប្រយុទ្ធ ដោយផ្ទាល់ ឬធ្វើការកាត់ផ្តាច់ប្រភពជំនួយផ្សេងៗ ធ្វើឲ្យទ័ពខ្មាំងមិនអាចរក្សាបានកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន នៅមូលកម្លាំងបានដោយគ្មានសល់នូវថ្នាំសង្កូវ ស្បៀងអាហារ ប្រភពទឹកប្រើប្រាស់ ហើយទីបញ្ចប់គឺ បាត់បង់កម្លាំងប្រយុទ្ធទាំងស្រុង។

ការធ្វើការឡោមព័ទ្ធជាយុទ្ធវិធីមួយ ដែលមានសារៈសំខាន់ និងពេញនិយមបំផុត។ កាលបើពើបប្រយុទ្ធភាគី ដែលត្រូវឡោមព័ទ្ធ និងត្រូវវាយប្រហារ



www.elibraryofcambodia.org

ពីគ្រប់ទិសទី បណ្ដាលឲ្យគេត្រូវធ្វើការប្រយុទ្ធទប់ទល់វិញយ៉ាងពិបាក។ ប៉ុន្តែកាលបើពុំបានពើបប្រយុទ្ធទេនោះ ការធ្វើការឡោមព័ទ្ធក៏នឹងអាចកាត់ផ្ដាច់ប្រភពជំនួយផ្សេងៗបានដែរ ។ អាស្រ័យហេតុនេះ ការឡោមព័ទ្ធគឺ ជាយុទ្ធវិធីមូលដ្ឋាន ដ៏សំខាន់មួយក្នុងសឹកសង្គ្រាមផងដែរ។ យើងគួរផ្ដោតជាសំខាន់ថា៖ យុទ្ធវិធីឡោមព័ទ្ធ ដែលមានល័ក្ខខណ្ឌប្រកបដោយអត្ថន័យជ្រាលជ្រៅ ហើយក៏ជាដំណោះស្រាយល្អនោះ លុះត្រាណាការអនុវត្តន៍មានប្រសិទ្ធិភាព ហើយបាននាំមកនូវលទ្ធផលល្អបំផុត។ ការវាយលុកដកថយ វាយបណ្ដើរ ដកថយបណ្ដើរ នោះក៏ជារបៀបនៃរូបភាពយុទ្ធវិធីឡោមព័ទ្ធដែរ តែឡោមព័ទ្ធក្នុងកម្រិតទាបជាង។ ការផ្ដុំកម្លាំងសន្ធាប់ដាក់សង្គ្រប់យក ជាយុទ្ធវិធីដែលស្ថិតនៅចំណាត់ថ្នាក់ទីពីរ ក្រោយពីយុទ្ធវិធីឡោមព័ទ្ធ។ យុទ្ធវិធីផ្ដុំកម្លាំងសន្ធប់ដាក់ គឺការប្រមូលផ្ដុំកម្លាំងសន្ធាប់ដាក់ ទៅលើចំណុចខ្សោយរបស់ទ័ពខ្មាំង។ ធ្វើការវាយឆ្មក់ ដោយពុំឲ្យខ្មាំងដឹងខ្លួន ដល់ថ្នាក់ដែលទ័ពខ្មាំងពុំអាចត្រៀមរៀបចំ ធ្វើការទប់ទល់នឹងគ្រោះ



www.elibraryofcambodia.org

អាសន្ន ដែលយើងវាយប្រហារនោះបានទាន់ពេល ។ សម្រាប់យុទ្ធវិធីនេះការឡោមព័ទ្ធ គឺមិនចាំបាច់ទេ ពីព្រោះកម្លាំងទ័ពយើងអាចវាយប្រហារកំទេចកងទ័ពខ្មាំងមួយចំណែកបាន ដោយការប្រើមហាកម្លាំងធ្វើការវាយប្រហារទ័ពខ្មាំង ដែលទន់ខ្សោយព្រោះត្រូវបែងចែកច្រើនក្រុម រួចហើយភ្លាមៗនោះយើងក៏ធ្វើការប្រមូលផ្តុំកម្លាំងឡើងវិញ ហើយផ្តុំកម្លាំងសន្ធាប់ដាក់ទៅលើផ្នែកផ្សេងៗទៀត របស់ទ័ពខ្មាំងជាបន្តបន្ទាប់ (ដែលហៅថា ការវាយប្រហារកំទេចទ័ពខ្មាំងតាមផ្នែកនីមួយៗ) ដោយទ័ពតិចឈ្នះទ័ពច្រើន ពីព្រោះទ័ពតិចប្រមូលផ្តុំ ទ័ពច្រើនត្រូវបែងចែកជាចំណែកជាផ្នែកតូចៗនេះឯង ។ បង្កើតភាពចៃដន្យ ភាពភ្ញាក់ផ្អើល បង្កប់កម្លាំងបែងចែក ចល័តកម្លាំងទ័ព និងការកំណត់គោលដៅច្បាស់លាស់ គឺជាកត្តាដ៏ចំបងនៃយុទ្ធវិធីនេះ ។ យុទ្ធវិធីនេះ វាអាស្រ័យទៅលើកងទ័ពខ្មាំង ដែលត្រូវធ្វើការបែងចែកកម្លាំងជាចំណែកស្មើៗ ហើយទ័ពខ្មាំងក៏ពុំអាចដឹងពុំអាចកំណត់បាន នូវចំណុចវាយប្រហារពី



www.elibraryofcambodia.org

កម្លាំងទ័ពយើង ។ ទ័ពខ្មាំង ត្រូវបង្ខំចិត្តបែងចែកកម្លាំងទ័ពការពារទាំងគ្រប់ចំណុចដែលមានកម្លាំងស្ទើងៗ ទាំងនោះ ។ ក្នុងពេលនោះ កងកម្លាំងវាយលុករបស់ទ័ពយើង ត្រូវបានប្រមូលផ្តុំសន្ធាប់ដាក់នៅត្រង់តែចំណុចមួយ ដែលទន់ខ្សោយរបស់ខ្មាំង ហើយធ្វើការវាយប្រហារ សង្គ្រប់យកតាមរបៀបនៃខ្លួន ។ ដើម្បីឲ្យទ័ពខ្មាំងបែងចែកកម្លាំងខ្លួនជាច្រើនចំណែកបាន ភាពចាំបាច់ត្រូវធ្វើយ៉ាងណា កុំឲ្យខ្មាំងកំណត់បានកងកម្លាំងពិសេស គោលដៅពិត និងចំណុចដែលត្រូវវាយប្រហារជាបន្តបន្ទាប់របស់ទ័ពយើង។ ធ្វើឲ្យទ័ពខ្មាំងយល់ថាចំណុចមួយណាក៏ត្រូវទ័ពយើងវាយប្រហារទាំងអស់ ។ ទ័ពខ្មាំងត្រូវការពារ គ្រប់ចំណុចទាំងអស់។ បញ្ហានេះការពិតជាកត្តាដ៏សែនពិបាកពេកណាស់ វាជារឿងដែលមិនងាយអនុវត្តបានដោយស្រួលៗនោះទេ។ ពីព្រោះភាគីទ័ពខ្មាំងក៏មានលទ្ធភាពសម្លឹងមកយើងដោយ ពិនិត្យតាមដាន ការដែលយើងធ្វើការប្រមូលផ្តុំកម្លាំង ហើយភាគីខ្មាំង ក៏នឹងមានប្រតិកម្ម ដោយធ្វើការបញ្ជូនកម្លាំងពិសេស



www.elibraryofcambodia.org

របស់ខ្លួនមកប្រយុទ្ធតទល់នឹងទ័ពយើងពុំខានឡើយ កាលបើវាក្តោបក្តាប់បានច្បាស់លាស់ នូវស្ថានភាពជាក់ស្តែង។

ការងារទ័ពជាការក្លែងភេទ លៃបំភន់ បោកបញ្ឆោតប្រកបដោយសិល្បៈលំអិតសុខម។ អ្នកណាធ្វើសកម្មភាពមានប្រសិទ្ធភាពដោយកម្រិតខ្ពស់ជាងអ្នកនោះនឹងឈ្នះ។

ជាធម្មតាយុទ្ធវិធីយកតិចឈ្នះច្រើននេះ វាគ្រាន់តែអនុវត្តបាននៅពេលណា ដែលទ័ពយើងមានអំណោយផល មានអទិភាព កម្លាំងទ័ពលើសលប់ជាពិសេសគឺ មានមេទ័ពពូកែ ឈ្លាសវៃពូកែក្នុងសឹកសង្គ្រាមដូច ស៊ុន ជឺ បានពោលៈ អ្នកដែលយល់បានថា ស្ថានភាពណាអាចវាយប្រហារទៅលើទ័ពខ្មាំងបាន ស្ថានភាពណាដែលពុំអាចវាយប្រហារបាន ទើបអាចវាយប្រហារយកឈ្នះបាន។ ហើយលោកថែមទាំងបាននិយាយទៀតថាៈ មេបញ្ជាការ ( មេទ័ព ) ណាដែលយល់បានថាទ័ពច្រើន ទ័ពតិច មានរបៀបប្រយុទ្ធខុសគ្នា ទើបអាចប្រយុទ្ធយកឈ្នះបាន។



www.elibraryofcambodia.org

ក្នុងយោធា ការដឹកនាំទ័ពប្រយុទ្ធ យកខ្លាំងវាយខ្សោយយកច្រើនទប់ទល់និងតិច ត្រូវបានគិតថាជារឿងធម្មតា។ ប៉ុន្តែផ្ទុយទៅវិញយកតិចឈ្នះច្រើន យកខ្សោយឈ្នះខ្លាំង នោះទើបជាអច្ឆរិយៈ ទើបទទួលបានការសរសើរ។ ឧទាហរណ៍ៈ ក្នុងសមរភូមិប្រយុទ្ធមួយរវាង ចូឆូ និង អួន ស៊ាវ ក្នុងសម័យសាមកុកចិន ចូឆូ មានទ័ពប្រហែលប្រាំពីរម៉ឺននាក់ អួន ស៊ាវ មានទ័ពប្រហែលទៅចិតសិបម៉ឺននាក់ លើសទ័ព ចូឆូ ដប់ដង ទីបំផុត ចូឆូ ជាអ្នកឈ្នះសង្គ្រាម។ រីឯសមរភូមិមួយទៀតក្នុងសម័យសាមកុកដែរ។ ចូឆូ មានទ័ពរាប់សិបម៉ឺននាក់ច្បាំងជាមួយស៊ុន កួន និង ឡាវពីបូកចូលគ្នាមានទ័ពប្រមាណពីរទៅបីម៉ឺននាក់តែប៉ុណ្ណោះ ទីបំផុត ចូឆូ ជាអ្នកចាញ់ទៅវិញ។ សមរភូមិមុនចូឆូដុតឃ្លាំងស្បៀងរបស់ អួន ស៊ាវ ចូឆូ ឈ្នះ សមរភូមិក្រោយ ចូឆូ ត្រូវ ស៊ុន កួន ដុតសំពៅរបស់ទ័ពខ្លួន ចូឆូជាអ្នកចាញ់វិញម្តង។ នេះជាសមរភូមិពីរ ដែលល្បីក្នុងសម័យសាមកុក ពីព្រោះហេតុផលមកពីភាគីខាងឈ្នះសង្គ្រាម បានច្នៃប្រឌិតនូវអច្ឆរិយៈកម្មយកតិច



www.elibraryofcambodia.org

ឈ្នះច្រើន។ ភាគីខាងខ្សោយដែលអាចយកខ្សោយឈ្នះខ្លាំងយកតិចឈ្នះច្រើនបាន ក៏ព្រោះតែគេដឹងទ័ពតិចត្រូវប្រយុទ្ធបែបណា? ហើយក៏គេដឹងថាក្នុងស្ថានភាពណាដែលអាចប្រយុទ្ធបាន ស្ថានភាពណាដែលមិនអាចប្រយុទ្ធនោះដែរ។ អ្នកដែលឈ្នះសមរភូមិមុនក៏ជាអ្នកចាញ់នៅសមរភូមិក្រោយ។ អ្នកទាំងពីគឺជាមនុស្សតែមួយ ចូឆូ នេះឯង។ សមរភូមិមុន ចូឆូយកខ្សោយឈ្នះខ្លាំង តែសមរភូមិក្រោយ ចូឆូ ជាអ្នកខ្លាំងបែជាចាញ់អ្នកខ្សោយទៅវិញ។ កត្តាខាងលើបញ្ជាក់ឲ្យឃើញថា ការដឹកនាំទ័ពបែបណា និងកលយុទ្ធដូចម្តេច វាសំខាន់ជាងកម្លាំងទ័ពតិច ឬច្រើនខ្សោយ ឬខ្លាំង។ កាលបើដឹងថាទ័ពត្រូវបញ្ជាដូចម្តេចសមរភូមិត្រូវប្រយុទ្ធបែបណានោះ ខ្សោយអាចឈ្នះខ្លាំង តិច អាចឈ្នះច្រើនបានដែរ។ រីឯយុទ្ធវិធីចន្លោះប្រហោង ភាពចន្លោះប្រហោង និងការផ្លោះផ្លោយក្នុងការដឹកនាំទ័ពប្រយុទ្ធតែងបង្ហាញនៅបីចំណុចៈ ទីមួយ គឺពួកមេបញ្ជាការទ័ពតែងមានការខ្វែងគំនិតគ្នាការខ្វែងគំនិតនោះហើយ អាចកើតនូវភាពជំទាស់



www.elibraryofcambodia.org

យោបល់ផ្ទៃក្នុង មិនឯកភាពក្នុងការធ្វើសកម្មភាពក្នុងយុទ្ធនាការ ការបញ្ជាទ័ពប្រយុទ្ធគឺខ្វះការឯកភាពសហការគ្នា។ ទីពីរក្នុងសមរភូមិប្រយុទ្ធធំមួយ ពេលចាត់តាំងកងទ័ពរមែងបន្សល់ទុក នៅចន្លោះប្រហោងណាមួយពុំខានឡើយ។ ទីបី គឺទំនាក់ទំនងរវាងជួរទ័ព ដែលចូលរួមក្នុងសមរភូមិប្រយុទ្ធ ក្នុងយុទ្ធនាការសឹកជាមួយគ្នា មានការខ្វែងគំនិតទំនាស់ផលប្រយោជន៍ការគម្លាតណាមួយ វានឹងកើតមានបាតុភាព ខ្លួនអ្នកណា អ្នកនោះដឹង ការងារអ្នកណា អ្នកនោះធ្វើ អ្នកណាក៏ចង់បានស្នាដៃ ចង់ជាធំរៀងៗខ្លួនដោយមិនព្រមសហការគ្នា។ ក្នុងសឹកសង្គ្រាម កាលបើក្តោបក្តាប់បានច្បាស់គោលការណ៍ « មើលភាពចន្លោះប្រហោង » របស់ទ័ពខ្មាំង យើងអាចទទួលបានផ្លែផ្កា លទ្ធផលគឺធ្វើការបែងចែកកម្លាំងខ្មាំងជាចំនែកតូចៗ ហើយធ្វើការវាយប្រហារចំណែកទាំងនោះម្តងមួយៗ។ ឧទាហរណ៍: កាលសម័យសង្គ្រាមលោកលើកទីពីរ។ សម្ព័ន្ធភាពយោធា អង់គ្លេស បារាំង បានរួមសហការគ្នាចាត់តាំងមហាទ័ពដ៏រឹងមាំមួយ នៅតំបន់វាលរាប



www.elibraryofcambodia.org

តាមបណ្ដោយឆ្នេរនៃឈូងសមុទ្រ Ingbit បំណាង ទប់ស្កាត់ការវាយលុកពីសំណាក់កងទ័ពអាល្លឺម៉ង់។ កងទ័ពអាល្លឺម៉ង់ ក្រោយពីបានមកដល់ខ្សែត្រៀមសមរភូមិមុខ ក៏បានក្រឡេកមើលឃើញស្ថានភាពកងទ័ពសម្ព័ន្ធមិត្ត ថ្វីត្បិតតែមានការចាត់ចែងសមរភូមិការពារដ៏រឹងមាំក៏ពិតមែន ប៉ុន្តែក៏នៅមានគម្លាតរវាងជួរទ័ពទាំងពីរ មានចន្លោះប្រហោងឆ្ងាយដាច់ពីគ្នា។ គម្លាតនេះហើយដែលកងទ័ពអាល្លឺម៉ង់ឆក់ឱកាសវាយលុកបុកទម្លុះតាមចន្លោះប្រហោងនោះ ធ្វើឲ្យប្រព័ន្ធការពារដ៏រឹងមាំ ដែលកងទ័ពប្រទេសទាំងពីរបានសាងឡើងត្រូវទទួលរងការវាយប្រហារយ៉ាងដំណំ។ នេះហើយភាពខ្វះចន្លោះក្នុងការរៀបចំក្បួនទ័ពក្នុងសមរភូមិប្រយុទ្ធ ឧទាហរណ៍មួយទៀត៖ ក្នុងសម័យកងទ័ពរំដោះចិនច្បាំងជាមួយកងទ័ពបក្សកុកមីងតាង។ ពេលនោះកងទ័ពកុកមិងតាងមានពីប្រភេទទ័ព។ ប្រភេទមួយមានខ្សែញាតិថ្នាក់ដឹកនាំ ប្រភេទមួយគ្មានខ្សែញាតិ។ ទ័ពដែលមានខ្សែញាតិត្រូវបានបំពាក់អាវុធទំនើប ផ្គត់ផ្គង់ស្បៀងបរិក្ខាបរិបូរ៍ រីឯប្រភេទ



www.elibraryofcambodia.org

ទ័ពមួយដែលគ្មានខ្សែញាតិ ត្រូវបានចាត់ទុកដូចកូន ចុង ម៉ែចុង ដោយបំពាក់អាវុធផុនអន់ ស្បៀងអាហារ យុទ្ធបរិក្ខា ក៏មិនគ្រប់គ្រាន់។ ដោយការបែងចែកនេះ ហើយ ធ្វើឲ្យមានទំនាស់ផ្ទៃក្នុងដែលជាចន្លោះប្រហោង ស៊ីរូងក្នុងជួរទ័ព ជាការមិនឯកភាពក្នុងការបញ្ជាទ័ព ប្រយុទ្ធក៏ដូចជាស្មារតីប្រយុទ្ធក្នុងសមរភូមិពិត។ ឆ្លៀត ក្នុងឱកាសនោះកងទ័ពរំដោះ ដែលដឹកនាំដោយលោក ប្រធាន ម៉ៅ ក៏បានលូកជ្រៅចូលទៅក្នុងទំនាស់នោះ ពុះជ្រែកបំបែកចេញជាចំណែកតូចៗ ហើយធ្វើការ វាយប្រហារសង្គ្រប់យកឈ្នះជាស្ថាពរ។ នេះជាភាព ចន្លោះប្រហោងដោយទំនាស់ផ្ទៃក្នុងរបស់ទ័ពខ្មាំង។ យុទ្ធវិធីវាយលុកដកថយ (វាយឆ្មក់ដកថយ) កាល បើភាគីខ្មាំងមានកម្លាំងទ័ពខ្សោយ ជាងកម្លាំងទ័ពយើង ហើយទ័ពខ្មាំងក៏ពុំអាចតស៊ូប្រយុទ្ធជាមួយការវាយ ប្រហារ ដោយកម្លាំងសាច់ដុំរបស់ទ័ពយើងបាននោះ ពេលនោះទ័ពខ្មាំងនឹងធ្វើការបែងចែកកម្លាំងទ័ព ជា ចំណែកជាក្រុមតូចៗ ដើម្បីចៀសវាងការវាយប្រហារ ដោយប្រការណាមួយពីសំណាក់ទ័ពយើង។ បណ្តា



www.elibraryofcambodia.org

ក្រុមទ័ពតូចៗនោះ តែងធ្វើការច្បាមកៀកជាប់ជាមួយនឹងគូរភាគីរបស់ខ្លួន ដោយអនុវត្តយុទ្ធវិធីជាក់ស្តែងតាមទិសដៅផ្សេងៗគ្នា ជាពិសេសនៅកន្លែងទីតាំងណាដែលគូភាគីពុំអាចប៉ាន់ប្រមាណបាន។ ហើយតែងតែធ្វើការឆ្មក់វាយប្រហារ បង្កមហន្តរាយទៅលើគូរសត្រូវ រួចហើយដកថយភ្លាមៗមុនពេលគូរសត្រូវរបស់ខ្លួនមានឱកាសប្រតិកម្ម វាយបកតបវិញ។ យុទ្ធវិធីនេះហៅថាសង្គ្រាមកងឆ្លប។ ដើម្បីធ្វើការទប់ទល់ជាមួយនឹងយុទ្ធវិធីនេះ សម្រាប់កងទ័ពដែលមានកម្លាំងទ័ពច្រើនជាងខ្លួនត្រូវចាត់ក្រុមសើបអង្កេត ដើម្បីកំណត់ទីតាំងគោលដៅលាក់ខ្លួនរបស់ក្រុមតូចៗ ទាំងនោះ ហើយចាត់វិធានការវាយប្រហារកំទេចក្រុមទាំងនោះម្តងមួយៗ។ វិធីនេះទំនងជាមិនអាចអនុវត្តទៅបាន កាលបើក្រុមទ័ពខ្មាំងតូចៗទាំងនោះបានបង្កប់លាក់ខ្លួននៅក្នុងព្រៃស្រោង ល្អាងភ្នំក្រមថ្ម កណ្តាលក្រុង ទីប្រជុំជន ឬ នៅទីតាំងទាំងឡាយដែលមានភាពប្រហាក់ប្រហែល ដែលពុំមានទីកំណត់ជាក់លាក់ច្បាស់លាស់ណាមួយ។ ក្នុងប្រវត្តិសាស្ត្រយោធាមាន



www.elibraryofcambodia.org

កងទ័ពទាំងឡាយដែលមានកម្លាំងទ័ពច្រើន ខ្លាំងរឹងមាំ តែងត្រូវបានវាយប្រហារដោយការឆ្មក់វាយពីសំណាក់ ទ័ពព្រៃ ដែលមានចំនួនទ័ពតិចទ្រង់ទ្រាយតូចជាង ប៉ុន្តែភាពចល័តរបស់គេលឿនរហ័សជាង។ ក្នុងពេល មនុស្សភាគច្រើនមិនអាចមើលឃើញបញ្ហានេះ យុទ្ធវិធី វាយឆ្មក់ដកថយនេះ រមែងនៅមានប្រសិទ្ធភាព សម្រាប់ជួរកងទ័ពធំ ដែលមានកម្លាំងទ័ពច្រើននោះ ផងដែរ។ ពេលដែលទ័ពខ្មាំងបាននឹងកំពុងតែប្រមូល ផ្តុំកម្លាំងទ័ពស្រួច ទ័ពពិសេស នៅទីតាំងណាមួយ ក្នុងសមរភូមិប្រយុទ្ធ ក្រុមវាយឆ្មក់តូចៗសហការគ្នា យ៉ាងស៊ីសង្វាក់រួមជាមួយអាវុធដែលមានកម្លាំងបំផ្លាញ ធំធេង និងប្រភេទអាវុធសាមញ្ញ តែចំឡែកៗ ដែល ទ័ពខ្មាំងមិនអាចគិតស្មានត្រូវ ដូចជាការជីករណ្តៅ ដាក់ចំរោងដែក ឬ ឫស្សី ធ្វើជំពាមការស៊ូឃីតគ្រាប់ បែកដៃពីចម្ងាយ ដោយមិនឮសម្លេងផ្ទុះចេញពីទីណា ដែលជាទីចាប់ផ្តើម។ អាវុធសាមញ្ញចំឡែកៗនេះហើយ ដែលអាចបង្កមហន្តរាយធំធេងទៅលើទីតាំងទ័ព ដែល មានការការពារដ៏រឹងមាំរបស់គូរសត្រូវ ពុំនោះសោត



www.elibraryofcambodia.org

វាអាចធ្វើឲ្យខាតបង់អាយុជីវិតជូរទ័ពពិសេសរបស់សត្រូវយ៉ាងច្រើន ដោយចំណាយកម្លាំងប្រយុទ្ធយ៉ាងតិចបំផុត។

- **គោលការនៃសមរភូមិប្រយុទ្ធ**

❖ *យុទ្ធវិធីពង្រាយទ័ព*

ការនិយមជាទូទៅពេលភាគីចម្បាំងទាំងសងខាងសំញែងទ័ពប្រឈមមុខដាក់គ្នា គេតែងពង្រាយទ័ពជាជួរទទឹងទល់មុខដាក់គ្នា។ មូលហេតុជាប្រយោជន៍គឺ ដើម្បីកុំឲ្យភាគីទ័ពខ្មាំងធ្វើការឡោមព័ទ្ធវាយប្រហារមកលើទ័ពខ្លួនបាន។ យើងមិនត្រូវពង្រាយជួរទ័ពនោះស្តើងពេកទេ ពីព្រោះភាគីសត្រូវអាចប្រើប្រាស់កងកម្លាំងពិសេស ឬទ័ពស្រួចធ្វើការវាយប្រហារបុកទម្លុះកម្លាំងទ័ពយើង ដោយប្រការណាមួយជាយថាហេតុ។ ដោយឡែកក៏មិនគួរប្រមូលផ្តុំកម្លាំងទ័ព ឬពូនផ្តុំនៅកន្លែងទីតាំងមួយច្រើនពេកដែរ។ ព្រោះជាការងាយស្រួលឲ្យទ័ពខ្មាំងឡោមព័ទ្ធ ឬក៏អាចក្លាយជាគោលដៅបាញ់កំទេច វាយប្រហារពីសំណាក់ទ័ពខ្មាំង។ មានសៀវភៅជាច្រើន ដែលបានសរសេរ



www.elibraryofcambodia.org

បានពិភាក្សាអំពីយុទ្ធវិធី និងបទពិសោធន៍នៃការពង្រាយទ័ព ធ្វើយ៉ាងណាឲ្យបានសមស្របទៅនឹងស្ថានភាពពិតក្នុងសមរភូមិប្រយុទ្ធជាអាថិដូចសៀវភៅប្រជុំនិក្ខេបបទយោធា របស់លោក Phri Drick Angel (ហ្វ្រីឌ្រីកអងហ្គែល) ជាដើម។ « ប្រឡូកចូលសមរភូមិពិតរួចហើយយើងនឹងដឹង» Napoleon។ល។

❖ *រក្សាគម្លាត*

បណ្ដាកងទ័ព នៃភាគីចម្បាំងពេលដែលពង្រាយទ័ពជាជួរទទឹងធម្មតាតែងពង្រាយទ័ពស្ថិតនៅក្រៅរង្វង់ផ្លែព្រួញ ឬគ្រាប់ផ្លោងពីភាគីម្ខាងទៀត ពោលគឺឲ្យផុតពីការបញ្ចេញប្រសិទ្ធភាពនៃអាវុធរបស់ទ័ពខ្មាំង។ បទពិសោធន៍ និងភាពជាក់ស្ដែងនេះ គឺជាកត្តាឥតឯាករេ ឥតប្រែប្រួលឡើយ ក្នុងប្រវត្តិយោធាតាំងពីយូរលង់។ កត្តានេះក៏ជាការរក្សាសុវត្ថិភាពរបស់ទាហានម្នាក់ៗ រហូតដល់ពេលកងទ័ពទាំងមូលបានធ្វើការត្រៀមប្រយុទ្ធរួចរាល់មុនពេលបើកប្រយុទ្ធ។ ក្នុងខណៈពេលដែលក្រុមទ័ពភាគីណាមួយបានរុលទៅមុខដល់ខ្សែត្រៀម ស្ថិតក្នុងប្រសិទ្ធភាពគ្រាប់ផ្លោងរបស់ទ័ព



www.elibraryofcambodia.org

ខ្មាំង គឺត្រូវរងការវាយប្រហារពីភាគីខ្មាំងពុំខានឡើយ។ ថ្វីត្បិតដំណើររុលទៅមុខប្រកបដោយគ្រោះថ្នាក់ក្តី ប៉ុន្តែកាលបើភាគីខ្មាំងពុំអាចមើលឃើញទាន់ពេល នូវការច្បាមកៀកនោះ ឬដោយសាទ័ពដែលជាក្រុមតូចៗនោះ ចេះពួនលាក់ខ្លួនបានល្អ ធ្វើការវាយប្រហារក្នុងល្បឿនលឿនរហ័ស ធ្វើឲ្យភាគីសត្រូវរបស់ខ្លួនវេខ្លួនប្រតិកម្មមិនទាន់ពេល។ ក្រុមទាហានដែលមានចំនួនតិចទ្រង់ទ្រាយតូចក៏ពិតមែន ប៉ុន្តែអាចបង្កមហន្តរាយយ៉ាងធំធេងដល់ភាគីសត្រូវបានដែរ។ ពេលក្រុមទាហានទាំងនោះបានចូលកៀកទ័ពខ្មាំងហើយ បណ្តាផ្នែកទ័ពប្រយុទ្ធផ្សេងៗរបស់គេក៏រុលឡើងទៅមុខយ៉ាងលឿនរហ័សដោយឆ្លងតាមចន្លោះប្រហោង ដែលត្រូវបានបុកទម្លុះលើខ្សែត្រៀមការពាររបស់ភាគីទ័ពខ្មាំង កម្លាំងក្រុមទ័ពតូចៗទាំងនោះ និងបណ្តាផ្នែកទ័ពប្រយុទ្ធផ្សេងៗទាំងប៉ុន្មានគេនឹងវិលបកមកវិញ ធ្វើការវាយប្រហារពីក្រោយទ័ពខ្មាំង ពេលនោះវានឹងបង្កើតបានប្រៀបមួយក្នុងសមរភូមិប្រយុទ្ធ គឺប្រៀបឡោមព័ទ្ធ។ ទ័ពខ្មាំងត្រូវបានឡោមព័ទ្ធ។ យុទ្ធវិធីនេះអាចហៅថា



www.elibraryofcambodia.org

សង្គ្រាមផ្ការីផ្សំជាមួយការឡោមព័ទ្ធ។ ការរក្សាគម្លាតមុនពេលបើបប្រយុទ្ធ គឺជាបញ្ហារួមនៃសិល្បវិធីសង្គ្រាម ក្នុងនោះរាប់ទាំងភាពក្លាហាន ភាពឈ្លាសវៃបំណិនប្រយុទ្ធ ជាលក្ខណៈបុគ្គលផងដែរ។ យើងងាកមកពិចារណាទៅលើក្បាច់គុននានាដូចជា ក្បាច់គុនតាក្វាន់ដូ ( Tackwondo ) គុនតំបង គុនដាវ ក្បាច់គុនប្រដាល់បុរាណខ្មែរជាដើម។ ការរក្សាគម្លាតចម្ងាយជាបញ្ហា ដែលមានសារៈសំខាន់បំផុត។ ចំណុចគួរចាប់អារម្មណ៍មួយដែលជាភាពចាំបាច់នោះគឺ ពុំមានគូរប្រកួត ក្រុមប្រយុទ្ធ ឬក្រុមជួរទ័ពនៃភាគីណាមួយដែលមានគម្លាតចម្ងាយក្នុងការប្រយុទ្ធប្រកបដោយប្រសិទ្ធភាព និងលទ្ធភាពដូចគ្នានោះទេ។ យល់ដឹងភាពខុសគ្នានេះ គឺជាខឿនគ្រឹះដ៏រឹងមាំក្នុងយុទ្ធសាស្ត្រហើយវាក៏ជាមូលដ្ឋាន ដែលមានសារៈសំខាន់ណាស់ដែរចំពោះយុទ្ធវិធី។ វិធីសាស្ត្រមួយ ដើម្បីពិចារណាអំពីគម្លាតចម្ងាយក្នុងឆាកប្រយុទ្ធ ឬការប្រកួតប្រជែងណាមួយ និងសារៈសំខាន់របស់វា។ យើងគួរស្រមៃគិតទៅលើកីឡាប្រដាល់ពីរនាក់ដែលឈរទល់មុខគ្នា



www.elibraryofcambodia.org

នៅលើសង្វៀន ម្នាក់ ដែលមានប្រវែងមួយលូកដៃរបស់គេវែងជាងគូរប្រកួតរបស់ខ្លួន 15cm គេនឹងអាចលូកវាយ ឬដាល់ត្រូវគូរប្រកួតរបស់ខ្លួនក្នុងពេលដែលមិនបានទទួលរងពីការលូកវាយបក ឬដាល់តបវិញរបស់គូរប្រកួតក្នុងគម្លាតចម្ងាយតែមួយដូចគ្នា។ ក្នុងប្រវត្តិសឹកសង្គ្រាមពិភពលោកមានបទពិសោធន៍ជាច្រើនដែលជាមេរៀនយោធាស្តីពីការខុសគ្នា និងសារៈសំខាន់នៃប្រវែងគម្លាតចម្ងាយក្នុងសមរភូមិប្រយុទ្ធ មានដូចនៅសមរភូមិ Agin Court ជាដើម ក្នុងនោះកងទ័ពបាញ់ធ្នូរបស់ទ័ពអង់គ្លេសត្រូវបានប្រើប្រាស់មុនបង្អស់ដើម្បីទប់ទល់ជាមួយទ័ពសេះរបស់ទ័ពខ្មាំង។ ភូមិសាស្ត្រ ក៏ជាកត្តាមួយក្នុងសមរភូមិប្រយុទ្ធបែបបុរាណដែលមិនអាចមើលរំលងខណៈពេល ដែលគិតអំពីគម្លាតចម្ងាយ របស់ទីតាំងទ័ពមុនពេលពើបប្រយុទ្ធនោះដែរ។

❖ *ភាពចល័ត*

វិធីមួយក្នុងចំណោមវិធីដ៏ល្អបំផុត ដើម្បីបុកទម្លុះខ្សែត្រៀម ឬបណ្តាញឡោមព័ទ្ធ របស់ទ័ពខ្មាំង គឺ



www.elibraryofcambodia.org

ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូន។ ក្នុងអតីតកាល មធ្យោបាយដឹកជញ្ជូនសំខាន់គឺប្រើសេះ។ បច្ចុប្បន្នគេប្រើរថក្រោះ រថពាសដែកដឹកជញ្ជូនទ័ព ប្រើឧត្ថម្ភកចក្រយន្តហោះឡើងត្រង់ និងយន្តហោះដឹកទាហានលោតឆ័ត្រ (ឆ័ត្រយោង) ដែលត្រូវបានប្រមូលផ្តុំ និងពេញនិយម។ មធ្យោបាយទាំងនេះជំនួយឲ្យកងទ័ពក្រុមមួយអាចធ្វើការឡោមព័ទ្ធ ឬ ចល័តទ័ពវាងពីខាងក្រោយ ឬ គាបពីខាងជួរទ័ពខ្មាំង ហើយចូលកៀកទ័ពខ្មាំងនៅជួរក្រោយ ឬសងខាងក្នុងពេលកម្លាំងទ័ពធំ ទ័ពពិសេសរបស់ខ្លួនកំពុងធ្វើការវាយលុកចំពីមុខទ័ពខ្មាំង។ ការរៀបចំនូវរាល់មធ្យោបាយដឹកជញ្ជូនទាំងនេះ ជានិច្ចកាលតែងមានការខូចខាតបាត់បង់ច្រើនជាងការកសាងកម្លាំងប្រដាប់អាវុធ ទ័ពថ្មើជើង។ អាស្រ័យហេតុនេះ កងកម្លាំងទ័ពចល័តកម្រិតខ្ពស់គ្រាន់តែមានមួយចំណែកក្នុងជួរទ័ពមួយទាំងមូលតែប៉ុណ្ណោះ ។ លក្ខណៈជាគុណសម្បត្តិរបស់កងទ័ពទាំងនេះ គឺស្ថិតនៅលើភាពចល័ត ពិសេសរបស់ខ្លួនក្នុងករណីជាក់ស្តែង ចល័តនៅដីវាលរាប (ថ្មើរជើង) គឺ



www.elibraryofcambodia.org

ពួកគេធ្វើសកម្មភាពរហ័សរហួន បុកទម្លុះខ្សែត្រៀមការពាររបស់ទ័ពខ្មាំង វាយសង្គ្រប់កាត់ផ្តាច់លុកលុយទំលាយចូលទៅជួរក្រោយ ឬពីខាងរបស់ទ័ពខ្មាំង។ រថក្រោះសម័យទំនើប ត្រូវបានប្រើប្រាស់ប្រហាក់ប្រហែលទៅនឹងទ័ពសេះ ក្នុងសមរភូមិពីសម័យមុន វាធ្វើឲ្យមានប្រសិទ្ធិភាពគ្រប់គ្រងទ័ព ចំពោះភាគីណាដែលចេះប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព ។ កាលពីសម័យដើមតែងមានមតិយោបល់ថា ភាពចល័តគ្រាន់តែបម្រើគោលបំណងផ្លាស់ទីតាំង និងធ្វើចារកិច្ចតែប៉ុណ្ណោះ។ កត្តានេះមិនត្រឹមត្រូវទេ ដោយសារទ័ពចល័តនៅគ្រប់ដំណាក់កាលនាសម័យបុរាណនោះ តែងជាមធ្យោបាយចល័តទ័ពដ៏ពិសេស ហើយក៏ជាគោលបំណងដំបូង និងមានសារៈសំខាន់ចំពោះការផ្លោះរំលងលើជួរទ័ពខ្មាំង ដើម្បីកាត់ផ្តាច់ទំនាក់ទំនងក្នុងជួរទ័ពខ្មាំង ធ្វើឲ្យភាគីខ្មាំងថយកម្លាំងខ្សោយប្រៀប ជ្រួលច្របល់បាត់សណ្តាប់ធ្នាប់ត្រូវទទួលរងការវាយប្រហារសង្គ្រប់លើ និងត្រូវកំទេចបង់ ។ ការចល័តទ័ពតាមអាកាសនាសម័យទំនើប ក៏មាន



www.elibraryofcambodia.org

ប្រសិទ្ធភាពគួរជាទីទាក់ទាញគួរចាប់អារម្មណ៍ណាស់ដែរចំពោះយុទ្ធវិធីនេះ ពីព្រោះការវាយប្រហារនីមួយៗតែងមានកំពស់ពី10000m នៅលើអាកាស ដែលជាការពិបាកទប់ទល់បំផុត។

❖ *ការការពារ*

នៅសមរភូមិប្រយុទ្ធ ការការពារ ជាកត្តាចាំបាច់បំផុត។ មានវិធីមួយចំនួនដែលធ្វើឲ្យកងទ័ព៖

១- ស្ថិតនៅក្រៅរង្វង់គ្រាប់ផ្លោងរបស់ទ័ពខ្មាំង។

២- លាក់ខ្លួនមិនឲ្យមើលឃើញបញ្ចៀសបានការវាយប្រហារពីភាគីខ្មាំង។

៣- ពាក់អាវក្រោះអាចការពារបាននូវប្រភេទគ្រាប់រំសេវធុនស្រាលរបស់ខ្មាំងក្នុងកម្រិតណាមួយដែរ រថសឹករថក្រោះ ក៏ជាឧទាហរណ៍មួយក្នុងរូបភាពជាក្រោះការពារម្យ៉ាងដែរ។

៤- កសាងប៉ុស្តិ៍ប៉ម កំពែង លេណដ្ឋាន ជីករណ្ដៅវាយចំរោង ចំការមីន ដើម្បីរាំងទ័ពខ្មាំង និងធ្វើការការពា ទប់ទល់ជាមួយអាវុធយុទ្ធភ័ណ្ឌ ពីខាងទ័ពខ្មាំង ដោយមធ្យោបាយផ្សេងៗតាមភាពជាក់



www.elibraryofcambodia.org

ស្តែង និងលទ្ធភាពដែលអាចធ្វើបាន។

❖ *បំណិនប្រយុទ្ធជាលក្ខណៈបុគ្គល(យុទ្ធវិធីបុគ្គល)*

បំណិនប្រយុទ្ធ រួមមានយុទ្ធវិធីដូចដែលបានពោលខាងលើ សម្រាប់បុគ្គល ឬការប្រយុទ្ធជាក្រុម។ នៅកម្រិតជាលក្ខណៈបុគ្គល ល្បឿននិងការវាយលុកចំគោលដៅជាកត្តាសំខាន់បំផុត។ ការវាយលុកចំគោលដៅកាន់តែមានកម្រិតខ្ពស់ កាន់តែល្អសម្រាប់ការវាយប្រហារទៅលើទ័ពខ្មាំង នៅពេលដែលទ័ពខ្មាំងស្ថិតនៅក្រៅរង្វង់ នៃគ្រាប់ផ្លោងរបស់យើង នោះគឺជាបំណិនមូលដ្ឋាន។ យើងគួរដឹងដែរថាទ័ពខ្មាំងតែងមានគោលការណ៍នៅក្រៅរង្វង់ប្រសិទ្ធភាព នៃគ្រាប់ផ្លោង ដែលវាយប្រហារពីភាគីម្ខាងទៀត។ ហេតុនេះកាលបើធ្វើការវាយប្រហារចំគោលដៅទ័ពខ្មាំង ដែលស្ថិតនៅក្រៅរង្វង់ប្រសិទ្ធភាពគ្រាប់ផ្លោងនោះ វាជាគុណប្រយោជន៍ធំធេងក្នុងឆាកប្រយុទ្ធ នៃសមរភូមិនោះ។ កត្តានេះចាំបាច់ត្រូវមានការហ្វឹកហាត់ឲ្យបានច្រើន បានស្ទាត់ជំនាញ និងធ្វើការអភិវឌ្ឍន៍បណ្តាបច្ចេកទេសលើអាវុធទំនើប ដែលមានប្រៀបជាងទ័ពខ្មាំង។

❖ *ល្បឿន* ជាកត្តាចាំបាច់បំផុតពោលគឺធ្វើយ៉ាងណា



www.elibraryofcambodia.org

ដើម្បីវាយប្រហារទៅលើទ័ពខ្មាំង ឲ្យបានមុនពេលទ័ពខ្មាំងធ្វើការវាយបកតបវិញ។ មានន័យថា យើងត្រូវធ្វើសកម្មភាពឲ្យបានរហ័សជាងទ័ពខ្មាំង នូវគ្រប់ចង្វាក់ប្រយុទ្ធ។ ដូចជាយុទ្ធវិធីដែលបានថែងខាងលើដែរ ចាំបាច់ត្រូវមានភាពចំគ្រង់ ទោះជាសកម្មភាពនោះស្ថិតនៅកម្រិតណាក៏ដោយ។

❖ *ស្វាយការពារ*

ពល់បំណិននៃការការពារដូច ដែលបានថែងខាងលើវាក៏ជាបំណិន នៃស្វាយការពារសម្រាប់ការអនុវត្តន៍ចំពោះបុគ្គលប្រយុទ្ធ នៃយុទ្ធជនម្នាក់ៗបានដែរ។

ការហ្វឹកហាត់ស្វាយការពារ នាសមរភូមិប្រយុទ្ធក៏មានសារសំខាន់ដូចការហ្វឹកហាត់ ប្រើប្រាស់អាវុធប្រសិទ្ធភាពនោះដែរ។ យុទ្ធវិធីនៃសម័យកាលនីមួយៗតែងផ្លាស់ប្តូរសម្របទៅតាមសមរភូមិពិត នៃសម័យកាលនោះ ដោយប្រើប្រាស់អាវុធ និងមធ្យោបាយបែបណា។ បច្ចុប្បន្នដែលប្រើប្រាស់មធ្យោបាយ និងអាវុធទំនើបក៏ពិតមែន ប៉ុន្តែបើបានសិក្សាក្បួនយុទ្ធសាស្ត្រសម័យមុនៗ វានឹងមានភាពសម្បូរបែបក្នុងសមរភូមិប្រយុទ្ធប្រកបដោយប្រសិទ្ធភាពពុំខានឡើយ។



www.elibraryofcambodia.org

## គោលការណ៍ប្រាំបួនចំណុច របស់ទ័ពជើងទឹកអាមេរិកមាន ៖

- គោលការណ៍ គោលដៅ
- គោលការណ៍ វាយលុក
- គោលការណ៍ ប្រមូលផ្តុំ
- គោលការណ៍ សំចៃកម្លាំងមនុស្ស
- គោលការណ៍ ចល័តទ័ព
- គោលការណ៍ បញ្ជាការឯកភាព
- គោលការណ៍ សុវត្ថិភាពកម្លាំងប្រយុទ្ធ
- គោលការណ៍ សកម្មភាពឆាប់រហ័ស
- គោលការណ៍ បំព្រួញខ្លី (សាម្មញ្ញភាព)

គោលការណ៍ទាំងប្រាំបួនយ៉ាងនេះ ផ្តោតជាសំខាន់ទៅលើមូលដ្ឋាន នៃស្មារតីប្រយុទ្ធ និងទ្រឹស្តីប្រយុទ្ធ ដែលជាគោលការណ៍ចម្រាញ់ ដកស្រង់ចេញពី ***ពិជ័យសង្គ្រាមស៊ុនជឺ*** ក៏ប៉ុន្តែ វាតម្រូវការតាមភាពជាក់ស្តែង ភាពប្រាកដនិយម និងការវិវត្ត នៃសម័យកាលរបស់វា ។ នេះហើយដែលថា " បុរាណអភិរក្សទំនើបអភិវឌ្ឍន៍ " ។



ជ័យ សេន
www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ចៅ ឃុនសំរ៉ង ខ្ចៅ យ៉ាតណៃ ខ្ចៅសុខផល ខ្ចៅ វិសាល ខ្ចៅ រ៉ាមុន

ខ្ចៅ ភារាដា ខ្ចៅ ចំរើន ខ្ចៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្ចៅ ពាញ** និង ឧបាសិកា **ឈរ យឿន**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **លី សិរីរ័ត្ន**

កញ្ញា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ចៅ ឃុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

«... ក្នុងសមរភូមិប្រយុទ្ធ ក្រៅពីកត្តាកម្លាំងទ័ព អាវុធយុទ្ធភណ្ឌ នឹងភាពសំណាងផលផ្សេងៗ អ្នកណា ដែលក្ដាប់ច្បាស់សិល្ប៍សាស្ត្រសង្គ្រាម អ្នកនោះនឹងមានឱកាសឈ្នះច្រើនជាង បើគេជាភាគីខាងខ្លាំង។ ប៉ុន្តែក៏ជាឱកាសជួយបញ្ចៀសភាពបរាជ័យច្រើនជាងដែរ សម្រាប់អ្នកដែលជាភាគីខាងខ្សោយ។ ធម្មតាជាអ្នកខ្សោយ ប៉ុន្តែ គេចផុតពីភាពបរាជ័យបាន វាក៏សក្តិសមស្មើដូចជាអ្នកឈ្នះនោះដែរ ...»។

